**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Economiques**

**Royal university of Law and Economics**


## សារណាបញ្ចប់ការសិក្សា

# ការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ

ស្រាវជ្រាវចាប់ពីថ្ងៃទី៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **កញ្ញា ឡាយ សុភា**

**កញ្ញា សុភី សុខលី**

ណែនាំដោយ

លោកគ្រូ **ម៉ៅ បុណ្ណា**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២៤

ឆ្នាំចូលរៀន ២០២០

ឆ្នាំសរសេរសារណា ២០២៤

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques

Royal university of Law and Economics


# សារណាបញ្ចប់ការសិក្សា

# ការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ

ស្រាវជ្រាវចាប់ពីថ្ងៃទី៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **កញ្ញា ឡាយ សុភា**

**កញ្ញា សុភី សុខលី**

ណែនាំដោយ

លោកគ្រូ **ម៉ៅ មុន្នីរ៉ា**



ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២៤

ឆ្នាំចូលរៀន ២០២០

ឆ្នាំសរសេរសារណា ២០២៤

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំទាំងពីរនាក់ឈ្មោះ **ឡាយ សុភា** និង **សុភី សុខលី** ជានិស្សិតបរិញ្ញាបត្រផ្នែកនីតិសាស្ត្រ ជំនាន់ទី២៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា២០២០-២០២៤។

ជាបឋមយើងខ្ញុំទាំងពីរសូមលំឱនកាយវាចាចិត្តដើម្បីសម្តែងការគោរព ការដឹងគុណ និងកតញ្ញូតាធម៌យ៉ាងជ្រាវជ្រៅបំផុតជូនចំពោះអ្នកមានគុណទាំងទ្វេគឺ **លោកឪពុក និងអ្នកម្តាយ** ដែលបានផ្តល់កំណើតដល់រូបកូន និងចិញ្ចឹមបីបាច់ថែរក្សា ព្យាយាមពុះពារគ្រប់ឧបសគ្គក្នុងការមើលថែកូនតាំងពីតូច រហូតដល់ធំធាត់ពេញវ័យ ព្រមទាំងបានផ្តល់នូវក្តីស្រឡាញ់ ភាពកក់ក្តៅ កម្លាំងចិត្ត រួមជាមួយដំបូន្មានល្អៗ ដើម្បីឱ្យកូនបានដើរតាមគន្លងធម៌។ មិនតែប៉ុណ្ណោះ លោកទាំងពីរបានផ្តល់នូវការផ្គត់ផ្គង់ថវិការ និង សិក្ខាបករណ៍ចាប់តាំងពីកម្រិតបឋមសិក្សា មធ្យមសិក្សា រហូតដល់ថ្នាក់បរិញ្ញាបត្រ។ គុណូបការៈរបស់លោកទាំងពីរមានទំហំធំធេងមិនអាចមានអ្វីប្រៀបស្មើ និងធ្វើឱ្យកូនចងចាំជានិច្ចរហូតតរៀងទៅ។

សូមថ្លែងអំណរគុណយ៉ាងជ្រាវជ្រៅចំពោះ **ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិតសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រមទាំងលោក លោកស្រីសាស្ត្រាចារ្យ និងថ្នាក់ដឹកនាំគ្រប់ជាន់ថ្នាក់** ទាំងអស់ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានខិតខំព្យាយាមយ៉ាងមុះមុតក្នុងការបង្ហាត់បង្រៀនផ្ទេរចំណេះដឹង អប់រំទូន្មាន ព្រមទាំងបានស្វះស្វែងរកឯកសារជំនួយដល់ការសិក្សារបស់យើងខ្ញុំទាំងពីរនាក់ឱ្យទទួលបាននូវចំណេះដឹងកាន់តែបានច្បាស់លាស់ ដើម្បីយកមកប្រើប្រាស់ជាប្រយោជន៍ក្នុងសង្គមជាតិ និងផ្តល់ជាផ្នែកមួយក្នុងការជួយអភិវឌ្ឍន៍សង្គមជាតិ។ ជាពិសេសសូមសម្តែងការដឹងគុណ ជូនចំពោះលោកសាស្ត្រាចារ្យ **ម៉ៅ មុន្នីណា** ក្នុងការជួយសម្របសម្រួលជួយជ្រោមជ្រែងដល់យើងខ្ញុំទាំងពីរ អស់ពីកម្លាំងកាយចិត្ត ប្រាជ្ញាស្មារតី និងពេលវេលាដ៏មានតម្លៃ ព្រមទាំងបានត្រួតពិនិត្យទាំងបញ្ហាអក្ខរាវិរុទ្ធ ទាំងកំហុសអត្ថន័យ និងបានកែលម្អជាច្រើនលើកច្រើនសារដល់យើងខ្ញុំទាំងពីរ ក្នុងការសិក្សាស្រាវជ្រាវ ចងក្រង សរសេរអត្ថបទសារណានេះឡើងរហូតដល់ចប់ជាស្ថាពរ និងប្រកបដោយលទ្ធផលវិជ្ជមាន។

ជាចុងបញ្ចប់នេះយើងខ្ញុំទាំងពីរ សូមគោរពបួងសួងដល់វត្ថុស័ក្តសិទ្ធិ សូមជួយបីបាច់ថែរក្សាមាតាបិតា ថ្នាក់ដឹកនាំសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចទាំងអស់ និងលោកគ្រូដឹកនាំសារណារបស់យើងខ្ញុំទាំងពីរ សូមឱ្យជួបប្រទះតែពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ក្នុងនាមយើងខ្ញុំទាំងពីរ ជានិស្សិតថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រឆ្នាំទី៤ ជំនាន់ទី២៤ ដែលបានសិក្សានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ចាប់តាំងពីឆ្នាំ២០២០ រហូតដល់ឆ្នាំ២០២៤។ ដោយបានឆ្លងកាត់នូវការបណ្តុះបណ្តាលនៅទីនេះកន្លងមក ដើម្បីក្រេបយកនូវចំណេះដឹង ដ៏មានតម្លៃនានាយ៉ាងច្រើនសម្បូរបែបនៃវិជ្ជាជីវៈច្បាប់ ដែលសាកលវិទ្យាល័យបានផ្តល់ឱ្យ ក្រោមការបង្ហាត់បង្ហាញយ៉ាងយកចិត្តទុកដាក់ពីសំណាក់លោកគ្រូ អ្នកគ្រូ ព្រមទាំងលោក លោកស្រីសាស្ត្រាចារ្យគ្រប់រូបនៅទីនេះ។ ដោយសារការជ្រោមជ្រែង និងការយកចិត្តទុកដាក់ពីដ៏ខ្ពង់ខ្ពស់ពីលោកគ្រូ អ្នកគ្រូ បានឈានមកដល់ការចងក្រងសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រដើម្បីរួមចំណែកក្នុងការចែករំលែកចំណេះដឹងមួយចំនួនដល់និស្សិតជំនាន់ក្រោយផងដែរ។ ក្នុងការសរសេរសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រនេះ យើងខ្ញុំទាំងពីរបានសម្រេចចិត្តជ្រើសរើសប្រធានបទមួយដែលទាក់ទងនឹង "**ការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ**" ។ នៅក្នុងការចងក្រងរៀបរៀងសារណាមួយនេះ យើងខ្ញុំពឹងផ្អែកទៅលើឯកសារសំខាន់មួយចំនួនដែលមានដូចជាក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៧ លិខិតគតិយុត្តមួយចំនួន ព្រមទាំងឯកសារមួយចំនួនទៀតដែលពាក់ពន្ធនៅក្នុងនីតិវិធីអនុវត្តនេះ។

តាមរយៈការសិក្សាស្រាវជ្រាវនេះ យើងខ្ញុំទាំងពីរនាក់សង្ឃឹមថា អត្ថបទសារណាមួយនេះអាចផ្តល់ជាឯកសារជំនួយស្មារតី ឯកសារសម្រាប់ស្រាវជ្រាវ និងផ្តល់ប្រយោជន៍ដល់អ្នកអានគ្រប់រូប ជាពិសេសនិស្សិតដែលកំពុងសិក្សាថ្នាក់បរិញ្ញាបត្រដែលមានគោលបំណងក្នុងការយល់ដឹងឱ្យកាន់តែស៊ីជម្រៅលើប្រធានបទមួយនេះផងដែរ។

ជាចុងក្រោយ យើងខ្ញុំក៏សូមអភ័យទោសជាមុន រាល់កំហុសខុសឆ្គង នឹងចំណុចខ្វះខាតទាំងឡាយនៅក្នុងអត្ថបទសារណាមួយនេះ ដូច្នេះហើយយើងខ្ញុំទាំងពីរ និងទទួលយកនូវការកែតម្រូវរបស់លោកអ្នកអានតាមរយៈការផ្តល់ជាមតិយោបល់រិះគន់ទាំងឡាយ នៅក្នុងន័យស្ថាបនាពីសំណាក់មិត្តៗនិស្សិតលោក លោកស្រីទាំងអស់ ដើម្បីអភិវឌ្ឍស្នាដៃមួយនេះឱ្យកាន់តែមានភាពល្អប្រសើរឡើង។

**មាតិកា** **ទំព័រ**

**សេចក្តីផ្តើម**...1

## ជំពូកទី១

## ទស្សនៈគតិយុត្ត ទាក់ទងនឹងការអនុវត្តដោយបង្ខំ

**១.១. សញ្ញាណទូទៅនៃការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ**

១.១.១.និយមន័យនៃការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ...៤

១.១.២.គោលការណ៍គ្រឹះនៃការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ...៤

១.១.៣.គោលបំណងនៃការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ...៥

១.១.៤.ស្ថាប័នអនុវត្ត...៥

ក.ដែនសមត្ថកិច្ចរបស់តុលាការអនុវត្ត...៦

ខ.ដែនសមត្ថកិច្ចរបស់អាជ្ញាសាលា...៧

១.១.៥. ភាគីនៃការអនុវត្ត...៨

១.១.៦. បណ្តឹងផ្សេងៗក្នុងនីតិវិធីអនុវត្តដោយបង្ខំ...៨

១.១.៧. ការផ្អាក និងការលុបចោលការអនុវត្តដោយបង្ខំ...១១

**១.២.ប្រភេទនៃការអនុវត្តដោយបង្ខំ**...១៣

១.២.១.ការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ...១៣

១.២.២.ការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ...១៤

១.២.៣.ការអនុវត្តដោយបង្ខំចំពោះនាវា...១៥

១.២.៤.ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល...១៦

**១.៣.ប្រភពច្បាប់មានការទាក់ទង ការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ**...១៦

## ជំពូកទី២

## លំហូរនីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ

**២.១ លក្ខខណ្ឌនៃការអនុវត្តដោយបង្ខំ**...១៨

២.១.១. លិខិតអនុវត្ត...១៨

២.១.២. លិខិតបញ្ជាក់អំពីការបញ្ជូនលិខិតអនុវត្ត ........................................................... ១៩
២.១.៣. រូបមន្តអនុវត្ត ........................................................... ១៩
២.១.៤. ពាក្យសុំអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ ........................................................... ២២
**២.២. ការបង់សោហ៊ុយសម្រាប់ការអនុវត្ត** ........................................................... ២៣
២.២.១. ពន្ធដាក់ពាក្យសុំ ........................................................... ២៣
២.២.២. សោហ៊ុយក្រៅពីពន្ធដាក់ពាក្យសុំ ........................................................... ២៤
**២.៣. ការពិនិត្យពាក្យសុំ** ........................................................... ២៤
**២.៤. ការចាប់ផ្ដើមនីតិវិធីលក់ដោយបង្ខំ** ........................................................... ២៥
**២.៤.១. ដីកាសម្រេចចាប់ផ្ដើមលក់ដោយបង្ខំ** ........................................................... ២៥
**២.៤.២. ការរឹបអូស** ........................................................... ២៥
២.៤.២.១. អានុភាពនៃការរឹបអូស ........................................................... ២៧
២.៤.២.២. ការហាមឃាត់មិនឱ្យធ្វើការចាត់ចែក ........................................................... ២៧
**២.៥.ដីកាសម្រេចអំពីការកំណត់ពេលចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែក**.២៧
២.៥.១. ការប្រកាសជាសាធារណៈអំពីការកំណត់ពេលចុងក្រោយសម្រាប់ការទាមទារ........................ ២៨
២.៥.២. ការដាស់តឿន ........................................................... ២៨
២.៥.៣. ពាក្យសុំទាមទារឱ្យចែកចំណែក ........................................................... ២៩
២.៥.៤. ការជូនដំណឹងអំពីការទាមទារឱ្យចែកចំណែក ........................................................... ៣០
**២.៦. ដីកាសម្រេចជ្រើសតាំងអ្នកវាយតម្លៃ និងបង្គាប់ឱ្យវាយតម្លៃ** ........................................................... ៣០
**២.៧.ដីកាបង្គាប់ឱ្យស្រាវជ្រាវអំពីស្ថានភាពបច្ចុប្បន្ននៃអចលនវត្ថុ** ........................................................... ៣១
**២.៨. ការលក់ដោយបង្ខំចំពោះអចលនវត្ថុ** ........................................................... ៣២
២.៨.១. លក្ខខណ្ឌនៃការលក់ដោយបង្ខំចំពោះអចលនវត្ថុ ........................................................... ៣២
២.៨.១.១. លក្ខខណ្ឌនៃការលក់ដែលច្បាប់កំណត់ ........................................................... ៣២
២.៨.១.២. លក្ខខណ្ឌពិសេសនៃការលក់ ........................................................... ៣៣
២.៨.២. ដីកាសម្រេចកំណត់តម្លៃអប្បបរមា ........................................................... ៣៣

២.៨.៣. ការរៀបចំឯកសារលំអិតអំពីអចលនវត្ថុ..........................................................................៣៤
២.៨.៤.ដីកាបង្គាប់ឱ្យអនុវត្តការលក់ ..............................................................................................៣៤
២.៨.៥. ការផ្សាយជាសាធារណៈអំពីកាលបរិច្ឆេទនៃការលក់........................................................៣៥
២.៨.៦. ពាក្យសុំផ្តល់សំណើរទិញ ......................................................................................................៣៥
២.៨.៧. កិច្ចនីតិវិធីលក់របស់អាជ្ញាសាលា...........................................................................................៣៥
**២.៩. ការអនុញ្ញាតឱ្យលក់** ........................................................................................................ ៣៧
២.៩.១. ការបរិច្ឆេទដើម្បីចេញដីការដីកាសម្រេចការលក់................................................................ ៣៧
២.៩.២. សេចក្តីថ្លៃការណ៍អំពីការលក់ ............................................................................................. ៣៧
២.៩.៣. ដីកាសម្រេចអនុញ្ញាតឱ្យលក់ ឬ ដីកាសម្រេចមិនអនុញ្ញាតឱ្យលក...................................៣៨
**២.១០. អានុភាពនៃការលក់ដោយបង្ខំ** .......................................................................................៣៨
២.១០.១ ការបង្កើតទំនាក់ទំនងការលក់ទិញ ......................................................................................៣៨
២.១០.២. អានុភាពចំពោះផល និងប្រយោជន៍អចលនវត្ថុ ...............................................................៣៩
២.១០.៣. ការទទួលខុសត្រូវក្នុងការធានានៅក្នុងការលក់ដោយបង្ខំ................................................. ៤០
២.១០.៤. ការទទួលបន្ទុកហានិភ័យនៅក្នុងការអនុវត្តដោយបង្ខំ...................................................... ៤០
២.១០.៥.ការផ្ទុកផ្តាក់ឱ្យចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិ និង លុបចោលការចុះបញ្ជីរឹបអូស........................ ៤០
២.១០.៦.ការប្រគល់អចលនវត្ថុ ........................................................................................................ ៤១
**២.១១. ការចែកចំណែក**................................................................................................................ ៤១
២.១១.១. ការរៀបចំការចែកចំណែក.....................................................................................................៤២
២.១១.២.វិធីចែកចំណែក ....................................................................................................................៤៣
**សេចក្តីសន្និដ្ឋាន**.......................................................................................................................៤៦
**អនុសាសន៍**.............................................................................................................................៤៧
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

បុគ្គលម្នាក់ៗនៅក្នុងសង្គមត្រូវបានផ្តល់ឱ្យ និងទទួលបាននូវសិទ្ធិសេរីភាពយ៉ាងទូលំទូលាយនៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃ និងនៅក្នុងទំនាក់ទំនងអាជីវកម្មដែលនៅក្នុងនេះផងដែរ ទំនាក់ទំនងមួយដែលតែងតែកើតមានឡើងនោះ គឺការកម្ចីប្រាក់ឬទ្រព្យសម្បត្តិគ្នាទៅវិញទៅមក។ នៅក្នុងប្រតិបត្តិការកម្ចីរវាងកូនបំណុល និងម្ចាស់បំណុល ដើម្បីបង្កើតការទុកចិត្ត និងការពារផលប្រយោជន៍របស់ម្ចាស់បំណុល និងកូនបំណុលគូភាគីទាំងសងខាង គឺគប្បីបង្កើតនូវរបបគតិយុត្តិមួយឡើង ដែលអាចអនុញ្ញាតឱ្យកូនបំណុលប្រើប្រាស់សិទ្ធិលើអចលនវត្ថុរបស់ខ្លួន ទៅធានាការអនុវត្តកាតព្វកិច្ចរបស់ខ្លួនជាមួយម្ចាស់បំណុល។ ហើយនៅក្នុងទំនាក់ទំនងនោះអាចកើតមានបញ្ហាទាក់ទងនឹងការអនុវត្តកាតព្វកិច្ចរវាងកូនបំណុល និងម្ចាស់បំណុល។ នៅក្នុងវិវាទរដ្ឋប្បវេណីនេះ ភាគីទាំងសងខាងមានសិទ្ធិបុគ្គលរៀងៗខ្លួនក្នុងការតវ៉ា និងការពារខ្លួន។ ដោយក្នុងករណីនេះ ម្ចាស់បំណុលគប្បីអនុវត្ត ការអនុវត្តដោយបង្ខំទៅលើអចលនវត្ថុរបស់កូនបំណុល ដើម្បីទទួលបានប្រាក់ត្រឡប់មកវិញ ហើយនៅក្នុងនីតិវិធីនេះអ្នកមានសមត្ថកិច្ចដោះស្រាយជាតុលាការអនុវត្ត។

## ២.ចំណោទបញ្ហា

ការមិនស្ម័គ្រចិត្តក្នុងការអនុវត្តកាតព្វកិច្ច ទៅម្ចាស់បំណុលជាហេតុមួយដែលធ្វើអោយម្ចាស់បំណុលមានការព្រួយបារម្មណ៍ និងខាតប្រយោជន៍ហើយជាបញ្ហាប្រឈមដែលម្ចាស់បំណុលបានជួបប្រទះញឹកញាប់។ ករណីមួយចំនួនកូនបំណុលមានទ្រព្យសម្បត្តិគ្រប់គ្រាន់ ប៉ុន្តែមិនស្ម័គ្រចិត្តសងហើយ អាចផ្ទេរទៅអ្នកផ្សេងដើម្បីជៀសវាងអំពីការរឹបអូសពីម្ចាស់បំណុល។ ដូច្នេះម្ចាស់បំណុលគប្បីជ្រើសការអនុវត្តដោយបង្ខំធ្វើជាមធ្យោបាយមួយ ក្នុងការការពារផលប្រយោជន៍របស់ខ្លួនស្របតាមច្បាប់ ដោយត្រូវអនុវត្តទៅតាមនីតិវិធីដែលមានបញ្ញត្តិនៅគន្ថីទី៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

នៅពេលដែលម្ចាស់បំណុលជ្រើសរើសយកមធ្យោបាយ ការអនុវត្តដោយបង្ខំ តើនិតិវិធីនៃការអនុវត្តដោយបង្ខំនេះមានដំណើរការនីតិវិធីដូចម្តេចខ្លះ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះធ្វើឡើង មានគោលបំណងក្នុងការសិក្សាទៅលើនៃទ្រឹស្តីគតិ្តយុត្ត និងការយកនីតិវិធីដែលអ្នកអនុវត្តជាក់ស្តែងបានអនុវត្តនឹងប្រធានបទខាងលើ ដើម្បីអាចវិភាគទំនាក់ទំនងនៃទ្រឹស្តីនិងអនុវត្តជាក់ស្តែងមានភាពខុសគ្នាយ៉ាងដូចម្តេចខ្លះ។

## ៤ ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ប្រធានបទសារណានេះបានធ្វើការសិក្សា និងស្រាវជ្រាចំពោះតែ ការអនុវត្តដោយបង្ខំចំពោះអចលវត្ថុ ចំពោះសិទ្ធទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់ប៉ុណ្ណោះ។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

ប្រធានបទសារណានេះ បានជាប្រយោជន៍សម្រាប់ជាជំនួយក្នុងការសិក្សាស្រាវជ្រាវបាន មួយផ្នែកជូនដល់អ្នកដែលមានគោលបំណងក្នុងការស្វែងយល់អំពីមូលដ្ឋាននៃការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ និងអំពីនីតិវិធីនៃការចាប់ផ្ដើមឱ្យមានការអនុវត្តដោយបង្ខំ ថាវាកើតឡើងដោយរបៀបណា? តើមានលក្ខខណ្ឌអ្វីខ្លះ? ដែលភាគីអាចចាប់ផ្ដើមអនុវត្តនីតិវិធីនេះបាន។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

ស្នារដៃសិក្សាស្រាវជ្រាវមួយនេះគឺ ត្រូវបានធ្វើឡើងយោងតាមក្រមនីតិវិធីរដ្ឋប្បវេណីបទដ្ឋានគតិយុត្តសៀវភៅពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណីព្រមទាំងលិខិតមួយចំនួនដែលមាននិងចាំបាច់មួយចំនួន ដែលមាននៅក្នុងនីតិវិធីនៃការអនុវត្តដោយបង្ខំ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការស្រាវជ្រាវអំពី ការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុនេះ ធ្វើឡើងដើម្បីស្វែងយល់ឱ្យកាន់តែច្បាស់នូវចំណុចនីមួយៗ និងវិធីសាស្ត្រដែលមានសារៈសំខាន់លើរចនាសម្ព័ន្ធនៃការស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវនេះត្រូវបានបែងចែកជាផ្នែកដូចខាងក្រោម៖

- **សេចក្ដីផ្ដើម** បង្ហាញយ៉ាងលំអិតអំពី លំនាំបញ្ហានៃការស្រាវជ្រាវ ចំណោទបញ្ហានៃការស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ និងវិធីសាស្ត្រនៃការស្រាវជ្រាវ ។
- **ជំពូកទី១ ទស្សនៈគតិយុត្តទាក់ទងនឹងការអនុវត្តដោយបង្ខំ** ដោយជំពូកនេះបានបង្ហាញទាក់ទងទៅនឹងសញ្ញាណទូទៅរបស់ប្រធានបទនេះរួមមាន និយមន័យ ប្រភេទនៃការអនុវត្តដោយបង្ខំ គោលការណ៍នៃការអនុវត្ត បង្ហាញថាតើស្ថាប័នណាជាអ្នកអនុវត្ត និងបណ្ដឹងនានាទាក់ទងនឹងការអនុវត្តនេះ ព្រមទាំងប្រភពច្បាប់ផងដែរ។
- **ជំពូកទី២ លំហូរនីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ** ជំពូកនេះ យើងខ្ញុំ នឹងធ្វើការបកស្រាយអំពីដំណាក់កាលនៃការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុទាំងអស់ចាប់ពី ការដាក់ពាក្យសុំរូប

មន្តអនុវត្ត ការដាក់ពាក្យសុំអនុវត្តដោយបង្ខំ នីតិវិធីចាប់ផ្តើមលក់ ការរឹបអូស ការលក់ដោយបង្ខំ រហូតដល់ការចែកចំណែក។

- **សេចក្តីសន្និដ្ឋាន** បានធ្វើការសង្ខេបលម្អិតទៅលើការបកស្រាយចំណុចសំខាន់ៗទាំងអស់ដែលមាននៅក្នុងកិច្ចការស្រាវជ្រាវនោះ។
- **អនុសាសន៍** ទៅលើចំណុចដែលមានភាពខ្វះខាតដើម្បីការកែលម្អ។

# ជំពូកទី១

# ទស្សនៈគតិយុត្តទាក់ទងនឹងការ
# អនុវត្តដោយបង្ខំ

# ជំពូកទី១

# ទស្សនៈគតិយុត្ត ទាក់ទងនឹងការអនុវត្តដោយបង្ខំ

## ១.១. សញ្ញាណទូទៅនៃការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ

### ១.១.១. និយមន័យនៃការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ

ការអនុវត្តដោយបង្ខំគឺ ជានីតិវិធីមួយរបស់តុលាការក្នុងការសម្រេចនូវសិទ្ធិទាមទារ ឬសិទ្ធិប្រាតិភោគ ដែលបានកំណត់នៅក្នុងនីតិឯកជនដោយប្រើអំណាចរដ្ឋ។[១] ដោយការអនុវត្តនីតិវិធីនេះ គឺអនុវត្តឡើងដោយស្ថាប័នអនុវត្ត ដែលមានចែងនៅក្នុងបញ្ញត្តិច្បាប់យ៉ាងច្បាស់លាស់ ហើយការអនុវត្តការរឹបអូសនេះមានច្រើនប្រភេទទៅតាមកម្មវត្ថុ នៃការទាមទាររបស់ម្ចាស់បំណុល។

នៅក្នុងចំណោមការអនុវត្តដែលកម្ពុជាបានជួបប្រទះច្រើនជាងគេនោះ គឺការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ។ ការអនុវត្តដោយង្ខំចំពោះអចលនវត្ថុ គឺជាការលក់អចលវត្ថុដែលមានគោលបំណងយកសិទ្ធិលើបំណុលរបស់ខ្លួនមកវិញពីថ្លៃលក់នោះ។ ការអនុវត្តដោយបង្ខំមិនមែនជានីតិវិធីបន្ទាប់ ឬបន្តពីនីតិវិធីបណ្តឹងទេ តែគឺជានីតិវិធិឯករាជ្យមួយ ដែលលចាប់ផ្តើមដោយការដាក់ពាក្យសុំរបស់ម្ចាស់បំណុលដែលត្រូវការឱ្យមានការសម្រេចនូវសិទ្ធិទាមទាររបស់ខ្លួន។[២]

### ១.១.២.គោលការណ៍គ្រឹះនៃការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ

ប្រការដែលនាំឱ្យមានការចាប់ផ្តើមនៃនីតិវិធីនៃការអនុវត្តដោយបង្ខំនោះ លុះត្រាតែគូភាគីនៃកិច្ចសន្យាមិនបានអនុវត្តទៅតាមខចែង និង លក្ខខណ្ឌនៅក្នុងកិច្ចសន្យាដែលនេះបង្កើតឱ្យមាននូវការរំលោភបំពានសិទ្ធិ និងផលប្រយោជន៍របស់ភាគីម្ខាងទៀតនៃកិច្ចសន្យា ហេតុដូច្នេះទើបឈានដល់ការអនុវត្តដោយបង្ខំ។ នៅក្នុងក្រមនីវិធីរដ្ឋប្បវេណី ម្ចាស់បំណុលមានតួនាទីក្នុងការស្រាវជ្រាវ និងពិនិត្យមើលនូវទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំដោយផ្ទាល់ ពោលគឺមិនមែនជាកាតព្វកិច្ចរបស់តុលាការនោះទេ។ ការស្រាវជ្រាវនេះម្ចាស់បំណុលនៃការអនុវត្ត ត្រូវពិនិត្យព័ត៌មានដូចជា ថាតើអចលនវត្ថុនោះត្រូវបានចុះបញ្ជីហើយឬនៅ? តើ

---

[១] ក្រុមការងារជប៉ុនដែលទទួកបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, *សេចក្តីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណី, ភាគ២, ការអនុវត្តដោយបង្ខំ និងការចាត់ចែងរក្សាការពារ (ភ្នំពេញៈក្រសួងយុត្តិធម៌)១។*

[២] ក្រុមការងារជប៉ុនដែលទទួកបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, *សេចក្តីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណី, ភាគ២, ការអនុវត្តដោយបង្ខំ និងការចាត់ចែងរក្សាការពារ (ភ្នំពេញៈក្រសួងយុត្តិធម៌)២។*

កូនបំណុលពិតជាកម្មសិទ្ធិករនៃទ្រព្យនោះពិតឬយ៉ាងណា។ ដោយម្ចាស់បំណុលត្រូវកំណត់ឱ្យបានច្បាស់លាស់អំពីទ្រព្យសម្បត្តិរបស់កូនបំណុលនៃការអនុវត្ត មុននឹងឈានដល់ការដាក់ពាក្យសុំអនុវត្តដោយបង្ខំមកតុលាការដែលមានសមត្ថកិច្ច។

### ១.១.៣.គោលបំណងនៃការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ

ការអនុវត្តដោយបង្ខំមានគោលបំណង ក្នុងការសម្រេចឱ្យបាននូវកាតព្វកិច្ចដែលជាកម្មវត្ថុនៃសិទ្ធិទាមទារ ឬសិទ្ធិប្រាតិភោគតាមរយៈការប្រើប្រាស់អំណាចរបស់រដ្ឋ ដើម្បីការពារផលប្រយោជន៍របស់ម្ចាស់សិទ្ធិនៅក្នុងនីតិវិធីរដ្ឋប្បវេណី។ ក្នុងករណីដែលបុគ្គលជាប់កាតព្វកិច្ចផ្តល់តាវកាលិក ឬកូនបំណុលមិនព្រមអនុវត្តកាតព្វកិច្ចរបស់ខ្លួនដោយស្ម័គ្រចិត្តដោយមានគោលបំណងការពារសិទ្ធិរបស់បុគ្គលឯកជនចាំបាច់ត្រូវមានការរៀបចំនូវនីតិវិធីសម្រាប់អនុវត្តដោយបង្ខំ និងដើម្បីផ្តល់ឱ្យទៅម្ចាស់បំណុលនូវភាពស្ងប់ចិត្តដោយអំណាចរដ្ឋដូចគ្នា និងករណីដែលកូនបំណុលបានអនុវត្តកាតព្វកិច្ចរបស់ខ្លួនដែរ។[៣] ការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ ជានីតិវិធីដែលមានលក្ខណៈស្មុគស្មាញជាងគេ។ ដោយការអនុវត្តដោយបង្ខំអាចកើតឡើងបាន លុះត្រាតែមានលិខិតអនុវត្តលិខិតបញ្ជាក់អំពីការបញ្ជូន រូបមន្តអនុវត្ត ពាក្យសុំអនុវត្តដោយបង្ខំ។ ប្រសិនបើនីតិវិធីណាមួយមិនមានគោលបំណងធ្វើឱ្យសម្រេចនូវសិទ្ធិទាមទារទេ ទោះបីជាខ្លឹមសារនៃសាលក្រម ឬសាលដីកាត្រូវបានសម្រេចដោយនីតិវិធីនោះក៏ដោយ ក៏នីតិវិធីនោះពុំមែនជានីតិវិធីនៃការអនុវត្តដោយបង្ខំដែរ។

### ១.១.៤.ស្ថាប័នអនុវត្ត

ស្ថាប័នជាតិ គឺជាស្ថាប័នដែលមានសមត្ថភាពនិង អំណាចក្នុងការធ្វើការអនុវត្ត។[៤] ដោយសារនីតិវិធីនៃការអនុវត្តដោយបង្ខំ គឺជានីតិវិធីដាច់ដោយឡែក និងឯករាជ្យពីនីតិវិធីបណ្តឹងដូច្នេះវាមិនចាំបាច់ដែលតុលាការទទួលពាក្យបណ្តឹងត្រូវតែជាស្ថាប័នអនុវត្តនោះទេដោយគិតអំពីតម្រូវការនៃភាពងាយស្រួល និងភាពឆាប់រហ័សការដាក់ការទទួលបន្ទុកទៅឱ្យស្ថាប័នអនុវត្តមួយផ្សេងទៀតគឺជាការសមស្រប ហេតុដូច្នេះបានជាច្បាប់ចែងឱ្យ

---

[៣] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, *សេចក្តីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណី, ភាគ២, ការអនុវត្តដោយបង្ខំ និងការចាត់ចែងរក្សាការពារ (ភ្នំពេញ៖ក្រសួងយុត្តិធម៌)២៦។*

[៤] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, *សេចក្តីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណី, ភាគ២, ការអនុវត្តដោយបង្ខំ និងការចាត់ចែងរក្សាការពារ (ភ្នំពេញ៖ក្រសួងយុត្តិធម៌)១៣។*

តុលការអនុវត្ត និងអាជ្ញាសាលាធ្វើជាស្ថាប័នអនុវត្ត។[៥] ជារួមស្ថាប័ននៅក្នុងនិតិវិធីនេះមាន ២ប្រភេទរួមមាន តុលាការអនុវត្តនិងអាជ្ញាសាលា ។

ការអនុវត្តដោយបង្ខំ ត្រូវធ្វើឡើងដោយស្ថាប័នអនុវត្តតាមពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្ត។[៦] ស្ថាប័នទាំងពីរនេះ ជាស្ថាប័នឯករាជ្យនៃអំណាចតុលាការដោយមានលក្ខណៈពីរផ្សេងគ្នា ហេតុនេះហើយបានជាច្បាប់ដាក់បន្ទុកការងារផ្សេងគ្នាទៅឱ្យស្ថាប័ននីមួយៗ ដោយអាស្រ័យទៅតាមកម្មវត្ថុនៃការអនុវត្តដោយបង្ខំ និងទៅតាមប្រភេទបែបបទនៃការអនុវត្តជាអាទិ៍។[៧] ម្យ៉ាងវិញទៀតការបំបែកស្ថាប័នវិនិច្ឆ័យនិងស្ថាប័នអនុវត្តដាច់ពីគ្នានោះដោយសារការធ្វើវិនិច្ឆ័យអំពីអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិនិងទំហំហើយត្រូវតែមានការពិនិត្យឱ្យបានហ្មត់ចត់ នៅក្នុងនីតិវិធីនេះ ដោយបន្ទាប់ពីមាន ការសម្រេចនូវសិទ្ធិមានអត្ថិភាពរួចរាល់ហើយនោះនឹងតម្រូវឱ្យមានការអនុវត្តដើម្បីដំណើរការនីតិវិធី។ ជារួមមកតុលាការអនុវត្តផ្តោតសំខាន់ទៅលើការវិនិច្ឆ័យច្បាប់ដោយឡែកចំពោះអាជ្ញាសាលាផ្តោតទៅលើការធ្វើសកម្មភាពជាក់ស្តែងនៅទីតាំង។

**ក.ដែនសមត្ថកិច្ចរបស់តុលាការអនុវត្ត**

តាមន័យចង្អៀតតុលាការអនុវត្ត គឺជាតុលាការដែលមានភារកិច្ចធ្វើការអនុវត្តដោយបង្ខំ ឬធ្វើការពាក់ព័ន្ធនៅក្នុងនីតិវិធីអនុវត្តដោយបង្ខំ។ លើសពីនេះទៅទៀត នៅក្នុងក្រមនីតិវិធិរដ្ឋប្បវេណីបានចែងអំពីតុលាការអនុវត្តថាសាលាដំបូងដែលត្រូវអនុវត្តដោយបង្ខំ គឺជាតុលាការអនុវត្តតាមបញ្ញត្តិនៃគន្លឹទី៦។[៨]

ការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ តុលាការខាងក្រោមនេះជាតុលាការដែលមានសមត្ថកិច្ចៈ[៩]

- ករណីកម្មវត្ថុជាដី ឬអគារដែលបានចុះបញ្ជីនោះជាសមត្ថិកិច្ចរបស់សាលាដំបូងដែលនៅទីកន្លែងកម្មវត្ថុនោះ

[៥] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, *សេចក្តីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណី, ភាគ២, ការអនុវត្តដោយបង្ខំ និងការចាត់ចែងរក្សាការពារ, (ភ្នំពេញ៖ ក្រសួងយុត្តិធម៌)១៣*។

[៦] ក្រមនីតិវិរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣៣៦ កថាខណ្ឌទី១។

[៧] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, *សេចក្តីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណី, ភាគ២, ការអនុវត្តដោយបង្ខំ និងការចាត់ចែងរក្សាការពារ, (ភ្នំពេញ៖ ក្រសួងយុត្តិធម៌)១៣*។

[៨] ក្រមនីតិវិរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣៣៦ កថាខណ្ឌទី៣។

[៩] ក្រមនីតិវិរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៤១៨។

- ករណីកម្មវត្ថុជា ចំណែកនៃកម្មសិទ្ធិអវិភាគលើដី ឬលើអគារដែលបានចុះបញ្ជី ឬសិទ្ធិជួលអចិន្ត្រៃយ៍ ផលុបភោគដែលបានចុះបញ្ជី ឬចំណែកនៃសិទ្ធិទាំងនេះដែលជាសិទ្ធិរួមនោះជាសមត្ថកិច្ចរបស់សាលាដំបូងនៅ ទីកន្លែងដែលត្រូវចុះបញ្ជី។

សរុបមកសមត្ថកិច្ចរបស់តុលាការអនុវត្តគឺ តុលាការរបស់សាលាដំបូងដែលកម្មវត្ថុនៃការអនុវត្តនោះស្ថិតនៅក្នុងនីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុតុលាការអនុវត្តនឹងចេញ ដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំនឹងរឹបអូសអចលនវត្ថុរបស់កូនបំណុលនៃការអនុវត្ត។ តុលាការអនុវត្តធ្វើការអនុវត្តដោយមិនចុះដល់ទីកន្លែងជាក់ស្តែងនោះទេនៅក្នុងករណីដែលមានភាពចាំបាច់ក្នុងការអនុវត្តដោយបង្ខំ តុលាការអនុវត្តអាចស្នើសុំជំនួយពីក្រសួង ឬស្ថាប័នដលមានសមត្ថកិច្ចបាន។[១០] ម្យ៉ាងវិញទៀតប្រសិនបើករណីដែលម្ចាស់បំណុលបានដាក់ពាក្យសុំអនុវត្ត ដោយខុសស្ថាប័ននោះ អ្នកទទួលពាក្យសុំនោះត្រូវប្រាប់ដំណឹងនេះទៅម្ចាស់បំណុល។

### ខ.ដែនសមត្ថកិច្ចរបស់អាជ្ញាសាលា

អាជ្ញាសាលា គឺជាស្ថាប័នតុលាការដាច់ដោយឡែកមួយ ដែលទទួកបន្ទុកការងារអនុវត្តដោយបង្ខំ និងការងារពាក់ព័ន្ធ ហើយដែលមានមន្ត្រីរាជការគឺ អាជ្ញាសាលាដែលអាជ្ញាសាលានេះ គឺជាស្ថាប័នអនុវត្តមួយឯករាជ្យ មិនមែនស្ថាប័នជំនួយនៃតុលាការអនុវត្តទេ។[១១] អាជ្ញាសាលាត្រូវបំពេញមុខនាទីរបស់ខ្លួននៅតំបន់សមត្ថកិច្ចរបស់សាលាដំបូងដែលខ្លួនបំពេញការងារ។ នៅក្នុងការអនុវត្តដោយបង្ខំអាជ្ញាសាលា មានតួនាទីធ្វើសកម្មភាពនៃការអនុវត្តដោយបង្ខំ។ ចំពោះសកម្មភាពក្នុងការអនុវត្តដោយបង្ខំ របស់អាជ្ញាសាលាត្រូវផ្អែកទៅលើពាក្យសុំត្រឹមត្រូវតាមច្បាប់របស់ម្ចាស់បំណុល និងដោយអនុលោមទៅតាមនីតិវីធីដែលបានកំណត់។ នៅពេលដែលអាជ្ញាសាលា ធ្វើការរឹបអូសចំពោះចលនវត្ថុរបស់កូនបំណុល អាជ្ញាសាលាអាចូលទៅក្នុងទីកន្លែងរស់នៅរបស់កូនបំណុលនៃការអនុវត្ត ឬកន្លែងផ្សេងទៀតដែលកូនបំណុល នៃការអនុវត្តការកាន់កាប់នោះ ហើយអាចធ្វើការឆែកឆេ រកអចលនវត្ថុដែលអាចរឹបអូសនោះបាន នៅក្នុងករណីនេះបើមានភាពចាំបាច់ អាជ្ញាសាលាអាចធ្វើការចាត់ចែងចាំបាច់ដើម្បីបើកទ្វាដែក បិទទូដែក និងប្រអប់ផ្សេងទៀតបាន។[១២] នៅក្នុងករណីដែលអាជ្ញាសាលាមានទំនាក់ទំនងញាតិ ឬមានផលប្រយោជន៍ទាក់ទងជាក់លាក់ផ្សេងទៀតតជាមួយភាគីនោះត្រូវ

---

[១០] ក្រមនីតិវិរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣៤២។

[១១] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, (ភ្នំពេញ៖២០០៧), មាត្រា៣១៣។

[១២] ក្រមនីតិវិរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣៨៥ កថាខណ្ឌ២។

ដកចេញពីការអនុវត្តមុខងាររបស់ខ្លួន ដើម្បីជៀសវាងភាពមន្ទិលសង្ស័យអំពីភាពត្រឹមត្រូវនៅក្នុងការបំពេញមុខនាទី។[១៣] ប្រសិនបើអាជ្ញាសាលាជួបប្រទះនឹងការប្រឆាំងនៅពេលបំពេញមុខនាទីរបស់ខ្លួនអាជ្ញាសាលានោះអាចប្រើកម្លាំង ឬអាចសុំជំនួយពីនគរបាល ឬកងកម្លាំងផ្សេងទៀត ដែលមានសមត្ថកិច្ចដើម្បីបំបាត់នូវការប្រឆាំងនោះបាន។[១៤]

### ១.១.៥. ភាគីនៃការអនុវត្ត

នៅក្នុងនីតិវិធីអនុវត្តដោយបង្ខំ ការកំណត់ឋានៈរបស់ភាគីនីមួយៗ ត្រូវតែកំណត់ឱ្យបានច្បាស់លាស់។ ឋានៈរបស់ភាគីត្រូវបានកំណត់ដោយយោងតាមលិខិតអនុវត្ត និង រូបមន្តអនុវត្ត។

នៅក្នុងនីតិវិធីនៃការអនុវត្តដោយបង្ខំ ភាគីត្រូវហៅដូចខាងក្រោម៖[១៥]

- ភាគីដែលដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំ ត្រូវហៅថាម្ចាស់បំណុលនៃការអនុវត្ត
- ភាគីម្ខាងទៀតត្រូវហៅថា កូនបំណុលនៃអនុវត្ត។

ម្ចាស់បំណុលនៃការអនុវត្ត គឺជាបុគ្គលដែលដាក់ពាក្យសុំឱ្យតុលាការអនុវត្តសាលក្រម ឬសាលដីកាដែលត្រូវបានគេស្គាល់ថាជាអ្នកឈ្នះក្តីតាមផ្លូវតុលាការ ឬតាមការអនុវត្តដោយបង្ខំតាមលិខិតអនុវត្តផ្សេងទៀត។ ចំណែកកូនបំណុលនៃការអនុវត្ត គឺជាបុគ្គលដែលចាញ់ក្តី និងមិនព្រមអនុវត្តដោយស្ម័គ្រចិត្តហើយត្រូវបានគេដាក់ពាក្យសុំ។

### ១.១.៦. បណ្តឹងផ្សេងៗក្នុងនីតិវិធីអនុវត្តដោយបង្ខំ

ស្ថាប័នអនុវត្ត ដែលមានតួនាទីក្នុងការអនុវត្តដោយបង្ខំនោះត្រូវអនុវត្តដោយ អនុលោមទៅតាមការកំណត់របស់ច្បាប់ និងបទបញ្ញត្តិដែលពាក់ព័ន្ធនានាឱ្យបានត្រឹមត្រូវសមស្របទៅតាមច្បាប់។ ប៉ុន្តែទោះបីជាយ៉ាងនេះក្តី ការអនុវត្តឱ្យបានត្រឹមត្រូវ មិនមែនសុទ្ធតែត្រូវបានធានារហូតនោះទេ ដោយនៅក្នុងករណីខ្លះអាចនឹងកើតមាន ការអនុវត្តដោយបង្ខំដែរ ផ្ទុយនឹងច្បាប់ ដូចជាករណីដែលសកម្មភាពណាមួយរបស់ស្ថាប័នអនុវត្ត បាន

[១៣] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, *សេចក្តីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណី, ភាគ២, ការអនុវត្តដោយបង្ខំ និងការចាត់ចែងរក្សាការពារ, (ភ្នំពេញ៖ ក្រសួងយុត្តិធម៌)១៧*។

[១៤] ក្រមនីតិវិរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣៣៨ កថ។

[១៥] ក្រមនីតិវិរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣៤៧ កថាខណ្ឌ២។

អនុវត្តបំពានទៅលើក្រមនីតិវិធីឬបញ្ញត្តិផ្សេងៗជាដើម។ ដូចច្នេះភាគីអាចដាក់ពាក្យបណ្ដឹងបានទៅតាមការកំណត់នៅក្នុង បញ្ញត្តិច្បាប់បានដែលមានដូចខាងក្រោម៖

❖ **បណ្ដឹងជំទាស់**

ជាគោលការណ៍ ប្រសិនបើការចេញដីកាសម្រេចបំពានទៅលើក្រមនីតិវិធីរដ្ឋប្បវេណី និង ផ្ទុយនឹងច្បាប់នោះ វិធីឧបាស្រ័យចំពោះដីកាសម្រេចនោះគឺតាមរយៈបណ្ដឹងជំទាស់។ ចំពោះការធ្វើបណ្ដឹងជំទាស់ក្នុងនីតិវិធីអនុវត្តដោយបង្ខំអាចធ្វើឡើងបានលុះត្រាមានបញ្ញត្តិជាក់លាក់ នៅក្នុងមាត្រានីមួយៗនៅក្នុងគន្ថិទី៦។

បណ្ដឹងជំទាស់ គឺជាឧបាស្រ័យចំពោះការចាត់ចែងការអនុវត្តដោយតុលាការអនុវត្ត ដែលមានលក្ខណៈជាការសម្រេចសេចក្ដី។[១៦] បណ្ដឹងជំទាស់ត្រូវធ្វើឡើងក្នុងអំឡុងពេល ១សប្ដាហ៍ ដោយគិតចាប់ពីថ្ងៃដែលបានទទួលដំណឹងអំពីដីកាសម្រេច។[១៧] សម្រាប់ភាគីដែលមានបំណងចង់ប្ដឹងជំទាស់ ត្រូវដាក់ពាក្យបណ្ដឹងទៅតុលាការដើម ក្នុងករណីនេះតុលាការដើមត្រូវផ្ញើរឱ្យបានឆាប់រហ័ស នូវពាក្យបណ្ដឹងជំទាស់ និងសំណុំរឿងទៅតុលាការនៃបណ្ដឹងជំទាស់។[១៨] ជាទូទៅតុលាការអនុវត្តត្រូវអនុវត្តនីតិវិធីនេះដោយត្រូវធ្វើឡើងក្រោមទម្រង់ជាសេចក្ដីសម្រេចពោលគឺចេញដីកាសម្រេច។ ចំពោះការសម្រេចសេចក្ដីនេះ អាចធ្វើបានដោយមិនបាច់ឆ្លងកាត់តាមការទាញ ហេតុផលផ្ទាល់មាត់។[១៩] បុគ្គលដែលមានសិទ្ធិអាចប្ដឹងជំទាស់បានរួមមាន ម្ចាស់បំណុល កូនបំណុល និងតតិយជនដែលរងការប៉ះពាល់ដោយសារដីកាសម្រេច។ គួរបញ្ជាក់ផងដែរថា ទោះបីជាតាមបញ្ញត្តិមាត្រា ៣០៥ (ការផ្អាកអនុភាពនៃដីកាសម្រេចដើម) នៃក្រមនីតិវិធីរដ្ឋប្បវេណីក៏ដោយ ប៉ុន្តែបណ្ដឹងជំទាស់នៅក្នុងនីតិវិធីនៃការ អនុវត្តដោយបង្ខំមិនផ្អាកអនុភាពនៃដីកាសម្រេចដើមទេ[២០] ព្រោះថាបើដីកាសម្រេចដើមត្រូវបានផ្អាក់ដោយសារតែពាក្យបណ្ដឹងជំទាស់នោះ នឹងធ្វើឱ្យមានការពន្យាពេលនៃការអនុវត្តនីតិវិធីនៃការអនុវត្តដោយការប្រើសិទ្ធិដោយបំពានដោយមិនសមហេតុផល។

[១៦] ក្រុមការងារជប៉ុនដែលទទួកបន្ទុកធ្វើសេចក្ដីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, *សេចក្ដីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណី, ភាគ២, ការអនុវត្តដោយបង្ខំ និងការចាត់ចែងរក្សាការពារ, (ភ្នំពេញ៖ ក្រសួងយុត្តិធម៌)*១៩។

[១៧] ក្រមនីតិរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣០៣។

[១៨] ក្រមនីតិរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣០១ កថាខណ្ឌទី១។

[១៩] ក្រមនីតិរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣០៦ កថាខណ្ឌទី១។

[២០] ក្រមនីតិរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣៤៣ កថាខណ្ឌទី១។

អំឡុងពេលរហូតដល់សេចក្ដីសម្រេចអំពីបណ្ដឹងជំទាស់មានអនុភាពតុលាការនៃបណ្ដឹងជំទាស់ អាចចេញដីកាសម្រេចដែលបានកំណត់នៅក្នុងចំណុចរួមមាន បង្គាប់ឱ្យផ្អាកអនុភាពនៃដីកាសម្រេចដើម ដោយឱ្យដាក់ប្រាតិភោគ ឬមិនឱ្យដាក់ប្រាតិភោគ និងបង្គាប់ឱ្យផ្អាកនីតិវិធីនៃការអនុវត្តដោយបង្ខំមួយផ្នែក ឬទាំងមូលដោយឱ្យដាក់ប្រាតិភោគ ឬមិនឱ្យដាក់ប្រាតភោគ។[២១]

❖ **បណ្ដឹងតវ៉ាចំពោះការទាមទារ**

នៅក្នុងលិខិតអនុវត្តបានបញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិទាមទារ និងអាចធ្វើការអនុវត្តដោយបង្ខំក៏ដោយក៏កូនបំណុលអាចធ្វើការទាមទារ និងធ្វើបណ្ដឹងតវ៉ាចំពោះការទាមទារបានផងដែរ។ បណ្ដឹងតវ៉ាចំពោះការទាមទារគឺបណ្ដឹងដែលតវ៉ាចំពោះអត្ថិភាព ឬអត្ថន័យនៃសិទ្ធិទាមទារដែលត្រូវបានកំណត់នៅក្នុងលិខិតអនុវត្ត។[២២]

ឧទាហរណ៍៖ សាលក្រមបង្គាប់ឱ្យ ក សងប្រាក់ចំនួន USD ២,០០០ (ពីរពាន់ដុល្លារអាមេរិក) ទៅឱ្យ ខ ។ នៅពេល ខ ដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំ ក បានអះអាងថាខ្លួនបានសងប្រាក់ឱ្យ ខ រួចហើយ។ ដូចច្នេះ ក ត្រូវដាក់ពាក្យបណ្ដឹងតវ៉ាចំពោះការទាមទារនេះមានន័យថា សិទ្ធិទាមទាររបស់ ខ លែងមានទៀតហើយ។

គោលបំណងនៃបណ្ដឹងតវ៉ាចំពោះការទាមទារ គឺដើម្បីឱ្យមានការវិនិច្ឆ័យតាមនីតិវិធីបណ្ដឹងអំពីអត្ថិភាព និត្ថិភា និង អត្ថន័យនៃសិទ្ធិទាមទារ ឬសិទ្ធិប្រាតិភោគដែលបានកំណត់នៅក្រោមច្បាប់សារធាតុដែលលិខិតអនុវត្តបានបញ្ជាក់ថាអត្ថិភាព។[២៣] ហើយការតវ៉ាចំពោះការទាមទារអាចធ្វើឡើងនៅពេលដែលលិខិតអនុវត្តមានអនុភាពអនុវត្តដោយបង្ខំ។ នៅពេលដែលលិខិតអនុវត្តនោះបានអនុវត្តចប់រួចរាល់ហើយនោះដូចច្នេះបណ្ដឹងតវ៉ាចំពោះការទាមទារពុំអាចធ្វើបានទេ។

❖ **បណ្ដឹងតវ៉ាចំពោះការផ្ដល់រូបមន្ត**

បណ្ដឹងតវ៉ាចំពោះការផ្ដល់រូបមន្ត គឺជាបណ្ដឹងពិសេសដែលអាចធ្វើទៅបាន នៅក្នុងករណីដែលមានការផ្ដល់រូបមន្តអនុវត្តពិសេសតាមបញ្ញត្តិ មាត្រា៣៥៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ដើម្បីឱ្យកូនបំណុលនៃការអនុវត្តអាចផាត់ចេញនូវការ អនុវត្តដោយបង្ខំដោយផ្អែកលើឯកសារចម្លងយថាភូតនៃលិខិតអនុវត្តនោះដោយបង្ខំ ដោយ

---

[២១] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣៤៣ កថាខណ្ឌទី២។

[២២] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣៦៣ កថាខណ្ឌទី១។

[២៣] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្ដីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, *សេចក្ដីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណី, ភាគ២, ការអនុវត្តដោយបង្ខំ និងការចាត់ចែងរក្សាការពារ, (ភ្នំពេញ៖ ក្រសួងយុត្តិធម៌)*៥៦។

ផ្អែកលើឯកសារចម្លងយថាភូតនៃលិខិតអនុវត្តនោះ ដោយឈរលើមូលហេតុថាលក្ខខណ្ឌចាំបាច់សម្រាប់ការផ្តល់រូបមន្តពិសេសនោះមិនត្រូវបានបំពេញ ។[២៤] ដើមចោទនៅក្នុងបណ្តឹងនេះ គឺជាកូនបំណុលនៃការអនុវត្ត ឬបុគ្គលក្រៅពីភាគីក្នុងលិខិតអនុវត្តដែលត្រូវទទួលរងនូវអនុភាពនៃការអនុវត្ត។ ចុងចម្លើយនៅក្នុងរឿងក្តីនេះ គឺជាម្ចាស់បំណុលនៃការអនុវត្ត។កូនបំណុលនៃការអនុវត្តអាចដាក់ពាក្យបណ្តឹងតវ៉ាចំពោះ ការផ្តល់រូបមន្តអនុវត្តចាប់តាំងពីពេលដែលមានការផ្តល់រូបមន្តអនុវត្តរហូតដល់ពេលអនុវត្តដោយបង្ខំមិនទាន់ត្រូវបានបញ្ចប់។

❖ **បណ្តឹងតវ៉ារបស់តតិយជន**

ភាគីអាចមានសិទ្ធិធ្វើបណ្តឹង ប្រសិនបើភាគីយល់ថាសិទ្ធិរបស់ខ្លួនត្រូវបានបំពាននិងមានបំណងសង្គ្រោះ សិទ្ធិតាមផ្លូវតុលាការ។ បណ្តឹងតវ៉ារបស់តតិយជន គឺជាបណ្តឹងរបស់តតិយជនដែលមានកម្មសិទ្ធិ ឬសិទ្ធិផ្សេងទៀតដែលរាំងស្ទះការធ្វើអនុប្បទាន ឬប្រគល់ចំពោះវត្ថុដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំដើម្បីទាមទារកុំឱ្យអនុញ្ញាតការអនុវត្តដោយបង្ខំចំពោះម្ចាស់បំណុលនៃការអនុវត្តនោះបាន។[២៥] គោលបំណងនៃបណ្តឹងតវ៉ារបស់តតិយជន គឺដើម្បីចេញពីការអនុវត្តដោយបង្ខំនូវកម្មវត្ថុជាក់លាក់ណាមួយពីការអនុវត្តដោយបង្ខំ ហើយបណ្តឹងនេះមានសារសំខាន់ណាស់ពីព្រោះថាករណីនេះសម្រាប់ស្ថាប័នអនុវត្តមិនពិនិត្យមើលថា អ្នកណាជាម្ចាស់កម្មសិទ្ធិនោះទេ ប៉ុន្តែគ្រាន់តែពិនិត្យលក្ខខណ្ឌទម្រង់សម្រាប់ចាប់ផ្តើមការអនុវត្តដោយបង្ខំតែប៉ុណ្ណោះ។[២៦]

## ១.១.៧. ការផ្អាក និងការលុបចោលការអនុវត្តដោយបង្ខំ

ការផ្អាកការអនុវត្តដោយបង្ខំសំដៅ ទៅស្ថានភាពដែលស្ថាប័នអនុវត្តមិនអាចចាប់ផ្តើមឬបន្តការអនុវត្តដោយបង្ខំតាមច្បាប់បានដែលទំហំនៃ ការផ្អាកគឺប្រែប្រួលទៅតាមមូលហេតុនៃការផ្អាក។[២៧] គេអាចហៅថា

---

[២៤] ក្រុមការងារជប៉ុនដែលទទួកបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, *សេចក្តីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណី, ភាគ២, ការអនុវត្តដោយបង្ខំ និងការចាត់ចែងរក្សាការពារ, (ភ្នំពេញ៖ ក្រសួងយុត្តិធម៌)*៦៣។

[២៥] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣៦ដ កថាខណ្ឌទី១។

[២៦] លោកស្រី ចាំង ស៊ីណាត និងផ្សេងទៀត, សៀវភៅស្តីពី ការពន្យល់អំពីបណ្តឹងការតវ៉ានិងបណ្តឹងជំទាស់ទាក់ទងទៅនឹងការអនុវត្ត (វិច្ឆិកា ២០១១), ១៨។

[២៧] ក្រុមការងារជប៉ុនដែលទទួកបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, *សេចក្តីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណី, ភាគ២, ការអនុវត្តដោយបង្ខំ និងការចាត់ចែងរក្សាការពារ, (ភ្នំពេញ៖ ក្រសួងយុត្តិធម៌ )*៧០។

ជាការផ្អាកការអនុវត្តដោយបង្ខំមួយរយៈផងដែរ។[២៨] នៅក្នុងករណីដែល មានពាក្យបណ្ដឹងតវ៉ាចំពោះការទាមទារ ពាក្យបណ្ដឹងតវ៉ាចំពោះការផ្ដល់រូបមន្តអនុវត្ត ឬពាក្យបណ្ដឹងតវ៉ារបស់តតិយជនបើមានសេចក្ដីបញ្ជាក់ដំបូងអំពីមូលហេតុតវ៉ាដែលត្រូវបានអះអាង តុលាការដែលបានទទួលពាក្យបណ្ដឹង អាចបង្គាប់ឱ្យផ្អាកការបង្ខំមួយរយៈតាមពាក្យសុំ ដោយឱ្យដាក់ប្រាតិភោគ ឬមិនអោយដាក់ប្រាតិភោគបានរហូត ដល់ធ្វើការសម្រេចសេចក្ដីដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ នៃមាត្រា៣៦៩ (ការសម្រេចសេចក្ដីផ្អាកការអនុវត្តនៅក្នុងសាលក្រម ឬសាលដីកាលចុងក្រោយជាអាទិ៍) នៅក្នុងសាលក្រមចុងក្រោយ។[២៩]

ចំពោះតុលាការនៃបណ្ដឹងជំទាស់ មានវិធីពីរយ៉ាងនៅក្នុងការផ្អាករួមមាន បង្គាប់ឱ្យផ្អាកអនុភាពនៃដីកាសម្រេចដើម ដោយឱ្យដាក់ប្រាតិភោគ ឬមិនឱ្យដាក់ប្រាតិភោគ និងបង្គាប់ឱ្យផ្អាកនីតិវិធីនៃការអនុវត្តដោយបង្ខំមួយផ្នែក ឬទាំងមូលដោយឱ្យដាក់ប្រាតិភោគ ឬមិនឱ្យដាក់ប្រាតិភោគ។[៣០]

ការលុបចោលការអនុវត្តដោយបង្ខំ សំដៅទៅលើការជម្រះចេញនូវការចាត់ចែងការអនុវត្តទាំងមូល ឬមួយផ្នែកដែលបានធ្វើរួចហើយដោយស្ថាប័នអនុវត្ត នៅក្នុងដំណើរការនៃនីតិវិធីការអនុវត្តដោយបង្ខំ។ ដោយមុនពេលចាប់ផ្ដើមការអនុវត្តដោយបង្ខំ និង នៅក្រោយការបញ្ចប់នៃនីតិវិធីនីមួយៗនៃការអនុវត្តដោយបង្ខំនេះ មិនអនុញ្ញាតនោះទេ។ ក៏ដូចគ្នាផងដែរ ប្រសិនបើស្ថាប័នអនុវត្ត រកឃើញថាមានការខ្វះល័ក្ខខ័ណ្ឌទាមទារសម្រាប់ការអនុវត្តដោយបង្ខំដែលធ្វើឱ្យការអនុវត្តនោះ ក្លាយជាមោឃៈដោយឯកឯង ឬថាមានហេតុដែលជាឧបសគ្គចំពោះការអនុវត្តដោយបង្ខំនោះស្ថាប័នអនុវត្តត្រូវផ្អាក ឬត្រូវលុបចោលការអនុវត្តដោយបង្ខំនោះ។[៣១]

ម្យ៉ាងវិញទៀត ទោះបីជាមិនទៅដល់ដំណាក់កាលចុងក្រោយក៏ដោយ ប្រសិនបើស្ថាប័នអនុវត្តផ្អាកនីតិវិធី និងលុបចោលការចាត់ចែងការដែលបានធ្វើរួចហើយ ដោយសារម្ចាស់បំណុលបានដកពាក្យសុំឱ្យអនុវត្តដោយបង្ខំ ឬដោយសារកូនបំណុលនៃការអនុវត្ត ឬ តតិយជនបានដាក់ឯកសារដែលនាំឱ្យផ្អាក ឬ លុបចោលការ

---

[២៨] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្ដីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, *សេចក្ដីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណី, ភាគ២, ការអនុវត្តដោយបង្ខំ និងការចាត់ចែងរក្សាការពារ, (ភ្នំពេញ៖ ក្រសួងយុត្តិធម៌ )*៧៥។

[២៩] ក្រមនីតិរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣៦៧ កថាខណ្ឌទី១។

[៣០] ក្រមនីតិរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣៤៣ កថាខណ្ឌទី២។

[៣១] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្ដីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, *សេចក្ដីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណី, ភាគ២, ការអនុវត្តដោយបង្ខំ និងការចាត់ចែងរក្សាការពារ, (ភ្នំពេញ៖ ក្រសួងយុត្តិធម៌)*៧២។

អនុវត្តដោយបង្ខំ នោះនីតិវិធីនៃការអនុវត្តដោយបង្ខំ ត្រូវបានបញ្ចប់ ឧទាហរណ៍នៃករណីទាំងនេះ មានដូចជាករណីដែលមានវិការៈនៅក្នុងឯកសារចម្លងយថាភូតដែលមានអនុភាព អនុវត្តនៃលិខិតអនុវត្ត ឬ ករណីរកឃើញថាមាននីតិវិធីក្ស័យធនរបស់កូនបំណុលនៃការអនុវត្តបានចាប់ផ្តើមជាអាទិ៍។[៣២]

## ១.២.ប្រភេទនៃការអនុវត្តដោយបង្ខំ

បុគ្គលដែលមានសិទ្ធិទាមទារ ឬសិទ្ធិប្រាតិភោគដែលបានកំណត់នៅក្នុងក្រមរដ្ឋប្បវេណី ឬច្បាប់ផ្សេងៗ អាចទាមទារសម្រេចសិទ្ធិដោយការអនុវត្តដោយបង្ខំបាន ប៉ុន្តែទោះបីយ៉ាងនេះក្តីនៅក្នុងក្រមនីតិវិធីបានកំណត់ច្បាស់លាស់ ចំពោះទ្រព្យសម្បត្តិដែលអាចរឹបអូសបាន និងទ្រព្យសម្បត្តិដែលមិនអាចរឹបអូសបានដើម្បីជៀសវាងការបំពាននូវសិទ្ធិណាមួយ និង ការពារដល់ជីវភាពរបស់កូនបំណុល។

ការរឹបអូស អាចធ្វើបានចំពោះរូបទ្រព្យ ឬ អរូបទ្រព្យដែលធ្លាក់ទៅលើកូនបំណុលនៃការអនុវត្ត ហេតុដូច្នេះ ការអនុវត្តនេះមានការបែងចែកប្រភេទផ្សេងៗគ្នាដែលមានដូចជា ការអនុវត្តដោយបង្ខំចំពោះអចនវត្ថុ ការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ ការអនុវត្តដោយបង្ខំចំពោះនាវា ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល។

### ១.២.១.ការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ

អចលនវត្ថុសំដៅ ទៅលើដីអគារដែលត្រូវបានចុះបញ្ជីចំណែកនៃកម្មសិទ្ធិអវិភាគលើដីឯអគារនោះសិទ្ធិជួលអចិន្ត្រៃយ៍និងផលុបភោគដែលត្រូវបានចុះបញ្ជី និងចំណែកនៃសិទ្ធិទាំងនេះដែលជាសិទ្ធិរួម។[៣៣] ការរឹបអូសអាចធ្វើបានចំពោះរូបទ្រព្យ ឬ អរូបទ្រព្យដែលធ្លាក់ទៅលើកូនបំណុលនៃការអនុវត្ត។ ចំពោះការអនុវត្តដោយបង្ខំនេះផងដែរ ត្រូវតែមានពាក្យសុំពីភាគី និងអនុវត្តដោយស្ថាប័នអនុវត្ត ហើយត្រូវធ្វើតាមវិធីលក់ដោយបង្ខំ។ ការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ ត្រូវធ្វើតាមវិធីលក់ដោយបង្ខំ។[៣៤]

---

[៣២] ក្រុមការងារជប៉ុនដែលទទួកបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, *សេចក្តីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណី, ភាគ២, ការអនុវត្តដោយបង្ខំ និងការចាត់ចែងរក្សាការពារ, (ភ្នំពេញ៖ ក្រសួងយុត្តិធម៌)*៧០។

[៣៣] ក្រមនីតិវិរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៤១៧។

[៣៤] ក្រមនីតិវិរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៤១៧ កថាខណ្ឌទី២។

នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីមាន ស្ថាប័ន២ប្រភេទ គឺតុលាការអនុវត្ត និងអាជ្ញាសាលា ដែលត្រូវបាន កំណត់ថាជាស្ថាប័នអនុវត្ត។ សម្រាប់ការអនុវត្តដោយបង្ខំចំពោះអចនវត្ថុ តុលាការដែលមានសមត្ថកិច្ចនោះ អាស្រ័យទៅលើកម្មវត្ថុនៃការអនុវត្តនោះ៖[៣៥]

- ដោយក្នុងករណីដី ឬ អគារដែលបានចុះបញ្ជីជាកម្មវត្ថុនោះជាសមត្ថកិច្ចរបស់សាលាដំបូងនៅទីតាំង នោះមានសមត្ថកិច្ច
- ហើយបើក្នុងករណី កម្មវត្ថុនៃការអនុវត្តនោះជាចំណែកនៃកម្មសិទ្ធិអវិភាគនៅលើដី ឬអគារដែលបានចុះ បញ្ជី ឬសិទ្ធិជួលធចិរន្ត្រៃយ៍ ផលុបភោគដែលបានចុះបញ្ជី ចំណែកនៃសិទ្ធិទាំងនេះជាសិទ្ធិរួម។

**ចំពោះកម្មវត្ថុនៃបណ្តឹងជំទាស់នៅក្នុងនីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុមាន ច្រើនដូចជា៖**

- ដីកាសម្រេច លើកចោលពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ[៣៦]
- ដីកាសម្រេចលើកចោលការទាមទារឱ្យចែកចំណែក[៣៧]
- ដីកាសម្រេចអនុញ្ញាត ឬមិនអនុញ្ញាតឱ្យលក់ដោយបង្ខំចំពោះអចលនវត្ថុ[៣៨]
- ដីកាសម្រេចអំពីពាក្យសុំឱ្យចេញដីកាសម្រេចបង្គាប់ឱ្យប្រគល់អចលនវត្ថុ[៣៩]

### ១.២.២.ការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ

ចលនវត្ថុ សំដៅទៅលើវត្ថុដែលអាចរំកិល ឬផ្លាស់ទីតាំងបាន ដូចជារបស់របរផ្ទាល់ខ្លួន ឬ ទ្រព្យសម្បត្តិ ទាំងឡាយដែលអាចបម្លាស់ទីបាន ហើយមិនត្រូវបានចាត់ទុកជាប្រភេទនៃអចលនវត្ថុ។ម្យ៉ាងទៀតចលនវត្ថុ ដែលបានកំណត់នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី មានរួមបញ្ចូលទាំងផលធម្មជាតិដលមិនទាន់បំបែកពីដីនៅ ឡើយហើយអាចនឹងទទួលផលបានយ៉ាងច្បាស់នៅក្នុងអំឡុងពេលមួយខែ។[៤០] ការអនុវត្តដោយបង្ខំចំពោះ ចលនវត្ថុ គឺជាការអនុវត្តដោយបង្ខំដែលត្រូវធ្វើឡើងតាមវិធីដែលអាជ្ញាសាលារឹបអូសយកចលនវត្ថុដែលជាកម្ម

[៣៥] ក្រមនីតិរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៤១៨។

[៣៦] ក្រមនីតិរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៤១៩ កថាខណ្ឌទី៣។

[៣៧] ក្រមនីតិរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៤២៦ កថាខណ្ឌទី៥។

[៣៨] ក្រមនីតិរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៤៤៤ កថាខណ្ឌទី១។

[៣៩] ក្រមនីតិរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៤៥០ កថាខណ្ឌទី៥។

[៤០]ក្រមនីតិរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣៨៤ កថាខណ្ឌទី៥។

សិទ្ធិរបស់កូនបំណុលនការអនុវត្ត។[41] សម្រាប់ការចាប់ផ្តើមនៃនីតិវិធីចំពោះចលនវត្ថុគឺអាជ្ញាសាលាជាអ្នកចាប់ផ្តើមដោយ ការរឹបអូសវត្ថុដែលជាកម្មវត្ថុនៃការរឹបអូស ហើយចលនវត្ថុដែលត្រូវបានរឹបអូសហើយ នឹងត្រូវស្ថិតនៅក្រោមការថែរក្សាគ្រប់គ្រងរបស់អាជ្ញាសាលាប៉ុន្តែ ប្រសិនបើអាជ្ញាសាលាយល់ឃើញថាសមរម្យអាជ្ញាសាលាអាចឱ្យកូនបំណុលនៃ ការអនុវត្តថែរក្សាគ្រប់គ្រងចលនវត្ថុដែលបានរឹបអូសនោះបាន។

### ១.២.៣.ការអនុវត្តដោយបង្ខំចំពោះចំពោះនាវា

នាវាសំដៅទៅលើជលផលយានដែលមានចំណុះសរុបជាតោនស្មើនឹង និងលើស២០តោន និងចលយានដែលមានចំណុះសរុបជាតោនក្រោម២០តោនហើយដែលបានចុះបញ្ជីនៅព្រះរាជាណាចក្រកម្ពុជា។[42] ចំពោះការចាត់ទុកថានាវានោះជានាវាស្របច្បាប់លុះត្រានាវានោះមាន លិខិតបញ្ជាក់សញ្ជាតិនាវា ដែលជាឯកសាដែលបញ្ជាក់ពីសញ្ជាតិរបស់នាវា និងឯកសារផ្សេងទៀតដែលចាំបាច់ ។

តុលាការអនុវត្តដែលមានសមត្ថកិច្ចនៅក្នុងការអនុវត្ត គឺជាតុលាការដំបូងដែលមានសមត្ថកិច្ចនៅកន្លែងដែលនាវាស្ថិតនៅ នៅពេលចេញដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំ ហើយការអនុវត្តដោយបង្ខំចំពោះនាវាត្រូវអនុវត្តតាមវិធីលក់ដោយបង្ខំ ធ្វើដោយតុលាការអនុវត្ត ។

ចំពោះកម្មវត្ថុនៃបណ្តឹងជំទាស់ នៅក្នុងនីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះនាវាមាន៖

- ដីកាសម្រេចលើកចោល ពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះនាវា[43]
- ដីកាសម្រេចអនុញ្ញាត ឬ មិនអនុញ្ញាតឱ្យលក់ដោយបង្ខំចំពោះនាវា[44]
- ដីកាសម្រេចអំពីពាក្យសុំឱ្យលុបចោលដីកាសម្រេចអនុញ្ញាតលក់[45]
- ដីកាសម្រេចបង្គាប់ឱ្យប្រគល់នាវា[46]

---

[41]ក្រុមការងារជប៉ុនដែលទទួកបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, *សេចក្តីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណី, ភាគ២, ការអនុវត្តដោយបង្ខំ និងការចាត់ចែងរក្សាការពារ, (ភ្នំពេញ៖ ក្រសួងយុត្តិធម៌)*៨៦។

[42] ក្រមនីតិវិធីរដ្ឋប្បវេណ្ី មាត្រា៤៥៤ កថាខណ្ឌទី១

[43] ក្រមនីតិវិរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៤៥៧ កថាខណ្ឌទី៧។

[44] ក្រមនីតិវិរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៤៧៥ កថាខណ្ឌទី១។

[45] ក្រមនីតិវិរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៤៧៦ កថាខណ្ឌទី២។

[46] ក្រមនីតិវិរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៤៨៣ កថាខណ្ឌទី៤។

### ១.២.៤.ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល

ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល គឺជាការអនុវត្តដោយបង្ខំដើម្បីសម្រេចនូវសិទ្ធិទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់របស់ម្ចាស់បំណុលតាមរយៈការរឹបអូសសិទ្ធិលើបំណុល ដែលមានកម្មវត្ថុជាការសងជាប្រាក់ ឬជាការប្រគលចលនវត្ថុដែលជារបស់កូនបំណុលហើយប្តូរជាប្រាក់នូវតម្លៃសេដ្ឋកិច្ចនៃសិទ្ធិលើបំណុលនោះ។[៤៧] សម្រាប់សិទ្ធិដែលជាកម្មវត្ថុនៃ ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលមានជាសិទ្ធិទាមទារឱ្យសងជាប្រាក់ និងសិទ្ធិទាមទារឱ្យប្រគល់វត្ថុ។ ចំពោះកម្មវត្ថុបណ្តឹងជំទាស់នៅក្នុងនីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលនៅក្នុងក្រមរដ្ឋប្បវេណីអនុញ្ញាតឱ្យប្តឹងលើដីកាសម្រេចចំនួន៣គឺ ៖

- សេចក្តីសម្រេចអំពីពាក្យសុំឱ្យអនុវត្ត[៤៨]
- ដីកាសម្រេចលើកចោលការទាមទារឱ្យចែកចំណែក[៤៩]
- ដីកាសម្រេចអំពីបាក្យសុំដីកាសំរេចបង្គាប់ឱ្យលក់សិទ្ធិលើបំណុល[៥០]

### ១.៣.ប្រភពច្បាប់ដែលមានការទាក់ទង ការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ

យើងបានដឹងហើយថាប្រទេសកម្ពុជា គឺជាប្រទេសដែលប្រកាន់នូវរបបនៅនីតិរដ្ឋ ហើយស្ថិតនៅក្រោមការគ្រប់ដោយច្បាប់ដោយរដ្ឋធម្មនុញ្ញជាច្បាប់កំពូលរបស់ប្រទេស និងមានឋានានុក្រមខ្ពស់ដែលត្រូវគោរពនិងអនុវត្តតាម។ យើងសង្កេតឃើញថា នៅក្នុងច្បាប់កំពូលនេះមានចែងទាក់ទងនឹងការការពារសិទ្ធិរបស់ប្រជាពលរដ្ឋទាំងអស់ ជាក់ស្តែងជំពូកទី៣ ស្តីពីសិទ្ធិនិងករណីកិច្ចរបស់ប្រជាពលរដ្ឋខ្មែរ ដោយបានចែងថាប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងករណីកិច្ចដូចគ្នាទាំងអស់ដោយមិនប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសាជំនឿ ឬស្ថានភាពផ្សេងទៀត។[៥១]

---

[៤៧] ក្រុមការងារជប៉ុនដែលទទួកបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, *សេចក្តីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណី, ភាគ២, ការអនុវត្តដោយបង្ខំ និងការចាត់ចែងរក្សាការពារ, (ភ្នំពេញ៖ ក្រសួងយុត្តិធម៌)*៩៣។

[៤៨] ក្រមនីតិវិរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៤០៣ កថាខណ្ឌទី១១។

[៤៩] ក្រមនីតិវិរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៤០៩ កថាខណ្ឌទី៣។

[៥០] ក្រមនីតិវិរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៤១៣ កថាខណ្ឌទី៣។

[៥១] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា,២៤ កញ្ញា ១៩៩៣, មាត្រា ៣១។

ច្បាប់ពាក់ព័ន្ធនឹងការអនុវត្តដោយបង្ខំត្រូវសំដៅទៅលើ បទប្បញ្ញត្តិដែលទាក់ទងទៅនឹងរចនាសម្ព័ន្ធ និង នីតិវិធីនៃប្រព័ន្ធនៃការអនុវត្តទាំងអស់នេះ។ ច្បាប់ពាក់ព័ន្ធនឹង ការអនុវត្តដោយបង្ខំ មានប្បញ្ញត្តិនៅក្នុងគន្ថីទី៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦ ចែងចម្បងអំពីស្ថាប័នអនុវត្ត នៃនីតិវិធិក្នុងការអនុវត្តដោយបង្ខំ និងបណ្ដឹងពាក់ព័ន្ធនៅក្នុងនីតិវិធីនេះ។ ប្រពន្ធនៃការអនុវត្តដោយបង្ខំនេះ គឺជាផ្នែកមួយដ៏សំខាន់នៃប្រព័ន្ធនីតិវិធីរដ្ឋប្បវេណី។ និងប្រកាសអន្តរក្រសួងរបស់ក្រសួងយុត្តិធម៌ និងក្រសួងរៀបចំដែនដី នគររូបនីយកម្មនិងសំណង់ឆ្នាំ២០១១ ស្ដីពីនីតិវិធីនៃការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី បញ្ញត្តិ អំពីនីតិវិធីនៃការផ្ទុកផ្ដាក់របស់ក្រឡាបញ្ជីទៅស្ថាប័នដែលមានសមត្ថកិច្ចចុះបញ្ជីអំពីការរឹបអូស ការផ្ទេរ ការលុបចោល ដោយយោងតាមក្រមនីតិវិធីរដ្ឋប្បវេណី និងនីតិវិធីនៃការចុះបញ្ជីទាំងនោះ។[៥២] ហើយអចលនវត្ថុ ដែលមិនទាន់បានចុះបញ្ជីបង្កការលំបាក់នៅក្នុងការអនុវត្តដោយបង្ខំ។

[៥២] ប្រកាសអន្តរក្រសួងលេខ ៥៩ ប្រក.ដ.ន.ស/១១ ស្ដីពីការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី,០៣ ឧសភា ២០១១ ប្រការ២

# ជំពូកទី២
# លំហូរនីតិវិធីនៃការអនុវត្តដោយបង្ខំ
# ចំពោះអចលនវត្ថុ

# ជំពូកទី២
# លំហូរនីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ

ការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ គឺជានីតិវិធីនៃការលក់ដោយបង្ខំចំពោះអចលនវត្ថុរបស់កូនបំណុលនៃការអនុវត្ត ដើម្បីជួយសម្រេចសិទ្ធិទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់ដោយប្រើអំណាចរបស់រដ្ឋ។ ដោយឡែក ចំពោះស្ថាប័នដែលមានសមត្ថកិច្ចក្នុងការអនុវត្តលក់ដោយបង្ខំចំពោះអចលនវត្ថុ ជាសមត្ថកិច្ចរបស់តុលាការអនុវត្ត។ នីតិវិធីនៃការអនុវត្តដោយបង្ខំ គឺជានីតិវិធីដែលអាចសម្រេចនៅសិទ្ធិទាមទាររបស់ម្ចាស់បំណុលនៃការអនុវត្ត នៅពេលដែលកូនបំណុលនៃការអនុវត្ត មិនអនុវត្តកាតព្វកិច្ចរបស់ខ្លួនដោយស្ម័គ្រចិត្ត។

## ២.១ លក្ខខណ្ឌនៃការអនុវត្តដោយបង្ខំ

ឯកសារចាំបាច់ក្នុងការដាក់ពាក្យសុំអនុវត្តដោយបង្ខំមានដូចជា៖ លិខិតអនុវត្ត លិខិតបញ្ជាក់អំពីការបញ្ជូនលិខិតអនុវត្ត រូបមន្តអនុវត្ត និងពាក្យសុំអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ។

### ២.១.១. លិខិតអនុវត្ត

ដើម្បីធ្វើការអនុវត្តដោយបង្ខំបាន លុះត្រាតែមានលិខិតអនុវត្ត។[៥៣] លិខិតអនុវត្ត គឺជាឯកសារដែលបញ្ជាក់អំពីសិទ្ធិទាមទារឱ្យផ្តល់តាវកាលិកណាមួយជាក់លាក់ ដែលកំណត់នៅក្រោមនីតិឯកជន ហើយដោយផ្អែកលើឯកសារនេះ ច្បាប់បានផ្តល់ឱ្យនូវអំណាចបង្ខំឱ្យអនុវត្ត ដើម្បីសម្រេចនូវអត្ថន័យនៃសិទ្ធិនោះ តាមរយៈការអនុវត្តដោយបង្ខំ។

លិខិតអនុវត្ត គឺជាប្រភេទលិខិតដែលបានកំណត់ដូចខាងក្រោម៖[៥៤]

- សាលក្រម ឬ សាលដីកាបង្គាប់ឲ្យផ្តល់តាវកាលិកដែលបានចូលជាស្ថាពរ
- សាលក្រម ឬ សាលដីកាបង្គាប់ឲ្យផ្តល់តាវកាលិក ដែលភ្ជាប់ជាមួយនឹងការប្រកាសឲ្យអនុវត្តជាបណ្តោះអាសន្ន
- ដីកាសម្រេចបង្គាប់ឲ្យផ្តល់តាវកាលិក។ ចំពោះដីកាសម្រេចដែលចូលជាស្ថាពរទើបមានអានុភាពលុះត្រាតែ ដីកាសម្រេចនោះចូលជាស្ថាពរសិន
- ដីកាសម្រេចដាស់តឿន ដែលភ្ជាប់ជាមួយនឹងការប្រកាស ឱ្យអនុវត្តជាបណ្តោះអាសន្ន

[៥៣] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១,០៦ កក្កដា ២០០៦, មាត្រា៣៥០ កថាខណ្ឌទី១។
[៥៤] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១,០៦ កក្កដា ២០០៦, មាត្រា៣៥០ កថាខណ្ឌទី២។

- ការចាត់ចែងរបស់ក្រឡាបញ្ជី ដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ នៃមាត្រា៦៦ (នីតិវិធីដើម្បីកំណត់ជាស្ថាពរនូវចំនួនប្រាក់ប្រដាប់ក្ដី) នៃក្រមនីតិវិធីរដ្ឋប្បវេណី
- លិខិតយថាភូត ដែលធ្វើដោយសារការី ចំពោះការទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់មានកំណត់ និងមានបញ្ជាក់សេចក្ដីថ្លៃការណ៍ថាកូនបំណុលនឹងទទួលការអនុវត្តដោយបង្ខំភ្លាមៗ
- សាលក្រម ឬសាលដីការបស់តុលាការបរទេស ដែលមានសាលក្រមអនុវត្ត ដែលបានចូលជាស្ថាពរ
- សេចក្ដីសម្រេចមជ្ឈត្តករ ដែលមានដីកាសម្រេចអនុវត្តដែលបានចូលជាស្ថាពរ
- កំណត់ហេតុ សះជា ឬទទួលស្គាល់ការទាមទារ ដែលបានកំណត់នៅក្នុងមាត្រា២២២ និងកំណត់ហេតុផ្សេងទៀតដែលមានអានុភាពដូចសាលក្រម ឬ សាលដីកាដែលបានចូលជាស្ថាពរ។

### ២.១.២. លិខិតបញ្ជាក់អំពីការបញ្ជូនលិខិតអនុវត្ត

ជាទូទៅមុននឹងចាប់ផ្ដើមការអនុវត្តដោយបង្ខំ លិខិតអនុវត្តត្រូវបញ្ជូនទៅឱ្យកូនបំណុលនៃការអនុវត្តជាមុនសិន។[៥៥] ដោយលិខិតបញ្ជាក់អំពីការបានបញ្ជូនលិខិតអនុវត្តនេះផងដែរ ធ្វើឡើងក្នុងគោលបំណងដើម្បីបញ្ជាក់ពីការបានបញ្ជូនលិខិតរួចហើយ។ មូលហេតុដែលត្រូវបញ្ជូនលិខិតអនុវត្តទៅកូនបំណុលនៃការអនុវត្តគឺដើម្បីជូនដំណឹងទុកជាមុនចំពោះកូនបំណុលនៃការអនុវត្ត ថា តើមានខ្លឹមសារអ្វីខ្លះ? ដែលនឹងត្រូវបានអនុវត្តដោយបង្ខំ។

### ២.១.៣. រូបមន្តអនុវត្ត

ស្ថាប័នអនុវត្តត្រូវបានធ្វើការអនុវត្តដោយបង្ខំ ដោយផ្អែកលើឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលភ្ជាប់ជាមួយនឹងរូបមន្តអនុវត្ត។[៥៦] រូបមន្តអនុវត្ត គឺជាប្រយោគក្រឡាបញ្ជីឬសារការីសរសេរបញ្ជាក់នូវអត្ថិភាព និងអត្ថន័យនៃអំណាចរបស់លិខិតអនុវត្តដើម្បីយកទៅអនុវត្តដោយបង្ខំនោះ។

មុននឹងឈានដល់ការដាក់ពាក្យសុំអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ ម្ចាស់បំណុលនៃការអនុវត្តត្រូវដាក់ពាក្យសុំឱ្យតុលាការផ្ដល់រូបមន្តអនុវត្តលើឯកសារចម្លងយថាភូតនៃលិខិតអនុវត្តជាមុនសិន។

---

[៥៥] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១,០៦ កក្កដា ២០០៦, មាត្រា៣៦០ វាក្យខណ្ឌទី១។

[៥៦] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១,០៦ កក្កដា ២០០៦, មាត្រា៣៥៤ កថាខណ្ឌទី១។

### ២.១.៣.១. ពាក្យសុំឱ្យផ្តល់រូបមន្តអនុវត្ត

**ពាក្យសុំឱ្យផ្តល់រូបមន្តអនុវត្ត ត្រូវធ្វើជាលាយលក្ខណ៍អក្សរដែលមានសរសេរនូវចំណុចដូចខាងក្រោម៖**[៥៧]

- ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋានរបស់ម្ចាស់បំណុលនៃការអនុវត្ត និងកូនបំណុលនៃការអនុវត្ត ហើយ និងឈ្មោះ និង អាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់
- សញ្ញាណនៃលិខិតអនុវត្ត
- ហេតុការណ៍ និងមូលហេតុ បើការទាមទារឲ្យផ្តល់រូបមន្តអនុវត្តត្រូវធ្វើឡើងតាមបញ្ញត្តិនៃមាត្រា ៣៥៦ ឬមាត្រា ៣៥៨ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

**ឯកសារដែលត្រូវភ្ជាប់ជាមួយពាក្យសុំឱ្យផ្តល់រូបមន្តអនុវត្តមានដូចជា៖**

- ឯកសារចម្លងយថាភូតនៃលិខិអនុវត្ត
- ឯកសារដែលបញ្ជាក់អំពីសិទ្ធិអំណាចរបស់អ្នកតំណាងដោយអាណត្តិ
- ភស្តុតាងជាឯកសារដែលបញ្ជាក់ថាសាលក្រមស្ថាពរ។

ប៉ុន្តែប្រសិនបើសេចក្តីសម្រេចនោះបានចូលស្ថាពរហើយក្នុងសំណុំរឿងនោះ ភស្តុតាងជាឯកសារដែលបញ្ជាក់ថាសាលក្រមស្ថាពរនោះ គឺមិនត្រូវបានភ្ជាប់មកជាមួយទេនៅក្នុងករណីនេះ។[៥៨]

បន្ទាប់ពីបានរៀបចំពាក្យសុំឱ្យផ្តល់រូបមន្តអនុវត្តរួចហើយ ម្ចាស់បំណុលនៃការអនុវត្តត្រូវដាក់ពាក្យសុំឱ្យផ្តល់រូបមន្តនេះ ទៅកាន់ការិយាល័យក្រឡាបញ្ជីនៃតុលាការដែលទទួលបន្ទុកដោះស្រាយសំណុំរឿងអង្គសេចក្តី។

កត់សម្គាល់ថា៖ លិខិតអនុវត្តដែលពុំចាំបាច់មានរូបមន្តអនុវត្តរួមមាន សាលក្រមនៃបណ្តឹងរឿងក្តីចំនួនទឹកប្រាក់តិចដែលបានចូលជាស្ថាពរ សាលក្រមនៃបណ្តឹងរឿងក្តីចំនួនទឹកប្រាក់តិចដែលភ្ជាប់ការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន ដីកាសម្រេចដាស់តឿនដែលភ្ជាប់ការប្រកាសឲ្យអនុវត្តជាបណ្តោះអាសន្ន។[៥៩]

### ក. ភាពចាំបាច់នៃរូបមន្តអនុវត្ត

គោលការណ៍ដែលតម្រូវឱ្យមានភ្ជាប់មកជាមួយនូវរូបមន្តអនុវត្តព្រោះ៖

---

[៥៧] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១,០៦ កក្កដា ២០០៦, មាត្រា៣៥៥ កថាខណ្ឌទី វាក្យខណ្ឌទី១។

[៥៨] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១,០៦ កក្កដា ២០០៦, មាត្រា៣៥៥ កថាខណ្ឌទី២ វាក្យខណ្ឌទី២។

[៥៩] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១,០៦ កក្កដា ២០០៦, មាត្រា៣៥៤ កថាខណ្ឌទី១ វាក្យខណ្ឌទី២។

១. ស្ថាប័នអនុវត្តមិនមែនជាតុលាការនៃបណ្តឹងទេ ដូច្នេះមិនមែនជាការសមស្របទេបើឱ្យស្ថាប័នអនុវត្តធ្វើការវិនិច្ឆ័យទៅលើការអនុវត្តនៃលិខិតអនុវត្តនៅពេលមានពាក្យសុំឱ្យអនុវត្តដោយបង្ខំម្តងៗ ដែលជាហេតុនាំឱ្យមានភាពយឺតយ៉ាវនៅក្នុងការអនុវត្តដោយបង្ខំ។

២. នៅក្នុងករណីដែលការអនុវត្តដោយបង្ខំត្រូវធ្វើឡើង ចំពោះបុគ្គលផ្សេងពីអ្នកដែលបានបញ្ជាក់នៅក្នុងលិខិតអនុវត្តថាជាម្ចាស់បំណុល ឬ កូនបំណុលនៃការអនុវត្តនោះចាំបាច់ត្រូវធ្វើការពិនិត្យស្រាវជ្រាវថា តើបុគ្គលដែលត្រូវទទួលឥទ្ធិពលនៃអានុភាពអនុវត្តនៃការអនុវត្តដែរ ឬ ទេ (តើបុគ្គលនោះមានលក្ខណៈក្នុងការធ្វើជាភាគីនៃការអនុវត្តដោយបង្ខំឬទេ) ហើយប្រសិនបើបុគ្គលនោះ ជាបុគ្គលដែលត្រូវទទួលឥទ្ធិពលនៃអានុភាពអនុវត្តនៃលិខិតអនុវត្តមែននោះ ត្រូវសរសេរបន្ថែមនៅក្នុងលិខិតអនុវត្តដោយរៀបរាប់អំពីចំណុចនោះ ក្រោមទម្រង់ជារូបមន្ត។

**ខ. ស្ថាប័នដែលផ្តល់រូបមន្តអនុវត្ត**

ជាគោលការណ៍រូបមន្តអនុវត្ត ត្រូវផ្តល់ដោយក្រឡាបញ្ជីនៃតុលាការអនុវត្ត ដែលមានសំណុំរឿងតាមពាក្យសុំ។[៦០] ហើយក្រឡាបញ្ជីនៃតុលាការដែលមានសំណុំរឿងនេះ ជាទូទៅគឺក្រឡាបញ្ជីនៃតុលាការដែលទទួលបន្ទុកដោះស្រាយបណ្តឹងអង្គសេចក្តី។ ប៉ុន្តែក្នុងករណីដែលលិខិតយថាភូតត្រូវបានធ្វើឡើងដោយសារការីចំពោះ
ការទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់មានកំណត់ហើយដែលរក្សាទុកនូវលិខិតដើមនោះ ជាស្ថាប័នអនុវត្ត។[៦១]

ការផ្តល់រូបមន្តអនុវត្តត្រូវធ្វើឡើងតាមវិធីសរសេរភ្ជាប់បន្ថែមនូវផ្នែក ខាងក្រោមនៃឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត។[៦២]

ចំណុចដែលត្រូវសរសេរក្នុងរូបមន្តអនុវត្តមានដូចខាងក្រោម៖

- បុគ្គលដែលអាចទាមទារ និងភាគីម្ខាងទៀត
- ហេតុការណ៍ក្នុងករណីដែលផ្តល់រូបមន្តអនុវត្តតាមមាត្រា ៣៥៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី
- ទំហំដែលអាចអនុវត្តដោយបង្ខំបាន

[៦០] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១,០៦ កក្កដា ២០០៦, មាត្រា៣៥៤ កថាខណ្ឌទី២ វាក្យខណ្ឌទី១។

[៦១] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១,០៦ កក្កដា ២០០៦, មាត្រា៣៥៤ កថាខណ្ឌទី២ វាក្យខណ្ឌទី២។

[៦២] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១,០៦ កក្កដា ២០០៦, មាត្រា៣៥៧ កថាខណ្ឌទី១។

- ហេតុការណ៍ក្នុងករណីផ្តល់រូបមន្តអនុវត្ត តាមមាត្រា ៣៥៨ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ក្រឡាបញ្ជី ឬ សារការីត្រូវចុះហត្ថលេខាលើរូបមន្តអនុវត្ត ដោយសរសេរ ថ្ងៃ ខែ ឆ្នាំ នៃការផ្តល់។[៦៣]

## ២.១.៤. ពាក្យសុំអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ

បន្ទាប់ពីទទួលបានរូបមន្តអនុវត្តរួចរាល់ហើយ ម្ចាស់បំណុលនៃការអនុវត្តត្រូវដាក់ពាក្យសុំអនុវត្តដោយបង្ខំ (ពាក្យសុំអនុវត្តដោយបង្ខំត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ)[៦៤] ទៅស្ថាប័នអនុវត្តដែលមានសមត្ថកិច្ច តុលាការអនុវត្ត ឬអាជ្ញាសាលា។[៦៥]

### ១. ពាក្យសុំឱ្យអនុវត្តដោយបង្ខំត្រូវសរសេរនូវចំណុចដូចខាងក្រោម៖

- ឈ្មោះឬ នាមករណ៍ និងអាសយដ្ឋានរបស់ម្ចាស់បំណុលនៃការអនុវត្ត និងកូនបំណុលនៃការអនុវត្ត ហើយនឹងឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់
- សញ្ញាណនៃលិខិតអនុវត្ត
- សេចក្តីសុំឱ្យអនុវត្តតាមការបង្ខំដោយផ្ទាល់ ឬការអនុវត្តជំនួស ឬវិធានបង្ខំដោយប្រយោល
- សញ្ញានៃទ្រព្យសម្បត្តិ ដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ និងវិធីអនុវត្តដោយបង្ខំដែលម្ចាស់បំណុលនៃការអនុវត្តសុំក្នុងករណីដែលសុំឱ្យអនុវត្តតាមការបង្ខំដោយផ្ទាល់
- ខ្លឹមសារនៃសេចក្តីសម្រេចដែលម្ចាស់បំណុលសុំ ក្នុងករណីដែលសុំឱ្យអនុវត្តដោយបង្ខំ តាមការអនុវត្តជំនួស ឬវិធានបង្ខំដោយប្រយោល។

ក្នុងករណីខ្លះទាមទារឱ្យម្ចាស់បំណុលនៃការអនុវត្ត សុំឱ្យអនុវត្តដោយបង្ខំ ចំពោះផ្នែកណាមួយនៃសិទ្ធិទាមទារដែលបានសរសេរនៅក្នុងលិខិតអនុវត្តដែលបង្គាប់ឱ្យសងជាប្រាក់ ម្ចាស់បំណុលនៃការអនុវត្តត្រូវសរសេរបញ្ជាក់អំពីសេចក្តីសុំ និងទំហំនៃសេចក្តីសុំនោះ ក្នុងពាក្យសុំឱ្យអនុវត្តដោយបង្ខំ។

### ២. ឯកសារដែលត្រូវភ្ជាប់ជាមួយពាក្យសុំអនុវត្តដោយបង្ខំមានដូចខាងក្រោម៖

- លិខិតចម្លងយថាភូតនៃលិខិតអនុវត្តដែលមានអានុភាពអនុវត្ត[៦៦]
- រូបមន្តអនុវត្ត

[៦៣] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣៥៧ កថាខណ្ឌទី២។

[៦៤] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣៤៩ កថាខណ្ឌទី១។

[៦៥] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣៣៦ កថាខណ្ឌទី២។

[៦៦] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣៤៩ កថាខណ្ឌទី២។

- ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃសៀវភៅចុះបញ្ជីអចលនវត្ថុ[៦៧]

**កត់សម្គាល់ ៖** (ទាក់ទងនឹងអចលនវត្ថុមិនទាន់ចុះបញ្ជី ម្ចាស់បំណុលតត្រូវភ្ជាប់លិខិតដែលបញ្ជាក់ថា ដីនោះជាកម្មសិទ្ធិរបស់កូនបំណុល)។

- លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ។

បន្ទាប់ពីម្ចាស់បំណុលនៃការអនុវត្ត បានរៀបចំពាក្យសុំអនុវត្តដោយបង្ខំគ្រប់គ្រាន់ដូចដែលបានរៀបរាប់ខាងលើរួចរាល់ហើយម្ចាស់បំណុលនៃការអនុវត្តត្រូវយកពាក្យសុំនោះទៅដាក់នៅសាលាដំបូងដែលមានសមត្ថកិច្ចលើកន្លែងដែលអចលនវត្ថុនោះតាំងនៅ។[៦៨]

## ២.២. ការបង់សោហ៊ុយសម្រាប់ការអនុវត្ត

សោហ៊ុយសម្រាប់ការអនុវត្ត សំដៅលើពន្ធដាក់ពាក្យសុំដែលមានកំណត់ក្នុងមាត្រា៣៧២ សោហ៊ុយក្រៅពីពន្ធដាក់ពាក្យសុំ ដែលមានកំណត់ក្នុងមាត្រា ៣៧៣ និងសោហ៊ុយភាគីដែលបានកំណត់ក្នុងមាត្រា ៣៧៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។[៦៩]

### ២.២.១. ពន្ធដាក់ពាក្យសុំ

ពន្ធដាក់ពាក្យសុំ គឺក្នុងករណីដែលបានដាក់ពាក្យសុំទៅតុលាការអនុវត្ត ម្ចាស់បំណុលនៃការអនុវត្តត្រូវបង់ពន្ធចំនួន ១០,០០០ (មួយម៉ឺន) រៀល ទៅតុលាការអនុវត្ត។ បន្ថែមពីនេះទៀត ចំពោះការដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំទៅអាជ្ញាសាលា ម្ចាស់បំណុលនៃការអនុវត្តត្រូវបង់ពន្ធ តាមបញ្ញត្តិដែលកំណត់ផ្សេង។ ដោយពុំគិតអំពីពាក្យសុំឱ្យអនុវត្ត ចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់ ឬចំពោះសិទ្ធិលើបំណុលដែលមិនមានគោលបំណងឱ្យសងជាប្រាក់ ហើយពុំគិតការបង្ខំដោយផ្ទាល់ ការអនុវត្តជំនួស ឬ ការបង្ខំដោយប្រយោលនោះទេ។ ចំណែកចំពោះការដាក់ពាក្យសុំឱ្យអនុវត្តពាក្យសុំទៅអាជ្ញាសាលាម្ចាស់បំណុលនៃការអនុវត្តក៏មានកាព្វកិច្ចត្រូវបង់ពន្ធតាមបញ្ញត្តិនៃច្បាប់ផ្សេងៗទៀត។[៧០]

---

[៦៧] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៤១៧ កថាខណ្ឌទី៣។

[៦៨] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១,០៦ កក្កដា ២០០៦, មាត្រា៤១៨។

[៦៩] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១,០៦ កក្កដា ២០០៦, មាត្រា៣៧១។

[៧០] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១,០៦ កក្កដា ២០០៦, មាត្រា៣៧២។

### ២.២.២. សោហ៊ុយក្រៅពីពន្ធដាក់ពាក្យសុំ

សោហ៊ុយក្រៅពីពន្ធដាក់ពាក្យសុំ គឺម្ចាស់បំណុលនៃការអនុវត្តត្រូវបង់នូវទឹកប្រាក់ ដែលកំណត់ដោយតុលាការអនុវត្ត ជាសោហ៊ុយចាំបាច់ក្នុងការបញ្ជូនឯកសារ ឬធ្វើសកម្មភាពផ្សេងទៀតដើម្បីនីតិវិធីក្នុងការអនុវត្តដោយបង្ខំ។[៧១] នៅក្នុងការអនុវត្តជាក់ស្តែង ក្រោយពីម្ចាស់បំណុលនៃការអនុវត្ត បានដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំរួចរាល់ហើយ តុលាការអនុវត្តនឹងចេញដីកាបង្គាប់ឱ្យបង់សោហ៊ុយក្រៅពីពន្ធដាក់ពាក្យសុំដែលបង្គាប់ឱ្យម្ចាស់បំណុលត្រូវបង់សោហ៊ុយដែលតុលាការបានកំណត់ ដើម្បីធ្វើសកម្មភាពផ្សេងៗ និងការបញ្ជូនឯកសារ។

អ្នកដាក់ពាក្យសុំត្រូវបង់ជាមុននូវសោហ៊ុយចាំបាច់ផ្សេងៗ ទៅតុលាការអនុវត្តដើម្បីធ្វើនីតិវិធីនៃការអនុវត្តដោយបង្ខំហើយ ក្នុងករណីដែលសោហ៊ុយត្រូវបានបង់ជាមុនមានភាពខ្វះនោះតុលាការនឹងបង្គាប់ឱ្យបង់នូវសោហ៊ុយដែលខ្វះនោះ ប៉ុន្តែប្រសិនបើភាគីដាក់ពាក្យសុំមិនព្រមបង់សោហ៊ុយជាមុនទេតុលាការអាចលើកចោលនូវពាក្យសុំអនុវត្តដោយបង្ខំ ឬលុបចោលនូវនីតិវិធីនៃការអនុវត្តដោយបង្ខំនោះបានចំពោះដីកាសម្រេចលើកចោលនីតិវិធីនៃការអនុវត្តនេះ គឺអាចប្តឹងជំទាស់បាន។[៧២]

## ២.៣. ការពិនិត្យពាក្យសុំ

បន្ទាប់ពីតុលាការអនុវត្តបានទទួលពាក្យសុំឱ្យអនុវត្តដោយបង្ខំហើយ តុលាការអនុវត្តត្រូវពិនិត្យមើលថាស្ថាប័នដែលម្ចាស់បំណុលបានដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំនោះ ជាស្ថាប័នមានសមត្ថកិច្ចអនុវត្ត ឬយ៉ាងណា? មានភាគីត្រឹមត្រូវដូចក្នុងលិខិតអនុវត្តដែរឬទេ? មានឯកសារភ្ជាប់មកគ្រប់គ្រាន់ ឬអត់? ហើយចំពោះលិខិតអនុវត្តមានការបញ្ជាក់ពីការចូលជាស្ថាពរ ឬអត់? មានរូបមន្តអនុវត្ត ឬអត់? ហើយពាក្យសុំឱ្យអនុវត្តដោយបង្ខំនោះ ធ្វើឡើងមានលក្ខណៈត្រឹមត្រូវតាមច្បាប់ដែរឬទេ? ក្នុងករណីដែលពាក្យសុំឱ្យអនុវត្តដោយបង្ខំមានចំណុចខ្វះខាតតុលាការ នឹងប្រាប់ឱ្យម្ចាស់បំណុលឱ្យធ្វើការកែតម្រូវដោយស្ម័គ្រចិត្ត។ ប៉ុន្តែករណីម្ចាស់បំណុលមិនបានកែតម្រូវតាមការស្ម័គ្រចិត្តទេ តុលាការអនុវត្តនឹងចេញដីកាបង្គាប់ឱ្យកែតម្រូវនូវចំណុចខ្វះខាតចំពោះពាក្យសុំឱ្យអនុវត្តដោយបង្ខំនោះ។ លើសពីនោះទៅទៀតក្នុងករណីដែលម្ចាស់បំណុលមិនបានកែតម្រូវនូវចំណុច

[៧១] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១,០៦ កក្កដា ២០០៦, មាត្រា៣៧៣។

[៧២] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១,០៦ កក្កដា ២០០៦, មាត្រា៣៧៥។

ខ្វះខាតទេ តុលាការនឹងត្រូវធ្វើការលើកពាក្យសុំចោលតាមរយៈដីការសម្រេចលើកចោលពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ ដោយដីកាសម្រេចនេះអាចប្តឹងជំទាស់បាន។[៧៣]

## ២.៤. ការចាប់ផ្តើមនីតិវិធីលក់ដោយបង្ខំ

នៅពេលដែលតុលាការអនុវត្តបានទទួលពាក្យសុំឱ្យអនុវត្តដោយបង្ខំ បានបំពេញត្រឹមត្រូវតាមច្បាប់ ហើយឯកសារចាំបាច់មានគ្រប់គ្រាន់ហើយ ដូចនេះតុលាការអនុវត្ត ត្រូវចាប់ផ្តើមនីតិវិធីនៃការលក់ដោយបង្ខំចំពោះអចលនវត្ថុ។

### ២.៤.១. ដីកាសម្រេចចាប់ផ្តើមលក់ដោយបង្ខំ

បន្ទាប់ពីពាក្យសុំឱ្យអនុវត្តដោយបង្ខំមានលក្ខណៈត្រឹមត្រូវតាមបញ្ញត្តិច្បាប់ និងម្ចាស់បំណុលបានបង់ប្រាក់សម្រាប់ការអនុវត្តរួចហើយ នោះតុលាការត្រូវបន្តនីតិវិធីដោយចេញដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំ ហើយត្រូវប្រកាសអំពីការរឹបអូសអចលនវត្ថុ ដើម្បីម្ចាស់បំណុលនៃការអនុវត្តក្នុងការសម្រេចចាប់ផ្តើមលក់ដោយបង្ខំ។[៧៤]

ជាគោលការណ៍ ដីកាសម្រេចចាប់ផ្តើមលក់ដោយបង្ខំនឹងមានអានុភាព លុះត្រាតែមានការបញ្ជូនទៅកូនបំណុលនៃការអនុវត្ត។[៧៥] ប៉ុន្តែចំពោះការបញ្ជូនដីកាសម្រេចនេះទៅឱ្យកូនបំណុល គឺត្រូវធ្វើឡើងបន្ទាប់ពីបានធ្វើការចុះបញ្ជីអំពីការរឹបអូសរួចជាមុនសិនទើបមានការបញ្ជូនដីកាសម្រេចនេះទៅកូនបំណុល។ចំពោះម្ចាស់បំណុលវិញនៅពេលដែលដីកាសម្រេចត្រូវបានចេញ គឺនឹងមានការជូនដំណឹងទៅម្ចាស់បំណុលភ្លាម។

### ២.៤.២. ការរឹបអូស

នៅពេលតុលាការបានចេញ ដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំរួចមក ក្រឡាបញ្ជីត្រូវរឹបអូសតាមរយៈការចេញលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជីអំពីការរឹបអូសទៅស្ថាប័នដែលមានសមត្ថកិច្ចចុះបញ្ជីអំពីការរឹបអូសដែលពាក់ព័ន្ធនឹងការសម្រេចចាប់ផ្តើមនោះជាបន្ទាន់។[៧៦] ក្នុងករណីដែលសេចក្តីសម្រេចចាប់ផ្តើមលក់ដោយបង្ខំត្រូវបានចេញចំពោះដីដែលមិនទាន់បានចុះបញ្ជី ស្ថាប័នដែលមានសមត្ថកិច្ចត្រូវចុះបញ្ជីក្បាលដីលើកដំបូងរួចសិនទើបចុះបញ្ជីពីការរឹបអូសនោះ។ ម្ចាស់បំណុលនៃការអនុវត្តមានកាតព្វកិច្ចបង់ជាមុននូវការចំណាយក្នុងការចុះ

[៧៣] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១,០៦ កក្កដា ២០០៦, មាត្រា៤១៩ កថាខណ្ឌទី៣។

[៧៤] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១,០៦ កក្កដា ២០០៦, មាត្រា៤១៩ កថាខណ្ឌទី១។

[៧៥] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១,០៦ កក្កដា ២០០៦, មាត្រា៤១៩ កថាខណ្ឌទី២។

[៧៦] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១,០៦ កក្កដា ២០០៦, មាត្រា៤២០ កថាខណ្ឌទី១។

បញ្ជីក្បាលដីលើកដំបូង (តម្លៃនៃការចុះបញ្ជីត្រូវអនុលោមតាមប្រកាសអន្តរក្រសួងស្តីពីការផ្តល់សេវាសាធារណៈរបស់រដ្ឋបាលសុរិយោដី)។

លិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជីអំពីការរឹបអូសនេះត្រូវបញ្ជូនតាមរយៈ ដីកាបញ្ជូនទៅរដ្ឋបាលសុរិយោដីរាជធានី/ខេត្ត ដែលអចលនវត្ថុតាំងនៅ។[៧៧] នៅក្នុងលិខិតផ្ទុកផ្តាក់នេះទៀតសោត ក្រឡាបញ្ជីត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរដោយសរសេរនូវ បាវចនានៃព្រះរាជាណាចក្រកម្ពុជា ឈ្មោះតុលាការអនុវត្ត លេខលិខិតផ្ទុកផ្តាក់ ឈ្មោះក្រឡាបញ្ជី កាលបរិច្ឆេទ ហត្ថលេខា និងបោះត្រារបស់ក្រឡាបញ្ជី ព្រមទាំងបន្ថែមនូវចំណុចមួយចំនួនដូចជា៖

- កម្មវត្ថុ នៃលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជីរឹបអូស
- អត្តសញ្ញាណនៃអចលនវត្ថុ
- ឈ្មោះកម្មសិទ្ធិករ
- គោលបំណងនៃការចុះបញ្ជី
- មូលហេតុ
- ឈ្មោះម្ចាស់បំណុលនៃការអនុវត្ត និង អ្នកតំណាងដោយអាណត្តិ (មេធាវី)
- ឈ្មោះកូនបំណុលនៃការអនុវត្ត និង អ្នកតំណាងដោយអាណត្តិ (មេធាវី)។

**ឯកសារភ្ជាប់ជាមួយលិខិតផ្ទុកផ្តាក់មានដូចជា៖**

- ដីកាសម្រេចចាប់ផ្តើមលក់ដោយបង្ខំ (ច្បាប់ដើម)
- វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ឬលិខិតផ្ទេរសិទ្ធិកាន់កាប់ (ច្បាប់ថតចម្លង) ជាដើម។

ចំណែកឯ ឯកសារដែលត្រូវដាក់បញ្ជូនទៅរដ្ឋបាលសុរិយោដីរាជធានី/ខេត្ត រួមមាន **លិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជីអំពីការរឹបអូសអចលនវត្ថុ ឯកសារចម្លងយថាភូតនៃដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំ។**[៧៨] ដើម្បីឱ្យរដ្ឋបាលសុរិយោដីរាជធានី/ខេត្ត ធ្វើការចុះបញ្ជីអំពីការរឹបអូសអចលនវត្ថុ។ បន្ទាប់ពីរដ្ឋបាលសុរិយោដីរាធានី/ខេត្ត បានចុះបញ្ជីអំពីការរឹបអូសតាមលិខិតផ្ទុកផ្តាក់របស់ក្រឡាបញ្ជីរួចរាល់ហើយ រដ្ឋបាលសុរិយោដីរាជធានី/ខេត្ត ត្រូវផ្ញើឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃសៀវភៅចុះបញ្ជីនោះទៅក្រឡាបញ្ជី។[៧៩] បើក្រឡាបញ្ជីពិនិត្យឃើញថា ឯកសារថតចម្លដែលមានសេចក្តីបញ្ជាក់នៃសៀវភៅគោលបញ្ជីដីធ្លី ឬសៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ ឬ

---

[៧៧] ប្រកាសអន្តរក្រសួងលេខ ៥៩ ប្រក.ដ.ន.ស/១១ ស្តីពីការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី,ប្រការ៤,ប្រការ២។

[៧៨] ប្រកាសអន្តរក្រសួងលេខ ៥៩ ប្រក.ដ.ន.ស/១១ ស្តីពីការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី,ប្រការ៧។

[៧៩] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១,០៦ កក្កដា ២០០៦, មាត្រា៤២០ កថាខណ្ឌទី២ និងប្រកាសអន្តរក្រសួងលេខ ៥៩ ប្រក.ដ.ន.ស/១១ ស្តីពីការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី,០៣ ឧសភា ២០១១ ប្រការ៣៨។

សៀវភៅចុះបញ្ជីផលុបភោគ ដែលត្រូវបានផ្ញើមកក្រឡាបញ្ជី មានចំណុចខ្វះ ឬចំណុចដែលមិនត្រឹមត្រូវ ឬ ការសរសេរខុសខ្ទង់ជាអាទិ៍ ក្រឡាបញ្ជីអាចឱ្យរដ្ឋបាលសុរិយោដីរាជធានី/ខេត្ត ធ្វើការកែតម្រូវឱ្យបានត្រឹមត្រូវឡើងវិញបាន។ ក្រោយពីរដ្ឋបាលសុរិយោដីរាជធានី/ខេត្ត បានកែតម្រូវរួចហើយ បញ្ញត្តិនៃប្រការ ៣៨ ក៏ត្រូវយកមកអនុវត្តដូចគ្នាផងដែរ។[៨០]

### ២.៤.២.១. អានុភាពនៃការរឹបអូស

អានុភាពនៃការរឹបអូស នឹងកើតឡើងនៅពេលបញ្ជូល ដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំទៅកូនបំណុលនៃការអនុវត្ត និង ពេលចុះបញ្ជីអំពីការរឹបអូស។[៨១] ប៉ុន្តែក្នុងការអនុវត្តជាក់ស្តែង ក្រោយពីការចុះបញ្ជីអំពីការរឹបអូសរួចរាល់សិន ទើបមានការបញ្ជូនដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំទៅកូនបំណុល។ ដោយហេតុថា ប្រសិនបើបញ្ជូនដីកាសម្រេចចាប់ផ្ដើមលក់ទៅកូនបំណុលមុននោះអាចនឹងមានហានិភ័យ កើតឡើងដោយកូនបំណុលអាចធ្វើអនុប្បទាននូវអចលនវត្ថុនោះទៅឱ្យតតិយជនមុន។ ដូច្នេះជននោះអាចនឹងទទួលបានការចុះបញ្ជីកម្មសិទ្ធិបានមុនការចុះបញ្ជីរឹបអូស។

អានុភាពនៃការរឹបអូស មានទៅលើអចលនវត្ថុដែលកម្មវត្ថុនោះ ព្រមទាំងលើវត្ថុដែលភ្ជាប់នឹងអចលនវត្ថុ (**អាគារ និង ដើមឈើលើដី**) និងជាផ្នែកមួយនៃអចលនវត្ថុនោះ ព្រមទាំងវត្ថុចំណុះ(**គ្រឿងសាងសង់ ក្នុងករណីការរឹបអូសអាគារដែលបានចុះបញ្ជី**) និងសិទ្ធិចំណុះ (**សេវភាពនៃដីដែលនៅជាប់គ្នា ដែលជាសិទ្ធិរបស់កូនបំណុលក្នុងនាមជាកម្មសិទ្ធិករនៃដីនោះ**) នៃអចលនវត្ថុផងដែរ។[៨២]

### ២.៤.២.២. ការហាមឃាត់មិនឱ្យធ្វើការចាត់ចែក

នៅក្នុងការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ អានុភាពចម្បងនៃការរឹបអូស គឺការហាមឃាត់មិនឱ្យធ្វើការចាត់ចែង។ នៅខណៈពេលដែលការរឹបអូសបង្កើតអានុភាពដោយតាមរយៈការបញ្ជូនដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំ ទៅកូនបំណុលនៃការអនុវត្ត ឬ ដោយការចុះបញ្ជីអំពីការរឹបអូស នោះកូនបំណុលនឹងបាត់បង់សិទ្ធិចាត់ចែងនូវអចលនវត្ថុដែលជាកម្មវត្ថុ ហើយអាជ្ញាធររដ្ឋទទួលបាននូវសិទ្ធិចាត់ចែងនោះវិញ។

## ២.៥.ដីកាសម្រេចអំពីការកំណត់ពេលចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែក

ក្នុងករណីដែលអានុភាពនៃការរឹបអូស ដោយផ្អែកលើដីកាសម្រេចចាប់ផ្ដើមលក់ដោយបង្ខំ បានកើតឡើងតុលាការអនុវត្តត្រូវ កំណត់ពេលចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែក ដោយគិតពិចារណានូវ

---

[៨០] ប្រកាសអន្តរក្រសួងលេខ ៥៩ ប្រក.ដ.ន.ស/១១ ស្តីពីការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី,ប្រកាស៣៩។

[៨១] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/0៧០៦/0២១,០៦ កក្កដា ២០០៦, មាត្រា៤២១ កថាខណ្ឌទី២។

[៨២] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/0៧០៦/0២១,០៦ កក្កដា ២០០៦, មាត្រា៤២១ កថាខណ្ឌទី១។

អំឡុងពេលចាំបាច់ដើម្បីធ្វើឯកសារលំអិតអំពីវត្ថុ លើកលែងតែករណីដែលបានចេញដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំត្រួតគ្នា។[៨៣] ដោយហេតុថាដីកានេះមានគោលបំណងដើម្បីជូនដំណឹងដល់ម្ចាស់បំណុលដែលពាក់ព័ន្ធ អំពីពេលវេលាជាក់លាក់ដើម្បីដាក់ពាក្យសុំទាមទារឱ្យចែកចំណែក។ ប៉ុន្តែក្នុងករណីម្ចាស់បំណុលផ្សេងទៀតមានការធ្វេសប្រហែស មិនបានដាក់ពាក្យសុំឱ្យបែងចែកចំណែកក្នុងអំឡុងពេលដែលបានកំណត់ទេ មានន័យថាម្ចាស់បំណុលនោះបានបោះបង់ចោលសិទ្ធិរបស់ខ្លួនក្នុងការទាមទារឱ្យចែកចំណែក។

ម្យ៉ាងទៀត ប្រសិនបើមិនបានចេញដីកាសម្រេចអនុញ្ញាតឱ្យលក់នៅក្នុងអំឡុងពេល ៣ខែ គិតចាប់ពីពេលកំណត់ចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែកទេ តុលាការអនុវត្តអាចផ្លាស់ប្តូរពេលកំណត់ចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែក។[៨៤] ក្នុងករណីតុលាការអនុវត្តធ្វើការពន្យាពេលកំណត់ចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែកជាថ្មី តុលាការអនុវត្តត្រូវធ្វើការប្រកាសជាសាធារណៈអំពីកាលបរិច្ឆេទពន្យាពេលនេះ។

សូមបញ្ជាក់ផងដែលថាក្នុងការចេញដីកាសម្រេចកំណត់ពេលចុងក្រោយសម្រាប់ ការទាមទារឱ្យចែកចំណែកនេះតុលាការអនុវត្តអាចចេញមុនដីកាបង្គាប់ឱ្យវាយតម្លៃ ឬក្រោយចេញដីកាបង្គាប់ឱ្យវាយតម្លៃ គឺអាស្រ័យទៅលើនីតិវិធីរបស់តុលាការនីមួយៗ។

### ២.៥.១. ការប្រកាសជាសាធារណៈអំពីការកំណត់ពេលចុងក្រោយសម្រាប់ការទាមទារ

បន្ទាប់ពីតុលាការអនុវត្ត បានចេញដីកាសម្រេចអំពីការកំណត់ពេលចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែក ហើយតុលាការអនុវត្តត្រូវប្រកាសជាសាធារណៈអំពីការណ៍ដែលដីកាសម្រេចចាប់ផ្តើមត្រូវបានចេញ និងអំពីពេលកំណត់ចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែក ហើយត្រូវដាស់តឿនឱ្យជនដែលបានកំណត់ខាងក្រោមរាយការណ៍ទៅតុលាការអនុវត្ត។[៨៥]

### ២.៥.២. ការដាស់តឿន

ការដាស់តឿនឱ្យ រាយការណ៍ទៅតុលាការអនុវត្តអំពីអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិលើបំណុល និង មូលហេតុនិងចំនួនទឹកប្រាក់នៃសិទ្ធិនៃសិទ្ធិលើបំណុល ត្រូវធ្វើឡើងនៅពេលកំណត់ពេលចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែក។ ហើយជនដែលត្រូវដាស់តឿនមានដូចជា ម្ចាស់បំណុលដែលបានចុះបញ្ជី អំពីការរឹបអូសជាបណ្តោះ អាសន្ន នៅមុនការចុះបញ្ជីអំពីការរឹបអូសដោយផ្អែកលើដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំ

[៨៣] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១,០៦ កក្កដា ២០០៦, មាត្រា៤២២ កថាខណ្ឌទី១។

[៨៤] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១,០៦ កក្កដា ២០០៦, មាត្រា៤២២ កថាខណ្ឌទី៤។

[៨៥] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១,០៦ កក្កដា ២០០៦, មាត្រា៤២២ កថាខណ្ឌទី២។

ចំពោះអចលនវត្ថុ ម្ចាស់បំណុលដែលមានសិទ្ធិប្រាតិភោគ ដែលត្រូវបានចុះបញ្ជី នៅមុនការចុះបញ្ជីអំពីការរឹបអូស ដោយផ្អែកលើដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំដំបូងចំពោះអចលនវត្ថុ និង ស្ថាប័នដែលមានសមត្ថកិច្ចលើពន្ធដារ ឬ អាករសាធារណៈផ្សេងទៀត។[៨៦]

### ២.៥.៣. ពាក្យសុំទាមទារឱ្យចែកចំណែក

ក្រោយពីតុលាការបានចេញដីកាសម្រេចកំណត់អំពីពេលចុងក្រោយដើម្បីទាមទារឱ្យចែកចំណែក និង ធ្វើការផ្សាយជាសាធារណៈរួចហើយនោះ ជនដែលមានអត្ថិភាពនៃសិទ្ធិលើបំណុលចំពោះកូនបំណុល អាចដាក់ពាក្យសុំទាមទារឱ្យចែកចំណែកមកតុលាការ។

ម្ចាស់បំណុលផ្សេងទៀតដែលមានសិទ្ធិទាមទារឱ្យចែកចំណែកមានដូចជា៖[៨៧]

ក. ម្ចាស់បំណុលដែលមានឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត ដែលអាចអនុវត្តដោយបង្ខំបានលើកលែងតែម្ចាស់បំណុល ដែលមានសិទ្ធិប្រាតិភោគប្រត្យក្ស ដែលនឹងបន្តអត្ថិភាពក្រោយការលក់។

ខ. ម្ចាស់បំណុលដែលបានចុះបញ្ជីអំពីការរឹបអូសបណ្តោះអាសន្ន នៅក្រោយពេលចុះបញ្ជីអំពីការរឹបអូសដោយផ្អែកលើដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំ។

គ. ម្ចាស់បំណុលដែលបញ្ជាក់ដោយឯកសារថា មានឯកសិទ្ធិទូទៅ។

ដូចនេះម្ចាស់បំណុលផ្សេងទៀតដែលបានរៀបរាប់ខាងលើ ត្រូវដាក់ពាក្យសុំទាមទារតារឱ្យចែកចំណែកបន្ទាប់ពីបានដឹងអំពីសេចក្តីប្រកាសជាធារណៈខាងលើនេះ ឬនៅពេលដែលមានការជូនដំណឹងអំពីការលក់អចលនវត្ថុដោយបង្ខំរបស់កូនបំណុល។

ពាក្យសុំការទាមទារឱ្យចែកចំណែក ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ នូវមូលហេតុ និង ចំនួទឹកប្រាក់នៃសិទ្ធិលើបំណុល ដោយរួមបញ្ចូលទាំងការប្រាក់ និង សិទ្ធិលើបំណុលបន្ទាប់បន្សំ។[៨៨]

ក្នុងករណីតុលាការចេញដីកាសម្រេចលើកចោលការទាមទារឱ្យចែកចំណែក អ្នកដាក់ពាក្យសុំអាចប្តឹងជំទាស់បាន (មាត្រា ៤២៦ កថាខណ្ឌទី៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ ហើយអំឡុងពេលសម្រាប់ប្តឹងជំទាស់មានរយៈពេល ១សប្តាហ៍ ដោយគិតចាប់ពីថ្ងៃដែលទទួលបានដំណឹងអំពីការសម្រេច។

[៨៦] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១,០៦ កក្កដា ២០០៦, មាត្រា៤២២ កថាខណ្ឌទី២ ចំណុច ក ដល់ ចំណុច គ។

[៨៧] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១,០៦ កក្កដា ២០០៦, មាត្រា៤២៦ កថាខណ្ឌទី១។

[៨៨] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១,០៦ កក្កដា ២០០៦, មាត្រា៤២៦ កថាខណ្ឌទី២។

### ២.៥.៤. ការជូនដំណឹងអំពីការទាមទារឱ្យចែកចំណែក

ក្រោយពីតុលាការបានទទួលពាក្យទាមទារឱ្យចែកចំណែក តុលាការត្រូវធ្វើការជូនដំណឹងទៅបុគ្គលពីររូបគឺ ម្ចាស់បំណុលនៃការអនុវត្ត និងកូនបំណុលនៃការអនុវត្ត។ ការជូនដំណឹងនេះផងដែរ គឺមានសារៈសំខាន់ណាស់ ក្នុងគោលបំណងឱ្យបុគ្គលទាំងពីរ បានដឹងអំពីការទាមទាររបស់ម្ចាស់បំណុលផ្សេងទៀត ក្នុងការបែងចែកចំណែក ឬដើម្បីឱ្យម្ចាស់បំណុលនៃការអនុវត្ត និង កូនបំណុលនៃការអនុវត្តអាចតវ៉ាគ្នា (បណ្តឹងតវ៉ាចំពោះការទាមទារ មាត្រា ៣៦៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី) បើយល់ឃើញថា អ្នកទាមទារគ្មានសិទ្ធិទាមទារ។

## ២.៦. ដីកាសម្រេចជ្រើសតាំងអ្នកវាយតម្លៃ និងបង្គាប់ឱ្យវាយតម្លៃ

តុលាការអនុវត្តត្រូវជ្រើសតាំងអ្នកវាយតម្លៃ និងបង្គាប់ឱ្យវាយតម្លៃអចលនវត្ថុដោយផ្អែកលើកាស្រាវជ្រាវអំពីសណ្ឋានដីនៃអចលនវត្ថុ ទំនាក់ទំនងនៃការកាន់កាប់ និងស្ថានភាពបច្ចុប្បន្ន។[៤៩]

ក្នុងករណីអ្នកវាយតម្លៃបានជួបប្រទះនឹងការប្រឆាំងពេលកំពុងបំពេញមុខងារ អ្នកវាយតម្លៃអាចសុំជំនួយពីអាជ្ញាសាលាបាន។ ដោយអាជ្ញាសាលាអាចសុំជំនួយពីនគរបាល ឬកងកម្លាំងផ្សេងទៀតដែលមានសមត្ថកិច្ចដើម្បីបំបាត់នូវការប្រឆាំងនោះបាន ប៉ុន្តែការអ្នកវាយតម្លៃត្រូវសុំការអនុញ្ញាតពីតុលាការអនុវត្តមានចែងក្នុងបញ្ញត្តិមាត្រា ៤៣០ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ អ្នកវាយតម្លៃត្រូវធ្វើរបាយការណ៍ជាលាយលក្ខណ៍អក្សរជូនមកតុលាការវិញ ក្រោយពីស្រាវជ្រាវអំពីស្ថានភាពបច្ចុប្បន្ននៃអលនវត្ថុ និង ការវាយតម្លៃអចលនវត្ថុនោះ។[៥០]

ម្យ៉ាងទៀតក្នុងករណីជាក់ស្តែង ម្ចាស់បំណុលនៃការអនុវត្ត ឬមេធាវីតំណាងដោយអាណត្តិ ក៏អាចដាក់ពាក្យស្នើសុំឲ្យចាត់តាំង អ្នកវាយតម្លៃ ទៅតុលាការអនុវត្ត ដើម្បីឱ្យតុលាការពិចារណាសម្រេចជ្រើសតាំងក្រុមហ៊ុនដែលបានស្នើសុំ ឱ្យធ្វើការវាយតម្លៃអចលនវត្ថុដែលជាកម្មសិទ្ធិរបស់កូនបំណុលនៃការអនុវត្ត។ ដោយនៅក្នុងពាក្យសុំនេះទៀតសោត គប្បីបង្ហាញអំពីក្រុមហ៊ុនវាយតម្លៃអចលនវត្ថុ ដែលមានការទទួលស្គាល់ជាស្តង់ដា ដែលអាចធ្វើឲ្យតុលាការ និងកូនបំណុលនៃការអនុវត្តទទួលយកបាន។ ម្យ៉ាងវិញទៀត ក្នុងពាក្យសុំគប្បីសរសេរចំណុចមួយចំនួនដូចជាៈ ឈ្មោះ និងអាសយដ្ឋានរបស់ម្ចាស់បំណុល ឬមេធាវីតំណាងដោយអាណត្តិ ឈ្មោះក្រុមហ៊ុនវាយតម្លៃអចលនវត្ថុ អាសយដ្ឋាន លេខទូរស័ព្ទ ជាដើម។ អ្នកវាយតម្លៃត្រូវធ្វើរបាយការណ៍ជា

[៤៩] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១,០៦ កក្កដា ២០០៦, មាត្រា៤៣០ កថាខណ្ឌទី១។

[៥០] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១,០៦ កក្កដា ២០០៦, មាត្រា៤៣០ កថាខណ្ឌទី៥។

លាយលក្ខណ៍អក្សរជូនមកតុលាការវិញ ក្រោយពីស្រាវជ្រាវអំពីស្ថានភាពនច្ចុប្បន្ននៃអលនវត្ថុ និង ការវាយតម្លៃអចលនវត្ថុនោះ។[៩១]

ក្រោយពីទទួលបានពាក្យសុំឱ្យចេញដីកាសម្រេចជ្រើសតាំងអ្នកវាយតម្លៃរបស់ម្ចាស់បំណុលនៃការអនុវត្ត ឬមេធាវីតំណាងដោយអាណត្តិរួចមក តុលាការនឹងពិនិត្យមើលថា តើក្រុមហ៊ុនដែលម្ចាស់បំណុលនៃការអនុវត្តឬមេធាវីតំណាងដោយអាណត្តិដាក់ពាក្យសុំនេះជាក្រុមហ៊ុនដែលមានការទទួលស្គាល់ច្បាស់លាស់អាចទទួលយកបានដែរ ឬ ទេ?។ ដូចនេះក្រោយពីការពិចារណារបស់តុលាការ ប្រសិនបើតុលាកាយល់ឃើញថាអាចទទួលយកតាមការស្នើសុំបាន នោះតុលាការនឹងចេញដីកាសម្រេចជ្រើសតាំងក្រុមហ៊ុនឱ្យវាយតម្លៃតែម្តង។ ប៉ុន្តែក្នុងករណីតុលាការយល់ឃើញថាក្រុមហ៊ុនដែលបានស្នើសុំនេះ មិនអាចទទួលយកបាននោះតុលាការអាចជ្រើសរើសក្រុមហ៊ុនផ្សេងទៀតដែលមានជំនាញតាមឆន្ទានុសិទ្ធិរបស់តុលាការ ដើម្បីទទួលបានសិទ្ធិក្នុងការវាយតម្លៃ អលនវត្ថុនោះ។

## ២.៧.ដីកាបង្គាប់ឱ្យស្រាវជ្រាវអំពីស្ថានភាពបច្ចុប្បន្ននៃអចលនវត្ថុ

ដីកាបង្គាប់ឱ្យស្រាវជ្រាវអំពីស្ថានភាពបច្ចុប្បន្ននៃអចលនវត្ថុ ត្រូវបានចេញបន្ទាប់ពីដីកាសម្រេចចាប់ផ្តើមលក់ដោយបង្ខំ មានអានុភាព។ បើយល់ឃើញថាចាំបាច់ក្នុងការចេញឯកសារលំអិត តុលាការអនុវត្តអាចបង្គាប់ឱ្យអាជ្ញាសាលាស្រាវជ្រាវអំពីស្ថានភាពបច្ចុប្បន្ននៃអចលនវត្ថុដូចជា សណ្ឋាននៃអចលនវត្ថុ ស្ថានភាពនៃការកាន់កាប់ ឬចនាសម្ព័ន្ធអាគារ ជាអាទិ៍ ហើយរាយការណ៍ដែលជាលទ្ធផលនៃការស្រាវជ្រាវនោះអាជ្ញាសាលាត្រូវធ្វើជាលាយលក្ខណ៍អក្សរ។[៩២]

នៅក្នុងដីកាសម្រេចឱ្យស្រាវជ្រាវអំពីស្ថានភាពបច្ចុប្បន្ននៃអចលនវត្ថុនេះ ត្រូវបញ្ជាក់ឱ្យច្បាស់អំពីអត្តសញ្ញាណដីនៃអចលនវត្ថុដែលជាកម្មវត្ថុ និង ភាគីនៃការអនុវត្ត។ អាជ្ញាសាលាអាចចូលទៅកាន់អចលនវត្ថុ ឬអាចសួរសំណួរ ឬទាមទារឱ្យបង្ហាញឯកសារ ចំពោះកូនបំណុលនៃការអនុវត្ត ឬ តតិយជនដែលកាន់កាប់អចលនវត្ថុនោះបាន។[៩៣] បន្ថែមពីនេះទៅទៀត អាជ្ញាសាលាអាចធ្វើការចាត់ចែង ដើម្បីបើកទ្វារដែលបាន

---

[៩១] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១,០៦ កក្កដា ២០០៦, មាត្រា៤៣០ កថាខណ្ឌទី៥។

[៩២] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១,០៦ កក្កដា ២០០៦, មាត្រា៤៣៤ កថាខណ្ឌទី២។

[៩៣] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១,០៦ កក្កដា ២០០៦, មាត្រា៤៣៤ កថាខណ្ឌទី៣ វាក្យខណ្ឌទី១។

បិទបាន។[៩៤] ក្នុងករណី មានការប្រឆាំងនៅពេលបំពេញមុខនាទីរបស់ខ្លួន អាជ្ញាសាលាអាចប្រើកម្លាំង ឬ អាចសុំជំនួយពីនគរបាល ឬ កងកម្លាំងផ្សេងទៀតដែលមានសមត្ថកិច្ច ដើម្បីបំបាត់នូវការប្រឆាំងនោះបាន។[៩៥]

ក្រោយពីស្រាវជ្រាវរួចរាល់ អាជ្ញាសាលាត្រូវធ្វើរបាយការណ៍ជាលាយលក្ខណ៍អក្សរនូវលទ្ធផលនៃការស្រាវជ្រាវអំពីស្ថានភាពបច្ចុប្បន្ននៃអចលនវត្ថុ តាមរយៈដីកាបញ្ជូន ទៅតុលាការអនុវត្តវិញឱ្យបានឆាប់រហ័សតាមដែលអាចធ្វើបាន។

## ២.៨. ការលក់ដោយបង្ខំចំពោះអចលនវត្ថុ

### ២.៨.១. លក្ខខណ្ឌនៃការលក់ដោយបង្ខំចំពោះអចលនវត្ថុ

នៅក្នុងលក្ខខណ្ឌនៃការលក់ដោយបង្ខំចំពោះអចលនវត្ថុមានពីរយ៉ាងគឺ **លក្ខខណ្ឌនៃការលក់ដែលច្បាប់កំណត់** និង **លក្ខខណ្ឌពិសេសនៃការលក់**។

#### ២.៨.១.១. លក្ខខណ្ឌនៃការលក់ដែលច្បាប់កំណត់

លក្ខខណ្ឌនៃការលក់ដែលច្បាប់កំណត់ មានដូចជា៖

- ការហាមឃាត់ការលក់ក្នុងតម្លៃថោកជាងតម្លៃលក់អប្បបរមាមានន័យថា អចលនវត្ថុដែលជាកម្មវត្ថុនៃការលក់ដោយបង្ខំ ដែលត្រូវបានអ្នកវាយតម្លៃធ្វើការវាយតម្លៃអចលនវត្ថុនោះ នៅក្នុងតម្លៃណាមួយ គឺតុលាការមិនអាចលក់ក្រោយតម្លៃកំណត់នោះបានទេ លើកលែងតែគ្មានអ្នកទិញ ទើបតុលាការមានឆន្ទានុសិទ្ធិក្នុងការបញ្ចុះតម្លៃបាន។ បើយល់ឃើញថាចាំបាច់ តុលាការអនុវត្តអាចផ្លាស់ប្តូរតម្លៃលក់អប្បរមាបាន។[៩៦] ឧទាហរណ៍ ក្រុមហ៊ុនវាយតម្លៃអចលនវត្ថុ បានវាយតម្លៃអចលនវត្ថុមួយកន្លែង ដែលមានតម្លៃចំនួន USD ៥០.០០០ (ប្រាំម៉ឺនដុល្លារអាមេរិក) ដូច្នេះ តុលាការអាចលក់ក្នុងតម្លៃនេះបាន ប៉ុន្តែមិនអាចលក់ក្រោមតម្លៃនេះបានទេ។
- ការទទួលបន្ត និង ការរលត់បន្ទុកចំពោះអចលនវត្ថុ មានន័យថា ការទទួលបន្ត គឺជាការទទួលបន្តនូវសិទ្ធិប្រាតិភោគប្រត្យក្ស សិទ្ធិប្រត្យក្សប្រើប្រាស់និងអាស្រ័យផល និងសិទ្ធិជួលដែលមានលើអចលនវត្ថុនោះ ត្រូវបន្តអត្ថិភាពនៅក្រោយការលក់។ ចំពោះការរលត់សិទ្ធិវិញ គឺរលត់ទៅលើសិទ្ធិនៃការរឹបអូស

---

[៩៤] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១,០៦ កក្កដា ២០០៦, មាត្រា៤៣៤ កថាខណ្ឌទី៣ វាក្យខណ្ឌទី២។

[៩៥] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១,០៦ កក្កដា ២០០៦, មាត្រា៣៣៨ កថាខណ្ឌទី១។

[៩៦] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១,០៦ កក្កដា ឆ្នាំ២០០៦, មាត្រា៤៣២ កថាខណ្ឌទី២។

និងការអនុវត្តការចាត់ចែងជាបណ្តោះអាសន្ន ត្រូវបាត់បង់អានុភាពដោយសារការលក់។[៩៧]

- ការលក់សរុប មានន័យថា តុលាការអាចធ្វើការលក់អចលនវត្ថុដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំត្រូវធ្វើឡើងចំពោះតែអចលនវត្ថុនីមួយៗដាច់ដោយឡែកពីគ្នា។ ប៉ុន្តែក្នុងករណីមានអចលនវត្ថុច្រើន ហើយអ្នកទិញស្នើសុំទិញសរុប តុលាការអាចលក់សរុបបាន លុះត្រាតែការយល់ព្រមពីកូនបំណុលនៃការអនុវត្ត។[៩៨]
- ករណីយកិច្ចរបស់អ្នកស្នើសុំទិញ មានន័យថា ដើម្បីធានាលើការទិញ ឬតម្លៃទិញ អ្នកទិញត្រូវដាក់ប្រាក់ធានាដែលមានចំនួនស្មើនឹងចំនួន ១ភាគ១០ នៃតម្លៃលក់អប្បបរមា។[៩៩]
- ការបង់ថ្លៃលក់ និងរយៈពេលផ្ទេរ មានន័យថា ដើម្បីមានអានុភាពនៃការលក់ លុះត្រាតែតុលាការបានចេញដីកាសម្រេចអនុញ្ញាតឲ្យលក់ជាស្ថាពរ អ្នកទិញត្រូវបង់ថ្លៃលក់ទៅតុលាការអនុវត្តឲ្យបានមុនពេលកំណត់។ ក្រោយពីអ្នកទិញបានបង់ប្រាក់ជូនតុលាការគ្រប់ចំនួន តុលាការត្រូវធ្វើការផ្ទេរតាមរយៈលិខិតផ្ទុកផ្តាក់។[១០០]

#### ២.៨.១.២. លក្ខខណ្ឌពិសេសនៃការលក់

លក្ខខណ្ឌពិសេសនៃការលក់ គឺជាលក្ខខណ្ឌនៃការលក់ផ្សេងពីការលក់តាមលក្ខខណ្ឌដែលច្បាប់បានកំណត់ ក្នុងករណីបុគ្គលដែលពាក់ព័ន្ធនឹងផលប្រយោជន៍មានការព្រមព្រៀងគ្នាផ្សេងពីបញ្ញត្តិនៃច្បាប់ ហើយបានរាយការណ៍អំពីការព្រមព្រៀងនោះ ទៅតុលាការអនុវត្ត នៅមុនពេលដែលចេញ ដីកាសម្រេចកំណត់តម្លៃលក់អប្បបរមា នោះលក្ខខណ្ឌដែលច្បាប់កំណត់ នឹងត្រូវបានផ្លាស់ប្តូរទៅតាមការព្រមព្រៀងនោះ។[១០១]

### ២.៨.២. ដីកាសម្រេចកំណត់តម្លៃអប្បបរមា

តុលាកាអនុវត្ត ត្រូវកំណត់តម្លៃលក់អប្បបរមា ដោយផ្អែកលើការវាយតម្លៃរបស់អ្នកវាយតម្លៃ។[១០២] ដូច្នេះក្រោយពីតុលាការអនុវត្តបានទទួលរបាយការណ៍ស្តីពីលទ្ធផលនៃការវាយតម្លៃពីអ្នកជំនាញ លទ្ធផលស្រាវជ្រាវ

---

[៩៧] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១,០៦ កក្កដា ឆ្នាំ២០០៦, មាត្រា៤៣១។

[៩៨] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១,០៦ កក្កដា ឆ្នាំ២០០៦, មាត្រា៤៣៣។

[៩៩] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១,០៦ កក្កដា ឆ្នាំ២០០៦, មាត្រា៤៣៧ កថាខណ្ឌទី១។

[១០០] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១,០៦ កក្កដា ឆ្នាំ២០០៦, មាត្រា៤៤៨។

[១០១] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, *សេចក្តីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណី, ភាគ២, ការអនុវត្តដោយបង្ខំ និងការចាត់ចែងរក្សាការពារ (ភ្នំពេញ៖ ក្រសួងយុត្តិធម៌) ១១០*។

[១០២] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១,០៦ កក្កដា ឆ្នាំ២០០៦, មាត្រា៤៣២ កថាខណ្ឌទី១។

ស្ថានភាពបច្ចុប្បន្ននៃអចលនវត្ថុ និង ធ្វើឯកសារលំអិតអំពីវត្ថុរួចរាល់ តុលាការអនុវត្តត្រូវចេញ ដីកាសម្រេចកំណត់ថ្លៃលក់អប្បបរមា។ ដោយនៅក្នុងដីកានេះ នឹងមានកំណត់អំពី តម្លៃលក់អប្បបរមា ដែលក្រុមហ៊ុនវាយតម្លៃ បានវាយតម្លៃសម្រាប់ការលក់ដោយបង្ខំ និង ប្រាក់ធានាលើសំណើទិញ។

វិធានការដែលតុលាការអនុវត្តត្រូវធ្វើ ក្នុងករណីដែលតម្លៃលក់អប្បបរមានៃអចលនវត្ថុ ក្រោយពីបានសងសោហ៊ុយសម្រាប់ការអនុវត្តនីតិវិធីហើយ គ្មានលទ្ធផលសល់ទេនោះ តុលាការអនុវត្តត្រូវជូនដំណឹង ទៅឱ្យម្ចាស់បំណុលនៃការអនុវត្ត។[១០៣] ជាគោលការណ៍ប្រសិនបើយល់ឃើញថា តម្លៃប៉ាន់ប្រមាណនៃសោហ៊ុយសម្រាប់នីតិវិធីនោះ ច្រើនជាងតម្លៃលក់អប្បបរមា តុលាការអនុវត្តត្រូវលុបចោលនូវនីតិវិធីនៃការលក់ដោយបង្ខំ។

## ២.៨.៣. ការរៀបចំឯកសារលំអិតអំពីអចលនវត្ថុ

បន្ទាប់ពីបានកំណត់តម្លៃអប្បបរមាហើយ តុលាការអនុវត្តត្រូវធ្វើឯកសារលំអិតអំពីវត្ថុ ហើយត្រូវទុកឯកសារលំអិតអំពីវត្ថុនោះ នៅតុលាការអនុវត្តជាមួយគ្នានឹងឯកសារចម្លងនៃរបាយការណ៍វាយតម្លៃ ដើម្បីឱ្យសាធារណៈជនបានមើល។ ហើយនៅក្នុងឯកសារលំអិតនេះ ត្រូវសរសេរចំណុចដូចជា សញ្ញាណនៃអចលនវត្ថុ សិទ្ធិលើអចលនវត្ថុដែលនឹងបន្ត អត្ថិភាពក្រោយការលក់ និងការអនុវត្តការចាត់ចែងជាបណ្តោះអាសន្នដែលមិនបាត់បង់អានុភាពដោយការលក់។[104] គោលបំណងនៃការរៀបចំឯកសារលំអិតអំពីវត្ថុ និងរបាយការណ៍វាយតម្លៃ គឺដើម្បីទុកឱ្យសាធារណៈជនមើល និងដើម្បីផ្តល់ព័ត៌មានស្តីពីអចលនវត្ថុដល់អ្នកដែលមានបំណងចង់ចូលរួមដេញថ្លៃ។

## ២.៨.៤.ដីកាបង្គាប់ឱ្យអនុវត្តការលក់

ប្រសិនបើលក់តាមវិធីលក់ឡាយឡុងដោយស្រោមសំបុត្រ តុលាការអនុវត្ត ត្រូវកំណត់កាលបរិច្ឆេទ និងទីកន្លែងលក់ ហើយត្រូវឱ្យអាជ្ញាសាលាអនុវត្តការលក់នោះ។[១០៥]

បន្ទាប់ពីតុលាការអនុវត្តបានចេញដីកាសម្រេចកំណត់តម្លៃលក់អប្បបរមារួចហើយ តុលាការអនុវត្តត្រូវចេញដីកាបង្គាប់ឱ្យអនុវត្តការលក់ ដែលនៅក្នុងដីកាបង្គាប់នេះទៀតសោត មានខ្លឹមសារកំណត់ពី៖ វិធីលក់ កាលបរិច្ឆេទនៃការលក់ ទីកន្លែងលក់ តម្លៃលក់អប្បបរមា ប្រាក់ធានាលើសំណើរទិញ ជាអាទិ៍។ ដោយបង្គាប់ឱ្យអាជ្ញាសាលាអនុវត្តការលក់អចលនវត្ថុដោយបង្ខំ ។

---

[១០៣] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១,០៦ កក្កដា ឆ្នាំ២០០៦, មាត្រា៤៣៥ កថាខណ្ឌទី១។

[១០៤] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១,០៦ កក្កដា ឆ្នាំ២០០៦, មាត្រា៤៣៤។

[១០៥] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១,០៦ កក្កដា ឆ្នាំ២០០៦, មាត្រា៤៣៦ កថាខណ្ឌទី៣។

សូមបញ្ជាក់ផងដែរថា ក្រោយពីបានចេញដីកាទាំងពីរខាងលើនេះមក ក្រឡាបញ្ជីត្រូវជូនដំណឹងដល់ភាគីដែលជនដែលពាក់ព័ន្ធទាំងអស់ឲ្យបានដឹងអំពីការលក់នេះ។

### ២.៨.៥. ការផ្សាយជាសាធារណៈអំពីកាលបរិច្ឆេទនៃការលក់

បន្ទាប់ពីតុលាការបានចេញដីកាបង្គាប់ឲ្យអនុវត្តការលក់ ក្រឡាបញ្ជីនៃតុលាការត្រូវផ្សព្វផ្សាយជាសាធារណៈអំពីការលក់ឡាយឡុងដោយស្រោមសំបុត្រ ដោយបញ្ជាក់នូវអត្តសញ្ញាណនៃអចលនវត្ថុដែលត្រូវលក់ តម្លៃលក់អប្បបរមា កាលបរិច្ឆេទលក់ ទីកន្លែងលក់ ព្រមទាំងព័ត៌មានផ្សេងៗទៀត។[១០៦] ការផ្សាយជាសាធារណៈអាចធ្វើបានតាម រយៈការបិតនៅក្តារព័ត៌មានរបស់តុលាការ ឬផ្សព្វផ្សាយតាមវេបសាយរបស់សាលាដំបូង។ ដែលជានីតិវិធីមួយដែលប្រកាសឱ្យអ្នកស្នើសុំទិញ មកទិញអចលនវត្ថុ។

### ២.៨.៦. ពាក្យសុំផ្តល់សំណើរទិញ

ពាក្យសុំផ្តល់សំណើរទិញ បន្ទាប់ផ្សាយជាសាធារណៈបុគ្គលដែលមានបំណងចង់ទិញអចលនវត្ថុតាមរយៈការដេញថ្លៃ អាចដាក់ពាក្យស្នើសុំទិញបាន។ ប៉ុន្តែដើម្បីក្លាយជាអ្នកទិញបាន លុះត្រាតែឆ្លងកាត់ការត្រួតពិនិត្យអំពីលក្ខខណ្ឌ និងលក្ខណៈសម្បត្តិ ដោយអាជ្ញាសាលាជាមុនសិន។ ក្នុងករណីអាជ្ញាសាលាយល់ឃើញថា បុគ្គលនោះមានលក្ខខណ្ឌ និង លក្ខណៈសម្បត្តិគ្រប់គ្រាន់ហើយ ទើបអាជ្ញាសាលាអនុញ្ញាតឱ្យចេញថ្លៃ។ ក្រោយពីបានដឹកនាំការដេញថ្លៃ និង ធ្វើកំណត់ហេតុដេញថ្លៃរួចហើយ អាជ្ញាសាលានឹងបញ្ជូនសំណុំរឿង និង ឯកសារពាក់ព័ន្ធទៅតុលាការអនុវត្តវិញ ដើម្បីចាត់ការតាមនីតិវិធីជាបន្តបន្ទាប់។

### ២.៨.៧. កិច្ចនីតិវិធីលក់របស់អាជ្ញាសាលា

បន្ទាប់ពីបានទទួលពាក្យស្នើទិញរួចមក អាជ្ញាសាលាត្រូវតម្រូវឲ្យអ្នកទិញដាក់ប្រាក់ធានាដែលមានចំនួនស្មើនឹង ១ ភាគ១០ នៃតម្លៃអប្បបរមា ។ ក្នុងករណី ការលក់ឡាយឡុងដោយស្រោមសំបុត្រ ឬដោយផ្ទាល់មាត់បានបញ្ចប់ អាជ្ញាសាលាត្រូវប្រកាសការបញ្ចប់កាលបរិច្ឆេទនៃការលក់ឡាយឡុង។ ក្រោយពេលបានកំណត់អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ត្រូវបានប្រកាសនូវនាម ឬនាមករណ៍របស់អ្នកទិញ និងតម្លៃលក់ឡាយឡុងនោះ។

ដោយយកអ្នកដេញថ្លៃខ្ពស់ជាងគេ ដើម្បីទិញកម្មវត្ថុនៃការលក់ឡាយឡុង។ ក្នុងករណី ដែលមានអ្នកដេញថ្លៃច្រើននាក់ ក្នុងតម្លៃអតិបរមាស្មើគ្នា គឺអ្នកស្នើសុំទិញក្នុងតម្លៃអតិបរមាស្មើគ្នាត្រូវដេញថ្លៃម្តងទៀត ដោយ

[១០៦] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១,០៦ កក្កដា ឆ្នាំ២០០៦, មាត្រា៤៣៦ កថាខណ្ឌទី៤។

អាចដេញក្នុងតម្លៃទិញជាតម្លៃដែលខ្លួនបានដេញពីមុនឡើយ។ ផ្ទុយមកវិញ ក្នុងករណីអ្នកស្នើសុំទិញក្នុងតម្លៃអតិបរមាស្មើគ្នា មិនព្រមដេញថ្លៃម្តងទៀត គឺត្រូវកំណត់ដោយចាប់ឆ្នោត។[១០៧] បន្ទាប់ពីអនុវត្តការលក់រួច អាជ្ញាសាលាត្រូវធ្វើកំណត់ហេតុស្តីពីការអនុវត្តការលក់ ដាក់ជូនតុលាការអនុវត្តភ្លាម ហើយត្រូវសរសេរកំណត់ហេតុនេះ នូវចំណុចមួយចំនួន ដូចជា៖

- សញ្ញាណអចលនវត្ថុ
- កាលបរិច្ឆេទនៃការលក់ឡាយឡុងដោយស្រោមសំបុត្រ
- សញ្ញាណរបស់អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា និងអ្នកតំណាង
- សញ្ញាណរបស់អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា និងអ្នកតំណាង
- តម្លៃទិញរបស់អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា
- ហេតុការណ៍ និងស្ថានភាពបើមិនអាចកំណត់អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា
- ស្ថានភាពរក្សាសណ្តាប់ធ្នាប់នៅកន្លែងលក់
- និងត្រូវចុះហត្ថលេខាអ្នកស្នើសុំទិញ និងអ្នកតំណាង លើកំណត់ហេតុនោះ។[១០៨]

**សូមបញ្ជាក់ផងដែរថា** ការស្នើសុំទិញនូវអចលនវត្ថុដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ ក៏ត្រូវបានហាមឃាត់ចំពោះបុគ្គលមួយចំនួនដូចជា៖

- បុគ្គលដែលគ្មានសមត្ថភាព ក្នុងការធ្វើសកម្មភាពដែលបានកំណត់ក្នុងក្រមរដ្ឋប្បវេណី មានដូចជា អនីតិជន ជននៅក្រោមអាណាព្យាបាលទូទៅ ជននៅក្រោមហិតូបត្ថម្ភ និងបុគ្គលដែលខ្វះសមត្ថភាពខាងឆន្ទៈ
- អ្នកគ្រប់គ្រងទ្រព្យសម្បត្តិតាមច្បាប់ តាមផ្លូវតុលាការ ឬតាមកិច្ចសន្យា ឬតាមរយៈអន្តរការី
- មន្ត្រីរាជការដែលទទួលបន្ទុកគ្រប់គ្រង ឬលក់
- ចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី អាជ្ញាសាលា ឬមន្ត្រីតុលាការផ្សេងៗទៀត
- មេធាវី ឬសារការី
- កូនបំណុលនៃការអនុវត្ត
- បុគ្គលដែលអាជ្ញាសាលាមិនអនុញ្ញាតឲ្យដាក់សំណើទិញ ដោយសារបានធ្វើសកម្មភាពរំខាន[១០៩]

[១០៧] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១,០៦ កក្កដា ឆ្នាំ២០០៦, មាត្រា៤៣៩ កថាខណ្ឌទី២។

[១០៨] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១,០៦ កក្កដា ឆ្នាំ២០០៦, មាត្រា៤៣៩ កថាខណ្ឌទី៤។

[១០៩] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១,០៦ កក្កដា ឆ្នាំ២០០៦, មាត្រា៤៣៦ កថាខណ្ឌទី៥។

- អ្នកទិញដោយបង្ខំលើកទី១ ដែលមិនបានបង់ថ្លៃលក់[១១០]

## ២.៩. ការអនុញ្ញាតឱ្យលក់

ការអនុញ្ញាតឲ្យលក់នេះ មានបីដំណាក់កាល គឺកាលបរិច្ឆេទដើម្បីចេញដីកាសម្រេចការលក់ ការថ្លែងការណ៍អំពីការលក់ និងដីកាសម្រេចអនុញ្ញាត ឬមិនអនុញ្ញាតឲ្យលក់។

### ២.៩.១. ការបរិច្ឆេទដើម្បីចេញដីកាសម្រេចការលក់

ក្រោយពីទទួលបានសំណុំឯកសារដេញថ្លៃពីអាជ្ញាសាលារួចហើយ តុលាការអនុវត្ត និងចេញដីកាសម្រេចអនុញ្ញាត ឬមិនអនុញ្ញាតឲ្យលក់ទៅបុគ្គលដែលបានដេញថ្លៃក្នុងតម្លៃអតិបរមា ដែលអាជ្ញាសាលាបានកំណត់នៅក្នុងកាលបរិច្ឆេទនៃការលក់ បើកាលបរិច្ឆេទដើម្បីចេញដីកាសម្រេចឲ្យអនុញ្ញាតការលក់ និងស្តាប់សេចក្តីថ្លែងការណ៍របស់បុគ្គលដែលពាក់ព័ន្ធនឹងផលប្រយោជន៍។ ជាពិសេស តុលាការអនុវត្ត ត្រូវជូនដំណឹងទៅបុគ្គលដែលពាក់ព័ន្ធ អំពីកាលបរិច្ឆេទនោះ។ ក្នុងករណី ដែលបុគ្គលពាក់ព័ន្ធនឹងផលប្រយោជន៍ មិនសុខចិត្តនិងដីកាសម្រេចនោះអាចធ្វើការប្តឹងជំទាស់បាន លុះត្រាតែដីកាសម្រេចនោះបណ្តាលឱ្យខូចខាតដល់សិទ្ធិខ្លួន។[១១១] ក្រោយពីដីកាសម្រេចអនុញ្ញាតឲ្យលក់ចូលជាស្ថាពរហើយ ទើបតុលាការចេញ ដីកាសម្រេចអំពីអំឡុងពេលសម្រាប់បង់ថ្លៃលក់ ឲ្យទៅអ្នកទិញ ដើម្បីមកបង់ប្រាក់ឲ្យគ្រប់ចំនួន។[១១២] ហើយដីកានេះនឹងត្រូវបញ្ជូនទៅឲ្យអ្នកទិញតាមរយៈរបាយការណ៍បញ្ជូន។ សូមបញ្ជាក់ផងដែរថា ក្នុងការបញ្ជូនដីកាសម្រេចអំពីអំឡុងពេលសម្រាប់បង់ថ្លៃលក់ គឺពុំមានមាត្រាណាមួយដែលបញ្ញត្តិឲ្យច្បាស់លាស់នោះទេ គ្រាន់តែមានបញ្ញត្តិអំពីការជូនដំណឹងដីកាសម្រេចអនុញ្ញាតឲ្យលក់ទៅអ្នកទិញតែប៉ុណ្ណោះ។[១១៣] ហេតុដូច្នេះ យើងអាចបកស្រាយបានថា ការបញ្ជូន ដីកាសម្រេចអំពីអំឡុងពេលសម្រាប់បង់ថ្លៃលក់ អាចយកមាត្រា ៤៧៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី មកអនុវត្តបាន។

### ២.៩.២. សេចក្តីថ្លែការណ៍អំពីការលក់

បន្ទាប់ពីទទួលបានដីកាសម្រេចអនុញ្ញាតឲ្យលក់ហើយ ជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍ ដែលបានបង្ហាញខ្លួនអាចថ្លែងយោបល់ចំពោះការអនុញ្ញាត ឬមិនអនុញ្ញាតឲ្យលក់អចលនវត្ថុនោះ ដោយផ្អែកលើហេតុ

[១១០] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១,០៦ កក្កដា ឆ្នាំ២០០៦, មាត្រា៤៥១ កថាខណ្ឌទី១។
[១១១] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១,០៦ កក្កដា ឆ្នាំ២០០៦, មាត្រា៤៤៤ កថាខណ្ឌទី១
[១១២] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១,០៦ កក្កដា ឆ្នាំ២០០៦, មាត្រា៤៤៧។
[១១៣] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១,០៦ កក្កដា ឆ្នាំ២០០៦, មាត្រា៤៧៨។

ផលដែលបានកំណត់ក្នុងកថាខណ្ឌទី២ នៃមាត្រា៤៤២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ដែលបណ្តាលឲ្យមានឥទ្ធិពលដល់សិទ្ធិរបស់ខ្លួន នៅក្នុងកាលបរិច្ឆេទដើម្បីចេញដីកាសម្រេចលក់បាន។[១១៤] ប៉ុន្តែក្នុងការអនុវត្តជាក់ស្តែង តុលាការមួយចំនួនមិនធ្វើជាសេចក្តីថ្លែងការណ៍នោះទេ គឺគ្រាន់តែធ្វើជាកំណត់ហេតុគឺគ្រាន់តែធ្វើជាកំណត់ហេតុ ដោយផ្តោតសំខាន់នៅត្រង់ ចំណុចដែលការប្រគល់ និងការទទួលប្រាក់បង្គ្រប់ តែប៉ុណ្ណោះ។

### ២.៩.៣. ដីកាសម្រេចអនុញ្ញាតឱ្យលក់ ឬ ដីកាសម្រេចមិនអនុញ្ញាតឱ្យលក់

ក្រោយពីទទួលបាននូវកំណត់ហេតុ ស្តីពីការអនុញ្ញាតឲ្យលក់ដោយអាជ្ញាសាលា ប្រសិនបើគ្មានមូលហេតុនៃការមិនអនុញ្ញាតឲ្យលក់ទេ តុលាការអនុវត្ត ត្រូវចេញដីកាសម្រេចអនុញ្ញាតលក់តាមមាត្រា ៤៤២ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ប៉ុន្តែ តុលាការអាចចេញដីកាសម្រេចមិនអនុញ្ញាតឲ្យលក់បាន ក្នុងករណី តុលាការទទួលស្គាល់ថា មានហេតុណាមួយដូចដែលបានចែងក្នុងកំណត់ហេតុខាងក្រោមនេះ៖

- មិនត្រូវបានចាប់ផ្តើម ឬបន្តនីតិវិធីនៃការលក់ដោយបង្ខំ
- អ្នកស្នើសុំទិញក្នុងតម្លៃអប្បបរមា ដោយពុំមានលក្ខណៈសម្បត្តិ ឬសមត្ថភាពដើម្បីទិញអចលនវត្ថុ ឬអ្នកតំណាងរបស់អ្នកស្នើសុំទិញក្នុងតម្លៃអតិប្បបរមា ពុំមានសិទ្ធិនោះ
- មានសេចក្តីស្នើសុំកុំអនុញ្ញាតការលក់ ដោយយោងទៅតាមបញ្ញត្តិកថាខណ្ឌទី១ នៃមាត្រា៤៤៤
- មានកំហុសធ្ងន់ធ្ងរក្នុងនីតិវិធីនៃដីកាសម្រេចកំណត់តម្លៃអប្បបរមា
- មានកំហុសធ្ងន់ធ្ងរនៅក្នុងនីតិវិធីលក់ ។

## ២.១០. អានុភាពនៃការលក់ដោយបង្ខំ

នៅក្នុងអានុភាពនៃការលក់ដោយបង្ខំនេះ ត្រូវបានបែងចែកជា០៥ដំណាក់កាល គឺការបង្កើតទំនាក់ទំនងការលក់ទិញ អានុភាពចំពោះផល និងប្រយោជន៍លើអចលនវត្ថុ ការទទួលខុសត្រូវក្នុងការធានានៅក្នុងការលក់ដោយបង្ខំ ការទទួលបន្ទុកហានិភ័យនៅក្នុងការអនុវត្តដោយបង្ខំ ការផ្ទុកផ្តាក់ឲ្យចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិ និងលុបចោលការចុះបញ្ជីរឹបអូស និង ការប្រគល់អចលនវត្ថុ។

### ២.១០.១ ការបង្កើតទំនាក់ទំនងការលក់ទិញ

បន្ទាប់ពីទទួលបាន ដីកាសម្រេចអនុញ្ញាតឲ្យលក់(បានចូលជាស្ថាពរ)ហើយ អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមានឹងក្លាយទៅជាអ្នកទិញ ដោយមានទំនាក់ទំនងគតិយុត្តនឹងកើតមានឡើង រវាងអ្នកទិញ និងកូន

[១១៤] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១,០៦ កក្កដា ឆ្នាំ២០០៦, មាត្រា៤៤១។

បំណុលនៃការអនុវត្ត ដូចគ្នាទៅនិងការលក់ទិញធម្មតាដែរ ដោយយោងទៅតាមលក្ខខណ្ឌនៃការអនុវត្ត។ ដោយឡែកចំពោះការបង់ថ្លៃលក់ គឺត្រូវមានអានុភាពនៅពេលដែល ការលក់ទិញត្រូវបានបង្កើតឡើង នៅពេលដែលអ្នកទិញបានបង់ថ្លៃទិញទៅឲ្យតុលាការអនុវត្ត។ ក្រោយពីដីកាសម្រេចអនុញ្ញាតឲ្យលក់បានចូលជាស្ថាពរ អ្នកទិញត្រូវបង់ថ្លៃលក់ទៅតុលាការអនុវត្ត ហើយតុលាការអនុវត្តត្រូវកំណត់ពេលដែលអ្នកទិញត្រូវបង់ថ្លៃ។ ហើយពេលកំណត់នេះ ត្រូវស្ថិតក្នុងអំឡុងពេល ០១ខែ ចាប់ពីថ្ងៃដែលបានដីកាសម្រេចអនុញ្ញាតឲ្យលក់បានចូលជាស្ថាពរ។[១១៥] ប៉ុន្តែ ក្នុងករណី អ្នកទិញមិនបានបង់ថ្លៃលក់ទេ ដីកាសម្រេចអនុញ្ញាតឲ្យលក់នោះនឹងបាត់បង់អានុភាព។ ក្នុងករណីនេះ អ្នកទិញ មិនអាចទាមទារឲ្យសងប្រាក់ដែលខ្លួនបានដាក់ការធានាលើសំណើទិញបានទេ។ ហើយអ្នកទិញដែលបានបង់ថ្លៃទិញ មិនអាចធ្វើសំណើសារជាថ្មីបានទេ។ ចំពោះការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុ គឺនៅពេលដែលអ្នកទិញបានបង់ថ្លៃលក់ហើយ អ្នកទិញត្រូវបានធ្វើលទ្ធកម្មនូវអចលនវត្ថុនោះ។[១១៦] ហើយការធ្វើលទ្ធកម្មនេះ ត្រូវកំណត់តាមលក្ខខណ្ឌនៃការលក់ ។

### ២.១០.២. អានុភាពចំពោះផល និងប្រយោជន៍អចលនវត្ថុ

នៅក្នុងការធ្វើការលទ្ធកម្មកម្មសិទ្ធ តាមរយៈការលក់ទិញអចលនវត្ថុនេះ គឺមិនត្រឹមតែការធ្វើការផ្ទេរកម្មសិទ្ធិនោះទេ គឺទៅព្រមដោយផលធម្មជាតិ និងផលស៊ីវិល ដូចជា ថ្លៃឈ្នួល ជាអាទិ៍នៃអចលនវត្ថុ ត្រូវក្លាយជារបស់អ្នកទិញ ចាប់ពេលដែលបានបង់ថ្លៃលក់។

ហើយអានុភាពចំពោះផល និងប្រយោជន៍លើអចលនវត្ថុ តែងតែត្រូវបានសាធារណៈជនលើកជាសំណួរថា ហេតុអ្វីបានជាគេចូលចិត្តទិញអចលនវត្ថុ ដែលលក់ដោយបង្ខំតាមផ្លូវតុលាការ? ចម្លើយបានជាគេចូលទិញអចលនវត្ថុ ដែលលក់ដោយបង្ខំតាមផ្លូវតុលាការ ដោយហេតុថា ការទិញតាមរយៈនេះ គឺមានប្រយោជន៍ ០២ យ៉ាងសំខាន់ៗ មានដូចជា៖

ទី១ ទាក់ទងតម្លៃ គឺការទិញតាមរយៈការអនុវត្តដោយបង្ខំនេះ តម្លៃអចលនវត្ថុនៃការលក់ទិញនោះមានតម្លៃទាបជាងទីផ្សារនៅក្នុងស្ថានភាពមួយដែលអាចទទួលយកបាន។ ឧទាហរណ៍ ទីតាំងអចលនវត្ថុដែលត្រូវបានលក់តាមរយៈការអនុវត្តដោយបង្ខំ បើគិតក្នុងតម្លៃទីផ្សារបច្ចុប្បន្នក្នុង ០១ (មួយ) ម៉ែត្រការ៉េ តម្លៃ USD ៧០ (ចិតសិបដុល្លារអាមេរិក) ប៉ុន្តែក្នុងតម្លៃលក់ដោយបង្ខំ គឺក្នុង ០១ (មួយ) ម៉ែត្រការ៉េ អាចតម្លៃ USD ៦០ (ហុកសិបដុល្លារអាមេរិក) ឬ USD ៥៥ (ហាសិបប្រាំដុល្លារអាមេរិក)។

[១១៥] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១,០៦ កក្កដា ឆ្នាំ២០០៦, មាត្រា៥៤៧។

[១១៦] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១,០៦ កក្កដា ឆ្នាំ២០០៦, មាត្រា៥៤៧ កថាខណ្ឌទី៤។

ទី២ ទាក់ទងស្ថានភាពនៃអចលនវត្ថុ គឺការទិញតាមរយៈការអនុវត្តដោយបង្ខំនេះ ត្រូវបានធានាថា អចលនវត្ថុនោះ មានស្ថានភាពស្របតាមផ្លូវច្បាប់ ដោយមានលក្ខណៈម្ចាស់កម្មសិទ្ធច្បាស់លាស់ មិនមានជាប់បន្ទុក (ផ្ទុកផ្តាក់ ឬបញ្ចាំ...) ជាដើម។ ផ្ទុយមកវិញ ក្នុងករណីមានតតិយជនណាមួយចេញមកតវ៉ា ក្រោយពេលផ្ទេរកម្មសិទ្ធិនោះ យើងអាចយកនូវឯកសារលក់ទិញនោះ មកធ្វើជាមូលដ្ឋានក្នុងការពារខ្លួនបាន ។

## ២.១០.៣. ការទទួលខុសត្រូវក្នុងការធានានៅក្នុងការលក់ដោយបង្ខំ

នៅក្នុងការលក់អចលនវត្ថុតាមរយៈការអនុវត្តដោយបង្ខំ ក៏មានការទទួលខុសត្រូវក្នុងការធានាការលក់ដូចជា ការលក់ទិញធម្មតាផងដែរ។ ដោយហេតុថា ក្នុងករណីដែលអ្នកទិញមិនអាចធ្វើលទ្ធកម្មនូវកម្មសិទ្ធិទាំងអស់ ឬមួយផ្នែកនៃអចលនវត្ថុ ដែលជាកម្មវត្ថុដោយសារមានវិការៈនៃសិទ្ធិនោះ អ្នកទិញអាចទាមទាររំលាយកិច្ចសន្យាលក់ទិញ ឬឲ្យបន្ថយថ្លៃលក់ចំពោះកូនបំណុលនៃការអនុវត្ត និងទាមទារឲ្យសងចំនួនទឹកប្រាក់ថ្លៃលក់ទាំងអស់ ឬចំនួនទឹកប្រាក់ដែលស្មើនឹងភាគដែលបានបន្ថយនោះមកវិញបាន។[១១៧]

## ២.១០.៤. ការទទួលបន្ទុកហានិភ័យនៅក្នុងការអនុវត្តដោយបង្ខំ

ការទិញអចលនវត្ថុនោះ ក៏មានហានិភ័យមួយចំនួនដូចជា៖ ការបាត់បង់ ឬការខូចខាតអចលនវត្ថុដែលជាកម្មវត្ថុ ដោយហេតុថា មិនមែនជាកំហុសរបស់អ្នកទិញ ឬកូនបំណុលនៃការអនុវត្តទាំងសងខាងនោះទេ គឺត្រូវផ្ទេរជាបន្ទុករបស់អ្នកទិញ ចាប់ពីត្រឹមពេលបង់ប្រាក់ថ្លៃលក់។ ករណីជាក់ស្តែង បើអចលនវត្ថុនោះត្រូវបានវិនាស ឬការបាត់បង់អចលនវត្ថុ តុលាការអនុវត្តត្រូវលុបចោលនីតិវិធីនៃការអនុវត្តដោយបង្ខំដោយឆន្ទានុសិទ្ធិរបស់ខ្លួន។[១១៨] ប៉ុន្តែក្នុងករណី ដែលអចលនវត្ថុនោះ បានខូចខាតធ្ងន់ធ្ងរ ដោយសារគ្រោះធម្មជាតិ ឬដោយមូលហេតុផ្សេងៗទៀត ដែលមិនមែនជាបន្ទុករបស់ខ្លួន អ្នកទិញអាចទាមទារឲ្យលុបចោលដីកាសម្រេចអនុញ្ញាតឲ្យលក់បាន ប្រសិនបើ ដីកាសម្រេចនោះមិនទាន់បានចូលជាស្ថាពរ។[១១៩] សូមបញ្ជាក់ផងដែរថា ការលុបដីកាសម្រេចអនុញ្ញាតឲ្យលក់នេះ គឺតាមពាក្យសុំរបស់អ្នកទិញ។

## ២.១០.៥.ការផ្ទុកផ្ដាក់ឱ្យចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិ និង លុបចោលការចុះបញ្ជីរឹបអូស

ក្រោយពីអ្នកទិញបានបង់ប្រាក់គ្រប់ចំនួនហើយ ក្រឡាបញ្ជីនៃតុលាការអនុវត្ត ត្រូវចេញលិខិតផ្ទុកផ្តាក់ឲ្យចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិ និងលុបចោលការចុះបញ្ជីរឹបអូសដូចជា៖

---

[១១៧] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១,០៦ កក្កដា ឆ្នាំ២០០៦, មាត្រា៥៣៦ កថាខណ្ឌទី៤។

[១១៨] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១,០៦ កក្កដា ឆ្នាំ២០០៦, មាត្រា៤២៧ ។

[១១៩] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១,០៦ កក្កដា ឆ្នាំ២០០៦, មាត្រា៤៤៥។

- ការចុះបញ្ជីអំពីការផ្ទេរសិទ្ធិដែលអ្នកទិញបានធ្វើលទ្ធកម្ម
- ការលុបចោលការចុះបញ្ជីអំពីលទ្ធកម្មនូវដែលបានរលត់ដោយការលក់ ឬសិទ្ធិដែលបានបាត់បង់អនុភាពដោយការលក់
- ការលុបចោលការចុះបញ្ជីអំពីការចាត់ចែងជាបណ្តោះអាសន្ន ដែលបានចាត់ចែងអានុភាពដោយការលក់
- ការលុបចោលការចុះបញ្ជីរឹបអូស ឬការរឹបអូសជាបណ្តោះអាសន្ន។

ហើយដើម្បីផ្ទុកផ្តាក់ការចុះបញ្ជីនេះ ក្រឡាបញ្ជីត្រូវភ្ជាប់មកជាមួយនូវឯកសារថតចម្លងយថាភូតនៃដីកាសម្រេចអនុញ្ញាតឲ្យលក់ ជាមួយនិងលិខិតផ្ទុកផ្តាក់ ព្រមទាំងដោយសោហ៊ុយចាំបាច់ដើម្បីផ្ទុកផ្តាក់ ហើយសោហ៊ុយនេះ ជាបន្ទុករបស់អ្នកទិញ។[១២០]

### ២.១០.៦.ការប្រគល់អចលនវត្ថុ

តុលាការអនុវត្តអាចចេញដីកាសម្រេចបង្គាប់ឱ្យកូនបំណុនៃការអនុវត្ត ឬ អ្នកកាន់កាប់អចលនវត្ថុប្រគល់អចលនវត្ថុនោះទៅឱ្យអ្នកទិញ តាមពាក្យសុំរបស់អ្នកទិញដែលបានបង់ថ្លៃលក់ហើយ។[១២១] ដូច្នេះក្នុងករណីដែលកូនបំណុលនៃការអនុវត្តមិនព្រមប្រគល់អចលនវត្ថុទេ ដីកាសម្រេចបង្គាប់ឱ្យប្រគល់វត្ថុនេះ ត្រូវបានផ្តល់ឱ្យ ដែលអាចធ្វើឱ្យអ្នកទិញអចលនវត្ថុអាចទទួលបានការកាន់កាប់អចលនវត្ថុ ដោយមិនបាច់ដាក់ពាក្យបណ្តឹងទាមទារឱ្យប្រគល់អចលនវត្ថុនោះទេ ដែលធ្វើឱ្យអ្នកទិញមានភាពងាយស្រួស និងចំណេញពេលវេលា។

អ្នកទិញមានរយៈពេល០៦ ខែ គិតចាប់ពីថ្ងៃដែល អ្នកទិញបានបង់ថ្លៃលក់ ដើម្បីដាក់ពាក្យសុំឱ្យតុលាការ ចេញដីកាសម្រេចបង្គាប់ឱ្យប្រគល់អចលនវត្ថុ។ ប្រសិបបើដីកាសម្រេចបង្គាប់ឱ្យប្រគល់អចលនវត្ថុមិនទាន់ចូលជាស្ថាពរ គឺមិនអាចមានអនុភាពឡើយ។

## ២.១១. ការចែកចំណែក

ក្រោយពីបានបង់ថ្លៃលក់អចលនវត្ថុដោយអ្នកបង់ដែលដេញថ្លៃរួចហើយ តុលាការត្រូវពិនិត្យមើលម្ចាស់បំណុលណាខ្លះដែលទទួលបាននូវការចែកចំណែក។ ក្នុងករណីដែលម្ចាស់បំណុលមានតែម្នាក់ ក្រោយពេលបានបង់សិទ្ធិលើបំណុលឱ្យម្ចាស់បំណុលហើយ ត្រូវផ្តល់ប្រាក់ដែលនៅសល់ឱ្យកូនបំណុលនៃការអនុវត្តវិញ។

[១២០] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១,០៦ កក្កដា ឆ្នាំ២០០៦, មាត្រា៤៤៨។

[១២១] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១,០៦ កក្កដា ឆ្នាំ២០០៦, មាត្រា៤៥០ កថាខណ្ឌទី១។

ម៉្យាងទៀត ករណីដែលម្ចាស់បំណុលមានច្រើននាក់ ហើយប្រាក់ដែលបានមកពីការលក់មិនគ្រប់ចំនួនទឹកប្រាក់សិទ្ធិលើបំណុលទេ ត្រូវបែងចែកតាមការព្រមព្រៀងឬ តាមការកំណត់នៃច្បាប់។

### ២.១១.១ ការរៀបចំការចែកចំណែក

បុគ្គលដែលមានសិទ្ធិទទួលបាននូវការចែកចំណែកមាន០២ គឺម្ចាស់បំណុលដែលត្រូវទទួលចំណែក និងជនដែលអាចទាមទារឲ្យចែកចំណែក។[១២២]

**ម្ចាស់បំណុលដែលត្រូវទទួលចំណែក មានដូចជា៖**

- ម្ចាស់បំណុល ដែលបានដាក់ពាក្យសុំការលក់ដោយបង្ខំ ឬការលក់ដោយបង្ខំដែលជាការអនុវត្តឯកសិទ្ធិទូទៅ រហូតដល់កំណត់ពេលចុងក្រោយសម្រាប់ការទាមទារឲ្យចែកចំណែក។ ជាទូទៅ គឺមានចំណុចសំខាន់ៗដូចជា៖
- ការដាក់ពាក្យសុំដោយផ្អែកលើលិខិតអនុវត្តនិងដាក់ពាក្យសុំជាការអនុវត្តសិទ្ធិប្រាតិភោគ។
- ម្ចាស់បំណុលដែលទាមទារឲ្យចែកចំណែក រហូតដល់ពេលកំណត់ចុងក្រោយសម្រាប់ការទាមទារឲ្យចែកចំណែក។

**ជនដែលអាចទាមទារឲ្យចែកចំណែក មានដូចជា៖**

- ជនដែលមានលិខិតអនុវត្ត (មាត្រា៣៥៤ និង មាត្រា ៣៥០ កថាខណ្ឌទី២ នៃក្រមដដែល)
- ម្ចាស់បំណុលដែលបានចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ន នៅក្រោយពេលចុះបញ្ជីអំពីការរឹបអូស ដោយផ្អែកលើដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំ។
- ជនដែលមានឯកសិទ្ធិទូទៅ (យោងតាមមាត្រា ៧៨៣ នៃក្រមរដ្ឋប្បវេណី)។
- ម្ចាស់បំណុលដែលបានចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ន នៅមុនការចុះបញ្ជីអំពីការរឹបអូសដោយផ្អែកលើដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំដំបូង។[១២៣]

ម្ចាស់បំណុលដែលបានចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ននៅក្រោយពេលចុះបញ្ជីអំពីការរឹបអូសត្រូវធ្វើការទាមទារឲ្យចែកចំណែកសិន ទើបអាចទទួលការចែកចំណែកបាន (យោងតាមមាត្រា ៤២៦ កថាខណ្ឌទី១ ចំណុច ខ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ ម៉្យាងទៀត ចំពោះម្ចាស់បំណុលដែលមានសិទ្ធិប្រាតិភោគដែល នឹងបន្តអត្ថិភាពក្រោយការលក់ (ម្ចាស់បំណុលដែលមានសិទ្ធិប្រាតិភោគត្រូវបានចុះបញ្ជី នៅមុនពេលការចុះបញ្ជី

[១២២] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១,០៦ កក្កដា ឆ្នាំ២០០៦, មាត្រា៤៥៣។

[១២៣] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១,០៦ កក្កដា ឆ្នាំ២០០៦, មាត្រា៤២៦ កថាខណ្ឌទី១។

អំពីការរឹបអូស) ទោះបីជាមានលិខិតអនុវត្តក៏ដោយ ក៏មិនអាចទទួលការចែកចំណែកបានឡើយ និងមិនអាចទាមទារឱ្យចែកចំណែកបានដែរ។

ដើម្បីអាចទទួលបានការចែកចំណែក ត្រូវដាក់ពាក្យសុំការលក់ដោយបង្ខំដែលជាការអនុវត្តសិទ្ធិប្រាតិភោគដោយឆន្ទៈរបស់ខ្លួន នៅមុនពេលកំណត់ចុងក្រោយនៃការទាមទារឲ្យចែកចំណែក។[១២៤] តុលាការអនុវត្តដែលត្រូវចែកចំណែកត្រូវកំណត់កាលបរិច្ឆេទនៃការចែកចំណែក ហើយផ្តល់ដំណឹងអំពីពេលវេលា និងទីកន្លែងនោះទៅម្ចាស់បំណុលដែលត្រូវទទួលការចែកចំណែក និងកូនបំណុល។ [១២៥]

### ២.១១.២.វិធីចែកចំណែក

វិធីចែកចំណែកមាន ០២យ៉ាង គឺការចែកចំណែកដោយមិនចាំបាច់ផ្អែកលើតារាងចែកចំណែក និងការចែកចំណែកដោយផ្អែកលើតារាងចែកចំណែក ។

### ក. ការចែកចំណែកដោយមិនចាំបាច់ផ្អែកលើតារាងចែកចំណែក

ការចែកចំណែកដោយមិនចាំបាច់ផ្អែកលើតារាងចែកចំណែក។[១២៦] ក្នុងករណី ដែលមានម្ចាស់បំណុលមានតែម្នាក់ ឬក្នុងករណីដែលម្ចាស់បំណុលមានច្រើននាក់ ហើយទឹកប្រាក់ដែលត្រូវបំពេញការចែកចំណែកនោះអាចសងសព្វគ្រប់ចំពោះសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនីមួយៗ ព្រមទាំងសោហ៊ុយសម្រាប់ការអនុវត្ត។

ឧទាហរណ៍៖ ម្ចាស់បំណុលនៃការអនុវត្តដែលអាចទទួលការចែកចំណែក (ចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុល)

ក. (១២លានរៀល) និង ខ. (១០លានរៀល)

ចំនួនទឹកប្រាក់សរុបដែលត្រូវអនុវត្តការចែកចំណែកគឺ (២៥លានរៀល)

ដូចនេះ ម្ចាស់បំណុលដែលអាចទទួលការចែកចំណែក (ចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុល)

ក (១២លានរៀល) និង ខ (១០លានរៀល)

ចំណែកប្រាក់ដែលនៅសល់ពីការចែកចំណែក(៣លានរៀល)គឺត្រូវប្រគល់ទៅកូនបំណុលនៃការអនុវត្តវិញ។

### ខ. ការចែកចំណែកដោយផ្អែកលើតារាងចែកចំណែក

---

[១២៤] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១,០៦ កក្កដា ឆ្នាំ២០០៦, មាត្រា៤២២ កថាខណ្ឌទី៣។

[១២៥] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១,០៦ កក្កដា ឆ្នាំ២០០៦, មាត្រា៤៨៨ កថាខណ្ឌទី១។

[១២៦] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១,០៦ កក្កដា ឆ្នាំ២០០៦, មាត្រា៤៨៩ កថាខណ្ឌទី១ វាក្យខណ្ឌទី១ និងកថាខណ្ឌទី២។

ការចែកចំណែកដោយផ្អែកលើតារាងចែកចំណែកដែលបានធ្វើនៅកាលបរិច្ឆេទនៃការចែកចំណែក។[១២៧] តុលាការ ត្រូវធ្វើតារាងចែកចំណែកនៅកាលបរិច្ឆេទនៃការចែកចំណែក។[១២៨] នៅកាលបរិច្ឆេទចែកចំណែក ត្រូវកោះហៅម្ចាស់បំណុលដែលត្រូវទទួលចំណែក (មាត្រា៤៥៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី) និងកូនបំណុលនៃការអនុវត្ត (មាត្រា៤៩០ កថាខណ្ឌទី២ ចំណុច គ)។

តុលាការត្រូវធ្វើសេចក្តីព្រាងនៃតារាងចែកចំណែកដោយផ្អែកលើលិខិតគណនា ដែលត្រូវបានដាក់ដោយម្ចាស់បំណុលម្នាក់ៗជាមុន។ នៅកាលបរិច្ឆេទចែកចំណែកពាក់ព័ន្ធនឹងការធ្វើតារាងចែកចំណែកតុលាការអាចសួរម្ចាស់បំណុល និងកូនបំណុលនៃការអនុវត្តដែលបង្ហាញខ្លួន ហើយអាចធ្វើការពិនិត្យភស្តុតាងជាឯកសារដែលអាចធ្វើការពិនិត្យភ្លាមៗបាននៅកាលបរិច្ឆេទនៃការចែកចំណែក យោងតាមមាត្រា៤៩០ កថាខណ្ឌទី៣ នៃក្រមនីតិវិធី រដ្ឋប្បវេណី)។ ចំណុចសំខាន់ៗ ដែលត្រូវសរសេរក្នុងតារាងចែកចំណែក យោងតាមមាត្រា៤៩០ កថាខណ្ឌទី ៤ ចំណុច គ នៃក្រមនីតិវិធីរដ្ឋប្បវេណីមានដូចខាងក្រោម៖

- ចំនួនទឹកប្រាក់បានមកពីការលក់
- អំពីម្ចាស់សិទ្ធិលើបំណុលម្នាក់ៗ (ប្រាក់ដើម ការប្រាក់ ការប្រាក់យឺតយ៉ាវនៃសិទ្ធិលើបំណុលជាអាទិ៍ និងចំនួនទឹកប្រាក់នៃសោហ៊ុយអនុវត្ត)។

លំដាប់ និងចំនួនទឹកប្រាក់នៃការចែកចំណែក គឺតាមកាលបរិច្ឆេទចែកចំណែក ក្នុងករណីដែលកិច្ចព្រមព្រៀងបានសម្រេចឡើង រវាងម្ចាស់បំណុលគ្រប់រូបនោះត្រូវសរសេរតាមការព្រមព្រៀង។ ដោយឡែកក្នុងករណីដែលកិច្ចព្រមព្រៀង មិនអាចសម្រេចបានត្រូវសរសេរតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណី ច្បាប់ដែលទាក់ទងនឹងពាណិជ្ជកម្ម ឬច្បាប់ផ្សេងទៀត។ ជាក់ស្តែងការសម្រេចដោយការព្រមព្រៀងគ្នា គឺពុំសូវមានទេ ភាគច្រើនគឺចែកចំណែកតាមបញ្ញត្តិនៃច្បាប់។

[១២៧] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១,០៦ កក្កដា ឆ្នាំ២០០៦, មាត្រា៤៨៩ កថាខណ្ឌទី១ វាក្យខណ្ឌទី១ ។

[១២៨] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១,០៦ កក្កដា ឆ្នាំ២០០៦, មាត្រា៤៩០ ។

# សេចក្ដីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវ ទៅលើប្រធានបទការរឹបអូសដោយបង្ខំចំពោះអចលនវត្ថុ និង តាមរយៈការសរសេររៀបរាប់អំពីខ្លឹមសារខាងលើនេះមក អាចឱ្យខ្ញុំធ្វើការសន្និដ្ឋានបានថា៖ នីតិវិធីនៃការអនុវត្ត ដោយបង្ខំចំពោះអចនលវត្ថុ គឺជានីតិវិធីមួយដែលមានលក្ខណៈស្មុគស្មាញ និងច្រើនដំណាក់កាលផងដែរ ហើយត្រូវតែគោរពទៅតាមបទបញ្ញត្តិ និងនិតិវិធីដែលបានចែង។ដោយមុននឹង អាចឈានទៅដល់ការចាប់ផ្តើម នៃការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុនោះ គឺម្ចាស់បំណុលនៃ ការអនុវត្តដោយបង្ខំនោះតម្រូវឱ្យដាក់ពាក្យសុំ ជាលាយលក្ខខណ្ឌអក្សរទៅតាមការកំណត់ចែងនៅក្នុងសេចក្តីច្បាប់ ទៅកាន់តុលាការអនុវត្តជាការចាំបាច់ដើម្បី ដំណើរនីតិវិធី និងលិខិតពាក់ពន្ធផ្សេងៗព្រមទាំងតម្រូវភ្ជាប់មកជាមួយផងដែរនូវលិខិតអនុវត្ត និងរូបមន្តអនុវត្ត។

នីតិវិធីអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ ពិតជាមានសារៈសំខាន់ណាស់សម្រាប់ម្ចាស់បំណុល ដែល បានជួបករណីដែល កូនបំណុលរបស់ខ្លួនមិនបានបំពេញនូវការព្វកិច្ចរបស់ខ្លួនដែលមានចែងនៅក្នុងលក្ខខណ្ឌ ឬ កិច្ចសន្យាណាមួយរវាងភាគីទាំងពីរ ដោយក្នុងករណីនេះច្បាប់បានជួយផ្តល់សិទ្ធិឱ្យម្ចាស់បំណុលបានទទួល នូវសំណងរបស់ខ្លួនវិញ ក្រោយការលក់អចលវត្ថុរបស់កូនបំណុលនោះ។ ដោយនៅពេលដែលកូនបំណុលមាន ចេតនាគេចវេសក្នុងការ បំពេញតាវកាលិកជូនម្ចាស់បំណុលដែលមានអត្ថិភាពនៃសិទ្ធិទាមទារ ប្រព័ន្ធអនុវត្ត ដោយបង្ខំបាន ធ្វើការបង្ខិតបង្ខំឱ្យកូនបំណុលផ្តល់តាវការលិកដល់ម្ចាស់បំណុល។ ហើយសិទ្ធិរបស់ម្ចាស់ បំណុលនៃការអនុវត្តដោយបង្ខំ ដែលមានគោលបំណងឱ្យសងជាប្រាក់និងសម្រេចបានស្ថាពរនៅពេលដែល បំណុលជាប្រាក់របស់ម្ចាស់បំណុលត្រូវបានសងមកវិញជាប្រាក់។

ទន្ទឹមនឹងសារសំខាន់របស់និតិវិធីនៃការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ យើងកត់សម្គាល់ឃើញថា ការអនុវត្តដោយទាំងអស់មិនមែនសុទ្ធតែអាចអនុវត្តបានសម្រេច ដោយជោគជ័យនោះទេ ដោយមានករណីខ្លះ អាចនឹងត្រូវបានរារាំង ឬរាអាកខានក្នុងការអនុវត្តដោយបង្ខំដោយឧបសគ្គនានាដែលអាចកើតមានឡើង។

# អនុសាសន៍

# អនុសាសន៍

ដើម្បីជាការរួមចំណែកដល់ការកែលម្អ និងបង្កើនប្រសិទ្ធិភាពនៃការអនុវត្តដោយបង្ខំនេះឱ្យកាន់តែមានប្រសិទ្ធិភាព ក្នុងនាមក្រុមនាងខ្ញុំជាអ្នកស្រាវជ្រាវអំពីប្រធានបទនេះ យើងខ្ញុំសូមផ្តល់ជាអនុសាសន៍មួយចំនួនដោយមានតែគោលបំណងក្នុងការជួយសម្រួល ទៅដល់អ្នកអនុវត្តច្បាប់និងភាគីដែរជាចំណុចខ្វះខាតដើម្បីឱ្យមានការកែលម្អនិងមានការអភិវឌ្ឍទៅមុខ ដោយសម្រាប់ប្រធានបទនេះដែលមានដូចជា បង្កើនការផ្សព្វផ្សាយអប់រំច្បាប់ ព្រោះថាការយល់ដឹងអំពីច្បាប់ គឺពិតជាមានសារសំខាន់ណាស់សម្រាប់ណាស់បុគ្គលម្នាក់ៗ នៅក្នុងសង្គម ដើម្បើបញ្ចៀសពី បញ្ហា ឬទំនាស់ណាមួយដែលទាក់ទងនឹងផ្លូវច្បាប់។ ម្យ៉ាងវិញទៀត ការជម្រុញឱ្យមានការដោះស្រាយរឿងក្តី និងវិវាទរបស់ភាគីប្រកបដោយយុត្តិធម៌ ភាពម៉ត់ចត់ និងឆាប់រហ័ស ។ លើសពីនេះទៅទៀត រឿងក្តីរដ្ឋប្បវេណី រាល់បន្ទុកនានាធ្លាក់មកលើភាគីជាអាទិ៍ ការបង់ពន្ធពាក្យសុំ ប្រាក់ប្រដាប់ក្តី សោហ៊ុយសម្រាប់អនុវត្ត សោហ៊ុយធ្វើសំណើរ និងចំណាយផ្សេងទៀតរបស់ភាគី ដូចច្នេះការពន្លឿនចំពោះ ការដោះស្រាយក៏បានជួយដល់ភាគីបានមួយផ្នែកផងដែរ។ ដោយក្រៅ ទំនាស់ទាក់ទងនឹងការជំពាក់ដែលត្រូវសងជាប្រាក់មានទំនាស់ជាច្រើនដែលកើតឡើងដោយសារការកំណត់ព្រំប្រទល់ដីមិនបានច្បាស់លាស់។ ដូច្នេះការចុះបញ្ជីដីធ្លីពិតជាមានសារសំខាន់ដើម្បីបង្ការ នៅពេលមាន ទំនាស់កើតមានឡើង។

ម្យ៉ាងវិញទៀតនោះទាក់ទងនឹងអចលនវត្ថុជាក់ស្តែងជាដី ជាដើម ការចុញបញ្ជីបើការចុះនោះមិនបានត្រឹមត្រូវស្របទៅតាមនិតិវិធីច្បាប់នោះ នឹងបង្កឱ្យមានការខាតពេលវេលា និងថវិការរបស់ភាគីផងដែរ។ ក្នុងនេះផងដែរការដែរ ពង្រឹងទៅលើសមត្ថភាពអនុវត្តច្បាប់របស់ មន្ត្រីដែរទទួលបន្ទុក និងមានកាតព្វកិច្ច ក៏ជាប្រការមួយចាំមបាចផងដែរ។ ព្រោះថាការព្រឹងសមត្ថភាពរបស់មន្ត្រីអនុច្បាប់ជួយធានាថា មន្ត្រីនីមួយៗយល់ដឹងអំពីនីតិវិធីតុលាការ និងតួនាទីរបស់ខ្លួន ផ្តល់កិច្ចសហប្រតិបត្តិការហើយចូលរួមអនុវត្តច្បាប់ និងសេចក្តីសម្រេចរបស់តុលាការប្រកបដោយប្រសិទ្ធភាពខ្ពស់។

ហេតុដូចនេះហើយក្នុងនាមយើងខ្ញុំជានិស្សិតច្បាប់ ក៏ដូចជាប្រជាពលរដ្ឋយើងទាំងអស់គ្នាសុទ្ធសឹងតែមានបំណងចងឱ្យ អ្នកអនុវត្តច្បាប់ដែលអនុវត្តនៅក្នុងផ្នែកណាមួយ ឬដំណាក់កាលណាមួយនៅក្នុងនីតិវិធីរដ្ឋប្បវេណី និងការដោះស្រាយវិវាទផ្សេងៗរបស់ប្រជាពលរដ្ឋសូមឱ្យប្រកាន់ភ្ជាប់នូវតួនាទីរបស់ខ្លួបប្រកបដោយភាពត្រឹមត្រូវដើម្បីជួយជាចំណែកមួយផ្នែកក្នុការលើកស្ទួយវិស័យយុត្តិធម៌នៅកម្ពុជា។

# ឯកសារយោង

# ឯកសារយោង

## ១. វចនានុក្រម

- ជួន ណាត. វចនានុក្រមខ្មែរ. ភ្នំពេញ បោះពុម្ព ឆ្នាំ២០០៩

## ២. ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០២០៨/០០៨, ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ ១៩៩៣
- ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។
- ក្រមរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៨ ធ្នូ ២០០៧
- ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា,លេខ នស/រកម/០៧១៤/០១៦,១៦ កក្កដា ២០២១៤
- ប្រកាសអន្តរក្រសួងលេខ ៥៩ ប្រក.ដ.ន.ស/១១ ស្តីពីការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី,០៣ ឧសភា ២០១១

## ៣. សៀវភៅ

- ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី, *សេចក្តីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណី, ភាគ២, ការអនុវត្តដោយបង្ខំ និងការចាត់ចែងរក្សាការពារ (ភ្នំពេញ៖ ក្រសួងយុត្តិធម៌)*
- ក្រុមការងារអនាគតគ្រូបណ្តុះបណ្តាលនៅសាកលភូមិន្ទចៅក្រម.*ស្តីពីការពន្យល់អំពីនីតិវិធីលក់ដោយបង្ខំចំពោះអចលនវត្ថុ* .បោះពុម្ពលើកទី១.ខែវិច្ឆិកាឆ្នាំ២០១១។

## ៤. ឯកសារផ្សេងៗ

- ស៊ុន លៀងហេង ,បាវកថាសេរីស្តីពី ការអនុវត្តដោយបង្ខំ លើកទី៣,រាជធានីភ្នំពេញថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២៣
- ម៉ុង មុនីសោភា នីតិវិធីនៃការអនុវត្តដោយបង្ខំ ការលក់ដោយបង្ខំលើអចលនវត្ថុ ទ្រឹស្តី រូបមន្ត ឆ្នាំ ២០១៧

# ឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធទី១៖ គតិយុត្ត

ក្រមនីតិវិធីរដ្ឋប្បវេណីណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦

## ឧបសម្ព័ន្ធទី២៖ លំហូរនីតិវិធីនៃការអនុវត្តដោយបង្ខំ

- ពាក្យសុំអនុវត្តដោយបង្ខំ
- រូបមន្តអនុវត្ត
- ដីកាសម្រេចបង្គាប់ឱ្យបង់សោហ៊ុយក្រៅពីពន្ធដាក់ពាក្យសុំ
- លិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជីអំពីការរឹបអូសអចលនវត្ថុ
- ដីកាសម្រេចអំពីការកំណត់ពេលចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែក
- ការប្រកាសជាសាធារណៈអំពីការកំណត់ការកំណត់ពេលចុងក្រោយសំរាប់ការទាមទារឱ្យចែកចំណែក
- ពាក្យស្នើសុំចាត់តាំងក្រុមហ៊ុនវាយតម្លៃ
- ដីកាសម្រេចជ្រើសតាំងអ្នកវាយតម្លៃ
- ដីកាបង្គាប់ឱ្យស្រាវជ្រាវស្ថានភាពបច្ចុប្បន្ននៃអចលនវត្ថុ
- របាយការណ៍វាយតម្លៃអចលនវត្ថុ
- ដីសម្រេចកំណត់តម្លៃលក់អប្បបរមា
- ដីកាបង្គាប់ឱ្យអនុវត្តការលក់
- ការផ្សាយជាសាធារណៈអំពីការលក់ឡាយឡុងដោយក្រោមសំបុត្រ
- ពាក្យសុំផ្តល់សំណើរទិញ
- ដីកាសម្រេចអនុញ្ញាតឱ្យលក់
- ដីកាសម្រេចកំណត់អំឡុងពេលបង់ថ្លៃលក់
- សេចក្តីថ្លែងការណ៍ស្តីពីការបង់ថ្លៃលក់អចលនវត្ថុ

- លិខិតផ្ទុកផ្ដាក់ឱ្យចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិ
- ដីកាសម្រេចអំពីការកំណត់កាលបរិច្ឆេទនៃការចែកចំណែក
- ដីកាកោះហៅនៅកាលបរិច្ឆេទនៃការចែកចំណែក
- លិខិតគណនាអំពីសិទ្ធិលើបំណុល
- ពាក្យសុំដីកាសម្រេចបង្គាប់ឱ្យប្រគល់អចលនវត្ថុ
- ដីកាសម្រេចបង្គាប់ឱ្យប្រគល់អចលនវត្ថុ

# ឧបសម្ព័ន្ធទី១៖ គតិយុត្ត

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ក្រម
# នីតិវិធីរដ្ឋប្បវេណី
# នៃ
# ព្រះរាជាណាចក្រកម្ពុជា

កាលបរិច្ឆេទប្រកាសឱ្យប្រើ

**០៦ កក្កដា ២០០៦**

# ព្រះរាជក្រម

នស/រកម/០៧០៦/០២១

## យើង

### ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
### សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
### ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
### ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសឱ្យប្រើ

ក្រមនីតិវិធីរដ្ឋប្បវេណី ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី ៤ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងដោយគ្មានកែប្រែអ្វីឡើយ កាលពីថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ២០០៦នាសម័យប្រជុំពេញអង្គលើកទី១នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

# គន្ទីទី ៦

# ការអនុវត្តដោយបង្ខំ

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

### ផ្នែកទី ១

### គោលគំនិត

**មាត្រា ៣៣៤.–** គោលគំនិត

បុគ្គលដែលមានសិទ្ធិទាមទារ ឬ សិទ្ធិប្រាតិភោគដែលបានកំណត់ក្នុងក្រមរដ្ឋប្បវេណី ឬ ច្បាប់ផ្សេងទៀត អាចទាមទារឱ្យសម្រេចសិទ្ធិនោះដោយការអនុវត្តដោយបង្ខំ តាមបញ្ញត្តិនៃគន្ទីនេះ លើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេសក្នុងច្បាប់ផ្សេង ។

**មាត្រា ៣៣៥.–** ការអនុវត្តដូចគ្នា តាមបញ្ញត្តិពីគន្ទីទី ២ ដល់គន្ទីទី ៤

បញ្ញត្តិពីគន្ទីទី ២ ដល់ គន្ទីទី ៤ នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះនីតិវិធីនៃការអនុវត្តដោយបង្ខំ លើកលែងតែមានបញ្ញត្តិពិសេស ។

### ផ្នែកទី ២

### ស្ថាប័នអនុវត្ត

**មាត្រា ៣៣៦.–** ស្ថាប័នអនុវត្ត

១-ការអនុវត្តដោយបង្ខំត្រូវធ្វើឡើងដោយស្ថាប័នអនុវត្ត តាមពាក្យសុំរបស់ភាគី ។

២-ស្ថាប័នអនុវត្ត គឺតុលាការអនុវត្ត ឬ អាជ្ញាសាលា ។

៣-សាលាដំបូងដែលត្រូវអនុវត្តដោយបង្ខំ តាមបញ្ញត្តិនៃគន្ទីនេះ គឺជាតុលាការអនុវត្ត ។

៤-ការសម្រេចសេចក្តីអំពីបណ្តឹងឧបាស្រ័យ ចំពោះការចាត់ចែងការអនុវត្តដែលធ្វើឡើងដោយអាជ្ញាសាលា ត្រូវធ្វើឡើងដោយសាលាដំបូងដែលអាជ្ញាសាលានោះស្ថិតនៅ ។

# ផ្នែកទី ៤
# លំនាំខណ្ឌនៃការអនុវត្តដោយបង្ខំ

**មាត្រា ៣៤៩.-** របៀបដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំ

១-ពាក្យសុំឱ្យអនុវត្តដោយបង្ខំ ត្រូវធ្វើជាលាយល័ក្ខណ៍អក្សរ ។

២-នៅក្នុងពាក្យសុំឱ្យអនុវត្តដោយបង្ខំ ត្រូវមានបញ្ជាក់នូវចំណុចដូចខាងក្រោមនេះ ហើយត្រូវភ្ជាប់ជាមួយនឹងលិខិតចម្លងយថាភូតនៃលិខិតអនុវត្ត ដែលមានអានុភាពអនុវត្ត:

ក-ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋាន របស់ម្ចាស់បំណុលនៃការអនុវត្ត និង កូនបំណុលនៃការអនុវត្ត ហើយនិងឈ្មោះ និង អាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់ ។

ខ-សញ្ញាណនៃលិខិតអនុវត្ត ។

គ-សេចក្តីសុំឱ្យអនុវត្ត តាមការបង្ខំដោយផ្ទាល់ ឬ ការអនុវត្តជំនួស ឬ វិធានបង្ខំដោយប្រយោល ។

ឃ-សញ្ញាណនៃទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ និង វិធីអនុ-វត្តដោយបង្ខំដែលម្ចាស់បំណុលនៃការអនុវត្តសុំ ក្នុងករណីដែលសុំឱ្យអនុវត្តតាមការបង្ខំដោយផ្ទាល់ ។

ង-ខ្លឹមសារនៃសេចក្តីសម្រេចដែលម្ចាស់បំណុលសុំ ក្នុងករណីដែលសុំឱ្យអនុវត្តដោយបង្ខំ តាមការអនុវត្តជំនួស ឬវិធានបង្ខំដោយប្រយោល ។

៣-ក្នុងករណីដែលម្ចាស់បំណុលនៃការអនុវត្តសុំឱ្យអនុវត្តដោយបង្ខំ ចំពោះផ្នែកណាមួយនៃសិទ្ធិទាមទារដែលបានសរសេរនៅក្នុងលិខិតអនុវត្តដែលបង្គាប់ឱ្យសងជាប្រាក់ ម្ចាស់បំណុលនៃការអនុវត្ត ត្រូវសរសេរបញ្ជាក់អំពីសេចក្តីសុំ និង ទំហំនៃសេចក្តីសុំនោះ ក្នុងពាក្យសុំឱ្យអនុវត្តដោយបង្ខំ ។

**មាត្រា ៣៥០.-** លិខិតអនុវត្ត

១-ការអនុវត្តដោយបង្ខំត្រូវធ្វើឡើង ដោយផ្អែកលើលិខិតអនុវត្ត ។

២-លិខិតអនុវត្ត គឺជាលិខិតដែលបានកំណត់ខាងក្រោមនេះ :

ក-សាលក្រម ឬ សាលដីកាបង្គាប់ឱ្យផ្តល់តាវកាលិកដែលបានចូលជាស្ថាពរ ។

ខ-សាលក្រម ឬ សាលដីកាបង្គាប់ឱ្យផ្តល់តាវកាលិកដែលភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន ។

គ-ដីកាសម្រេចបង្គាប់ឱ្យផ្តល់តាវកាលិក ។ ប៉ុន្តែ ចំពោះដីកាសម្រេចដែលមិនត្រូវមានអានុភាពបើមិនទាន់ចូលជាស្ថាពរវិញ មានកម្រិតតែដីកាសម្រេចនោះបានចូលជាស្ថាពរហើយ ។

ឃ-ដីកាសម្រេចដាស់តឿនដែលភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្តោះ-អាសន្ន ។

ង-ការចាត់ចែងរបស់ក្រឡាបញ្ជីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ៦៦ (នីតិវិធីដើម្បីកំណត់ជាស្ថាពរនូវចំនួនប្រាក់ប្រដាប់ក្តី) នៃក្រមនេះ ។

ច-លិខិតយថាភូតដែលធ្វើដោយសារការី ចំពោះការទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់មានកំណត់ ។ ប៉ុន្តែ មានកម្រិតតែលិខិតដែលបញ្ជាក់សេចក្តីថ្លែង-ការណ៍ថា កូនបំណុលនឹងទទួលការអនុវត្តដោយបង្ខំភ្លាមៗ ។

ឆ-សាលក្រម ឬ សាលដីការបស់តុលាការបរទេស ដែលមានសាលក្រមអនុ-វត្ត ដែលបានចូលជាស្ថាពរ តាមបញ្ញត្តិនៃមាត្រា ៣៥២ (សាលក្រមអនុវត្តសាលក្រម ឬ សាលដីការបស់តុលាការបរទេស) នៃក្រមនេះ ។

ជ-សេចក្តីសម្រេចមជ្ឈត្តករ ដែលមានដីកាសម្រេចអនុវត្តដែលបានចូលជាស្ថា-ពរតាមបញ្ញត្តិនៃមាត្រា ៣៥៣ (ដីកាសម្រេចអនុវត្តសេចក្តីសម្រេចមជ្ឈត្តករ) នៃក្រមនេះ ។

ឈ-កំណត់ហេតុដែលបានកំណត់នៅក្នុងមាត្រា ២២២ (អានុភាពនៃកំណត់ហេតុស្តីពីការសះជា ជាអាទិ៍) នៃក្រមនេះ និង កំណត់ហេតុផ្សេងទៀតដែលមានអានុភាពដូចសាលក្រម ឬ សាលដីកាដែលបានចូលជាស្ថាពរ ។

**មាត្រា ៣៥១.-** វិសាលភាពនៃអ្នកដែលអាចអនុវត្តដោយបង្ខំ

១-ការអនុវត្តដោយបង្ខំ អាចធ្វើបាន ដោយចង្អុលអ្នកដែលបានកំណត់ខាងក្រោមនេះ ជាម្ចាស់បំណុលនៃការអនុវត្ត ឬ កូនបំណុលនៃការអនុវត្ត ៖

ក-ភាគីដែលត្រូវបានបញ្ជាក់នៅក្នុងលិខិតអនុវត្ត ។

# ផ្នែកទី ៥
# បណ្ដឹងពាក់ព័ន្ធនឹងការអនុវត្ត

**មាត្រា ៣៦៣.-** បណ្ដឹងតវ៉ាចំពោះការទាមទារ

១-កូនបំណុលនៃការអនុវត្តដែលមានការតវ៉ាចំពោះអត្ថិភាព ឬ អត្ថន័យនៃសិទ្ធិទាមទារ ដែលត្រូវបានកំណត់នៅក្នុងលិខិតអនុវត្ត អាចដាក់ពាក្យបណ្ដឹងតវ៉ាចំពោះការទាមទារ ដើម្បីកុំឱ្យតុលាការអនុញ្ញាតការអនុវត្តដោយបង្ខំ ដោយផ្អែកលើលិខិតអនុវត្តនោះបាន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះលិខិតអនុវត្តដែលបានកំណត់នៅក្នុងចំណុច ខ ឬ ចំណុច ឃ នៃកថាខណ្ឌទី ២ មាត្រា ៣៥០ (លិខិតអនុវត្ត) នៃក្រមនេះ ហើយមិនទាន់ចូលជាស្ថាពរ ។

២-មូលហេតុនៃការតវ៉ាចំពោះសាលក្រម ឬ សាលដីកាស្ថាពរ ត្រូវបានកម្រិតត្រឹមតែហេតុដែលកើតឡើងនៅក្រោយការបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់តែប៉ុណ្ណោះ ។

៣-បណ្ដឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ស្ថិតនៅក្រោមសមត្ថកិច្ចរបស់តុលាការ តាមការកំណត់នីមួយៗ យោលទៅតាមផ្នែកនៃលិខិតអនុវត្តដែលបានកំណត់ក្នុងចំណុចនីមួយៗខាងក្រោមនេះ :

ក-លិខិតអនុវត្តដែលបានកំណត់ចាប់ពីចំណុច ក រហូតទៅដល់ចំណុច ឃ ឬ ចាប់ពីចំណុច ឆ រហូតទៅដល់ចំណុច ឈ កថាខណ្ឌទី ២ មាត្រា ៣៥០ (លិខិតអនុវត្ត) នៃក្រមនេះ : សាលាដំបូងនៃនីតិវិធីសម្រេចសេចក្ដីនោះ ។

ខ-លិខិតអនុវត្តដែលបានកំណត់នៅចំណុច ង កថាខណ្ឌទី ២ មាត្រា ៣៥០ (លិខិតអនុវត្ត) នៃក្រមនេះ : តុលាការដែលក្រឡាបញ្ជីចាត់ចែងដូចចំណុចនោះ ស្ថិតនៅ ។

គ-លិខិតអនុវត្តដែលបានកំណត់នៅចំណុច ច កថាខណ្ឌទី ២ មាត្រា ៣៥០ (លិខិតអនុវត្ត) នៃក្រមនេះ : តុលាការដែលមានសមត្ថកិច្ចលើទីកន្លែងរបស់ចុងចម្លើយ ដែលត្រូវបានកំណត់ដោយមាត្រា ៨ (សមត្ថកិច្ចសាលាជម្រះក្ដីដែលបានកំណត់ទៅតាមលំនៅឋាន ជាអាទិ៍) នៃក្រមនេះ ។ បើពុំមានតុលាការដែលមានសមត្ថកិច្ចតាមមាត្រានេះទេ សាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលកម្មវត្ថុនៃការទាមទារ ឬ ទ្រព្យសម្បត្តិរបស់កូនបំណុលនៃការអនុវត្ត ដែលអាចរឹបអូសបាន ស្ថិតនៅ ។

**មាត្រា ៣៦៤.–** បណ្តឹងតវ៉ាចំពោះការផ្តល់រូបមន្តអនុវត្ត

១-នៅក្នុងករណីដែលរូបមន្តអនុវត្តត្រូវបានផ្តល់ តាមបញ្ញត្តិនៃមាត្រា ៣៥៦ (រូបមន្តអនុវត្តពិសេស) នៃក្រមនេះ កូនបំណុលនៃការអនុវត្តដែលមានការតវ៉ាចំពោះការបំពេញល័ក្ខខ័ណ្ឌ ចំពោះការមកដល់ពេលកំណត់មិនពិតប្រាកដ ឬ ចំពោះលទ្ធភាពដែលអាចធ្វើការអនុវត្តដោយបង្ខំ ដោយយកបុគ្គលក្រៅពីភាគីដែលបានកំណត់ក្នុងលិខិតអនុវត្ត មកធ្វើជាម្ចាស់បំណុលនៃការអនុវត្ត ឬ កូនបំណុលនៃការអនុវត្ត អាចដាក់ពាក្យបណ្តឹងតវ៉ាចំពោះការផ្តល់រូបមន្តអនុវត្ត ដើម្បីកុំឱ្យអនុញ្ញាតការអនុវត្តដោយបង្ខំបាន ដោយផ្អែកលើឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលភ្ជាប់នឹងរូបមន្តអនុវត្តនោះ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ៣ នៃមាត្រា ៣៦៣ (បណ្តឹងតវ៉ាចំពោះការទាមទារ) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះបណ្តឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

**មាត្រា ៣៦៥.–** បណ្តឹងតវ៉ារបស់តតិយជន

១-តតិយជនដែលមានកម្មសិទ្ធិ ឬ សិទ្ធិផ្សេងទៀតដែលរាំងស្ទះការធ្វើអនុប្បទាន ឬប្រគល់ ចំពោះវត្ថុដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ អាចដាក់ពាក្យបណ្តឹងតវ៉ា ដើម្បីទាមទារកុំឱ្យអនុញ្ញាតការអនុវត្តដោយបង្ខំ ចំពោះម្ចាស់បំណុលនៃការអនុវត្តនោះបាន ។

២-បណ្តឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ចំពោះការអនុវត្តដោយបង្ខំ ដោយតុលាការអនុវត្តដែលក្លាយជាស្ថាប័នអនុវត្ត ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់តុលាការអនុវត្តនោះ រីឯចំពោះការអនុវត្តដោយបង្ខំ ដោយអាជ្ញាសាលាដែលក្លាយជាស្ថាប័នអនុវត្ត ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់សាលាដំបូងដែលអាជ្ញាសាលានោះស្ថិតនៅ ។

## ផ្នែកទី ៦
## ការផ្អាក និង ការលុបចោលការអនុវត្តដោយបង្ខំ

**មាត្រា ៣៦៦.–** ការសម្រេចសេចក្តីផ្អាកការអនុវត្តដោយការដាក់ពាក្យបណ្តឹងជំនុំជម្រះសាជាថ្មី ជាអាទិ៍

# ផ្នែកទី ៧
# សោហ៊ុយសម្រាប់ការអនុវត្ត និង ការមើលសំណុំរឿងនៃការអនុវត្ត

**មាត្រា ៣៧១.–** អត្ថន័យនៃសោហ៊ុយសម្រាប់ការអនុវត្ត និង សោហ៊ុយសម្រាប់នីតិវិធី

អត្ថន័យនៃពាក្យដែលកំណត់នៅក្នុងចំណុចនីមួយៗ ត្រូវអនុលោមទៅតាមបញ្ញត្តិក្នុងចំណុចនីមួយៗខាងក្រោមនេះ :

ក-សោហ៊ុយសម្រាប់ការអនុវត្ត : សំដៅទៅលើពន្ធដាក់ពាក្យសុំដែលបានកំណត់នៅក្នុងមាត្រា ៣៧២ (ពន្ធដាក់ពាក្យសុំ) សោហ៊ុយក្រៅពីពន្ធដាក់ពាក្យសុំដែលបានកំណត់នៅក្នុងមាត្រា ៣៧៣ (សោហ៊ុយក្រៅពីពន្ធដាក់ពាក្យសុំ) និង សោហ៊ុយភាគីដែលបានកំណត់នៅក្នុងមាត្រា ៣៧៤ (សោហ៊ុយភាគី) នៃក្រមនេះ ។

ខ-សោហ៊ុយសម្រាប់នីតិវិធី : សំដៅទៅលើសោហ៊ុយសម្រាប់ផលប្រយោជន៍រួមក្នុងចំណោមសោហ៊ុយសម្រាប់ការអនុវត្តដែលបានកំណត់នៅក្នុងចំណុច ក ខាងលើនេះ ។

**មាត្រា ៣៧២.–** ពន្ធដាក់ពាក្យសុំ

១-ក្នុងករណីដែលដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំទៅតុលាការអនុវត្ត ម្ចាស់បំណុលនៃការអនុវត្តត្រូវបង់ពន្ធចំនួន ១០.០០០ (មួយម៉ឺន) រៀល ទៅតុលាការ ។

២-ក្នុងករណីដែលដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំទៅអាជ្ញាសាលា ម្ចាស់បំណុលនៃការអនុវត្តត្រូវបង់ពន្ធ តាមបញ្ញត្តិដែលកំណត់ផ្សេង ។

**មាត្រា ៣៧៣.–** សោហ៊ុយក្រៅពីពន្ធដាក់ពាក្យសុំ

ម្ចាស់បំណុលនៃការអនុវត្តត្រូវបង់នូវចំនួនទឹកប្រាក់ដែលកំណត់ដោយតុលាការ ជាសោហ៊ុយចាំបាច់ក្នុងការបញ្ជូនឯកសារ ឬ ធ្វើសកម្មភាពផ្សេងទៀតដើម្បីនីតិវិធីក្នុងការអនុវត្តដោយបង្ខំ ។

**មាត្រា ៣៧៤.–** សោហ៊ុយភាគី

ក្រៅពីសោហ៊ុយដែលបានកំណត់នៅក្នុងមាត្រា ៣៧២ (ពន្ធដាក់ពាក្យសុំ) និង មាត្រា ៣៧៣ (សោហ៊ុយក្រៅពីពន្ធដាក់ពាក្យសុំ) នៃក្រមនេះ សោហ៊ុយដែលតុលាការទទួលស្គាល់

ការរឹបអូសជាបណ្តោះអាសន្ន ឬ ទាមទារឱ្យចែកចំណែក មុនពេលដែលបានកំណត់ខាងក្រោមនេះ :

ក-ពេលដែលកូនបំណុលទី ៣ បានធ្វើការធ្វើតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ឬ កថាខណ្ឌទី ២ នៃមាត្រា ៤១១ (ការធ្វើប្រាក់ទុកដោយកូនបំណុលទី ៣) នៃក្រមនេះ ។

ខ-ពេលដែលពាក្យបណ្តឹងទាមទារប្រមូលបំណុលត្រូវបានបញ្ជូនទៅកូនបំណុលទី ៣ ។

គ-ពេលដែលអាជ្ញាសាលាបានទទួលប្រាក់ពីការលក់តាមដីកាសម្រេចបង្គាប់ឱ្យលក់ ។

ឃ-ពេលអាជ្ញាសាលាបានទទួលការប្រគល់ចលនវត្ថុ ក្នុងករណីរឹបអូសសិទ្ធិទាមទារឱ្យប្រគល់ចលនវត្ថុ ។

**មាត្រា ៤១៦.-** ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត

ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើទ្រព្យសម្បត្តិផ្សេង ក្រៅពីអចលនវត្ថុ នាវា ចលនវត្ថុ និង សិទ្ធិលើបំណុល ត្រូវអនុវត្តតាមវិធីអនុវត្តចំពោះសិទ្ធិលើបំណុល លើកលែងតែមានបញ្ញត្តិពិសេស ។

## ផ្នែកទី ៤
## ការអនុវត្តចំពោះអចលនវត្ថុ

### កថាភាគទី ១
### កម្មវត្ថុនៃការអនុវត្តចំពោះអចលនវត្ថុ ស្ថាប័នអនុវត្ត វិធីអនុវត្ត វិធីរឹបអូស មធ្យោបាយប្រកាសជាសាធារណៈ និង ការចាត់ចែងការរក្សាការពារ

**មាត្រា ៤១៧.-** កម្មវត្ថុ និងវិធីនៃការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ

១-នៅផ្នែកទី ៤ នេះ អចលនវត្ថុសំដៅទៅលើដី អាគារដែលត្រូវបានចុះបញ្ជី ចំណែកនៃកម្មសិទ្ធិអវិភាគលើដី ឬ អាគារនោះ សិទ្ធិជួលអចិន្ត្រៃយ៍និងផលុបភោគដែលត្រូវបានចុះបញ្ជី និង ចំណែកនៃសិទ្ធិទាំងនេះដែលជាសិទ្ធិរួម ។

២-ការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ ត្រូវធ្វើតាមវិធីលក់ដោយបង្ខំ ។

**មាត្រា ៤២០.-** ការផ្ទុកផ្ដាក់ឱ្យចុះបញ្ជីអំពីការរឹបអូស ជាអាទិ៍

១-បើដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំត្រូវបានចេញ ក្រឡាបញ្ជីត្រូវផ្ទុកផ្ដាក់ឱ្យស្ថាប័នដែលមានសមត្ថកិច្ចចុះបញ្ជី អំពីការរឹបអូសដែលពាក់ព័ន្ធនឹងដីកាសម្រេចចាប់ផ្ដើមនោះជាបន្ទាន់ ។

២-បើបានធ្វើការចុះបញ្ជីអំពីការរឹបអូសដោយផ្អែកលើការផ្ទុកផ្ដាក់ តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ស្ថាប័នដែលមានសមត្ថកិច្ចត្រូវផ្ញើឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់នៃសៀវភៅចុះបញ្ជីនោះទៅក្រឡាបញ្ជី ។

**មាត្រា ៤២១.-** អានុភាពនៃការរឹបអូស

១-អានុភាពនៃការរឹបអូសអចលនវត្ថុ មានទៅលើវត្ថុដែលភ្ជាប់នឹងអចលនវត្ថុ និងជាផ្នែកមួយនៃអចលនវត្ថុនោះ ព្រមទាំងវត្ថុចំណុះនិងសិទ្ធិចំណុះនៃអចលនវត្ថុនោះ ។

២-អានុភាពនៃការរឹបអូស នឹងកើតឡើងនៅពេលដែលដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំត្រូវបានបញ្ជូន ទៅកូនបំណុលនៃការអនុវត្ត ។ ប៉ុន្តែ បើការចុះបញ្ជីអំពីការរឹបអូស ត្រូវបានធ្វើនៅមុនពេលបញ្ជូនដីកាសម្រេចចាប់ផ្ដើមនោះ អានុភាពនោះនឹងកើតឡើងនៅពេលបានចុះបញ្ជី ។

៣-ការរឹបអូសពុំត្រូវរារាំងកូនបំណុលនៃការអនុវត្តក្នុងការប្រើប្រាស់ ឬ អាស្រ័យផលពីអចលនវត្ថុ តាមវិធីប្រើធម្មតាឡើយ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យបង់ថ្លៃឈ្នួលអចលនវត្ថុ ត្រូវបានរឹបអូស ដោយយោងតាមបញ្ញត្តិនៃមាត្រា ៥១៦ (ការរឹបអូសសិទ្ធិលើបំណុលដែលជាថ្លៃឈ្នួលអចលនវត្ថុ) និង ករណីដែលការចាត់ចែងរក្សាការពារត្រូវបានបង្គាប់ ដោយយោងតាមបញ្ញត្តិនៃមាត្រា ៤២៩ (ការចាត់ចែងការរក្សាការពារ) នៃក្រមនេះ ។

**មាត្រា ៤២២.-** ការកំណត់ពេលចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែក និង ការផ្លាស់ប្ដូរពេលកំណត់នោះ

១-ក្នុងករណីដែលអានុភាពនៃការរឹបអូស ដោយផ្អែកលើដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំ បានកើតឡើង តុលាការអនុវត្តត្រូវកំណត់ពេលចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែក ដោយគិតពិចារណានូវអំឡុងពេលចាំបាច់ដើម្បីធ្វើឯកសារលំអិតអំពីវត្ថុ

លើកលែងតែករណីដែលបានចេញដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំត្រួតគ្នា ដោយយោងតាមកថាខណ្ឌទី ១ នៃមាត្រា ៤២៤ (ដីកាសម្រេចចាប់ផ្ដើមត្រួតគ្នា) នៃក្រមនេះ ។

២-នៅពេលដែលពេលចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែកត្រូវបានកំណត់ តុលាការអនុវត្តត្រូវប្រកាសជាសាធារណៈអំពីការណ៍ដែលដីកាសម្រេចចាប់ផ្ដើមត្រូវបានចេញ និង អំពីពេលកំណត់ចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែក ហើយត្រូវដាស់តឿនឱ្យជនដែលបានកំណត់ខាងក្រោមនេះ រាយការណ៍ទៅតុលាការអនុវត្ត អំពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិលើបំណុល និង មូលហេតុនិងចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលនោះ នៅមុនពេលកំណត់ចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែក:

ក-ម្ចាស់បំណុលដែលបានចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ន នៅមុនការចុះបញ្ជីអំពីការរឹបអូស ដោយផ្អែកលើដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំដំបូងចំពោះអចលនវត្ថុនោះ ។

ខ-ម្ចាស់បំណុលដែលមានសិទ្ធិប្រាតិភោគដែលត្រូវបានចុះបញ្ជី នៅមុនការចុះបញ្ជីអំពីការរឹបអូស ដោយផ្អែកលើដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំដំបូង ចំពោះអចលនវត្ថុនោះ ។

គ-ស្ថាប័នដែលមានសមត្ថកិច្ចលើពន្ធដារ ឬ អាករសាធារណៈផ្សេងទៀត ។

៣-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ តុលាការអនុវត្តត្រូវដាស់តឿនចំពោះជនដែលបានកំណត់នៅក្នុងចំណុច ខ នៃកថាខណ្ឌទី ២ អំពីចំណុចដែលបានកំណត់នៅក្នុងចំណុចនីមួយៗខាងក្រោមនេះ:

ក-ការរាយការណ៍អំពីអត្ថិភាព ឬ នត្ថិភាពនៃឆន្ទៈអនុវត្តសិទ្ធិប្រាតិភោគ នៅមុនពេលកំណត់ចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែក ។

ខ-កិច្ចដែលត្រូវដាក់ពាក្យសុំឱ្យអនុវត្តសិទ្ធិប្រាតិភោគ នៅមុនពេលកំណត់ចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែក ក្នុងករណីដែលមានឆន្ទៈអនុវត្តសិទ្ធិប្រាតិភោគ ។

៤-បើមិនបានចេញដីកាសម្រេចអនុញ្ញាតឱ្យលក់ នៅក្នុងអំឡុងពេល ៣ (បី) ខែ គិតចាប់ពីពេលកំណត់ចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែកទេ តុលាការអនុវត្តអាចផ្លាស់ប្ដូរពេលកំណត់ចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែកបាន ។

៥-បើបានផ្លាស់ប្ដូរពេលកំណត់ចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែក ដោយ

សម្រេចដែលយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ តាមពាក្យសុំបាន ។

៤-ចំពោះដីកាសម្រេចអំពីពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ឬ ទី ៣ ខាងលើនេះ អាចប្ដឹងជំទាស់បាន ។

៥-ដីកាសម្រេចដែលយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ទោះជានៅមុនពេលដែលត្រូវបានបញ្ជូនទៅភាគីម្ខាងទៀតក៏ដោយ ក៏អាចអនុវត្តបានដែរ ។

៦-សោហ៊ុយចាំបាច់សម្រាប់ពាក្យសុំ ឬ ការអនុវត្តដីកាសម្រេចដែលយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវចាត់ទុកជាសោហ៊ុយសម្រាប់ផលប្រយោជន៍រួមក្នុងនីតិវិធីនៃការលក់ដោយបង្ខំចំពោះអចលនវត្ថុនោះ ។

## កថាភាគទី ២
## លំនាំខ័ណ្ឌនៃការលក់

**មាត្រា ៤៣០.–** ការវាយតម្លៃ

១-តុលាការអនុវត្តត្រូវជ្រើសតាំងអ្នកវាយតម្លៃ និង បង្គាប់ឱ្យវាយតម្លៃអចលនវត្ថុដោយផ្អែកលើការស្រាវជ្រាវអំពីសណ្ឋាននៃអចលនវត្ថុ ទំនាក់ទំនងនៃការកាន់កាប់ និង ស្ថានភាពបច្ចុប្បន្នឯទៀត ។

២-ដើម្បីសុំជំនួយពីអាជ្ញាសាលាយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ៣៣៨ (ការធានាក្នុងការបំពេញមុខនាទីរបស់អាជ្ញាសាលា ជាអាទិ៍) នៃក្រមនេះ អ្នកវាយតម្លៃត្រូវទទួលការអនុញ្ញាតពីតុលាការអនុវត្ត ។

៣-នៅពេលស្រាវជ្រាវដើម្បីវាយតម្លៃ អ្នកវាយតម្លៃអាចចូលទៅកាន់អចលនវត្ថុ ឬ អាចសួរសំណួរ ឬ ទាមទារឱ្យបង្ហាញឯកសារ ចំពោះកូនបំណុលនៃការអនុវត្ត ឬ តតិយជនដែលកាន់កាប់អចលនវត្ថុនោះបាន ។

៤-បើមានភាពចាំបាច់ អាជ្ញាសាលាដែលអ្នកវាយតម្លៃបានសុំជាជំនួយ តាមបញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ៣៣៨ (ការធានាក្នុងការបំពេញមុខនាទីរបស់អាជ្ញាសាលា ជាអាទិ៍) នៃក្រមនេះ អាចធ្វើការចាត់ចែងចាំបាច់ដើម្បីបើកទ្វារដែលបិទបាន នៅក្នុងករណីដែលអ្នកវាយតម្លៃចូលទៅកាន់អចលនវត្ថុ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ៣ ខាងលើនេះ ។

ដើម្បីបើកទ្វារដែលបិទបាន ។

**មាត្រា ៤៣៥.–** វិធានការក្នុងករណីដែលមានការបារម្ភថាគ្មានសំណល់

១-ប្រសិនបើយល់ឃើញថា តម្លៃលក់អប្បបរមានៃអចលនវត្ថុ ក្រោយពីបានសងសោហ៊ុយសម្រាប់នីតិវិធីហើយ គ្មានលទ្ធភាពសល់ទេនោះ តុលាការអនុវត្តត្រូវជូនដំណឹងអំពីការណ៍នោះទៅឱ្យម្ចាស់បំណុលនៃការអនុវត្ត ។

២-តុលាការអនុវត្តត្រូវលុបចោលនូវនីតិវិធីនៃការលក់ដោយបង្ខំ ដែលទាក់ទងនឹងពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្ត បើម្ចាស់បំណុលនៃការអនុវត្ត មិនបានធ្វើសកម្មភាពដែលបានកំណត់នៅក្នុងចំណុចនីមួយៗខាងក្រោមនេះ :

ក-សំណើថា ខ្លួននឹងទិញអចលនវត្ថុក្នុងតម្លៃស្នើសុំ ក្នុងករណីដែលគ្មានសំណើទិញក្នុងតម្លៃដែលឡើងដល់តម្លៃស្នើសុំនោះ ។ ប៉ុន្តែ សំណើនោះ ត្រូវធ្វើឡើងក្នុងអំឡុងពេល ១ (មួយ) សប្តាហ៍ គិតចាប់ពីថ្ងៃដែលបានទទួលដំណឹងដែលយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ហើយតម្លៃស្នើសុំនោះ ត្រូវលើសពីតម្លៃប៉ាន់ប្រមាណនៃសោហ៊ុយសម្រាប់នីតិវិធី ។

ខ-ការដាក់ប្រាក់ធានាដែលស្មើនឹងតម្លៃស្នើសុំដែលបានកំណត់នៅក្នុងចំណុច ក ខាងលើនេះ ។

## កថាភាគទី ៣
## វិធីលក់

**មាត្រា ៤៣៦.–** វិធីលក់ ជាអាទិ៍

១-ការលក់អចលនវត្ថុ ត្រូវអនុវត្តតាមវិធីលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់ ។

២-តុលាការអនុវត្តអាចកំណត់វិធីលក់ ផ្សេងពីវិធីលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់ តែក្នុងករណីដែលពុំអាចលក់តាមវិធីលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់ ។

៣-ប្រសិនបើលក់តាមវិធីលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់

តុលាការអនុវត្តត្រូវកំណត់កាលបរិច្ឆេទ និង ទីកន្លែងលក់ ហើយត្រូវឱ្យអាជ្ញាសាលាអនុ-វត្តការលក់នោះ ។

៤-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ ក្រឡាបញ្ជីត្រូវផ្សាយជាសាធារណៈនូវសញ្ញាណនៃអចលនវត្ថុដែលត្រូវលក់ តម្លៃលក់អប្បបរមា ព្រមទាំងកាលបរិច្ឆេទ និង ទីកន្លែងលក់ ។

៥-បញ្ញត្តិនៃមាត្រា ៣៩៦ (ការរក្សាសណ្ដាប់ធ្នាប់នៅកន្លែងលក់) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ ។

**មាត្រា ៤៣៧.-** ការធានាលើសំណើទិញ

១-ជនដែលបម្រុងនឹងធ្វើសំណើទិញអចលនវត្ថុ ត្រូវដាក់ប្រាក់ធានាដែលមានចំនួនស្មើនឹងចំនួន ១ ភាគ ១០ (មួយភាគដប់) នៃតម្លៃលក់អប្បបរមា ។ ប៉ុន្តែ បើយល់ឃើញថាសមរម្យ តុលាការអនុវត្តអាចកំណត់ចំនួននៃប្រាក់ធានា លើសពីចំនួននេះបាន ។

២-ប្រសិនបើមានសំណើទិញពីបុគ្គលក្រៅពីអ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា តុលាការអនុវត្តត្រូវសងភ្លាមនូវប្រាក់ធានាដែលបានដាក់តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ក្រោយពេលបញ្ចប់ការលក់ដែលធ្វើឡើង ដោយផ្អែកលើបញ្ញត្តិនៃមាត្រា ៤៣៦ (វិធីលក់ជាអាទិ៍) នៃក្រមនេះ ។

**មាត្រា ៤៣៨.-** ការហាមឃាត់មិនឱ្យកូនបំណុលនៃការអនុវត្តធ្វើសំណើទិញ

កូនបំណុលនៃការអនុវត្តពុំអាចធ្វើសំណើទិញបានឡើយ ។

**មាត្រា ៤៣៩.-** ការកំណត់អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ជាអាទិ៍

១-បើការលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់បានបញ្ចប់ អាជ្ញាសាលាត្រូវប្រកាសការបញ្ចប់កាលបរិច្ឆេទនៃការលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់ ក្រោយពេលបានកំណត់អ្នកស្នើសុំទិញ ក្នុងតម្លៃអតិបរមា និង បានប្រកាសនូវនាម ឬ នាមករណ៍របស់អ្នកទិញ និង ថ្លៃលក់ឡាយឡុងនោះ ។

២-បើអ្នកដេញថ្លៃដោយស្រោមសំបុត្រ ដែលបានធ្វើសំណើទិញក្នុងតម្លៃអតិបរមា

មានច្រើននាក់ អាជ្ញាសាលាត្រូវកំណត់អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ដោយឱ្យអ្នកទាំងនោះដេញថ្លៃដោយស្រោមសំបុត្រម្តងទៀត ។ ក្នុងករណីនេះ អ្នកដេញថ្លៃមិនអាចដេញថ្លៃដោយតម្លៃតិចជាងតម្លៃដែលខ្លួនដេញមុនបានឡើយ ។

៣-បើអ្នកដេញថ្លៃដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ មិនដេញថ្លៃម្តងទៀតទេ អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ត្រូវបានកំណត់ដោយការចាប់ឆ្នោត ។ បញ្ញត្តិនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលអ្នកដេញថ្លៃដោយស្រោមសំបុត្រដែលបានធ្វើសំណើទិញក្នុងតម្លៃអតិបរមា មានច្រើននាក់ នៅក្នុងការលក់ឡាយឡុងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ នោះ ។

៤-បើបានអនុវត្តការលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់ហើយ អាជ្ញាសាលាត្រូវធ្វើកំណត់ហេតុនៃការលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់ ដែលសរសេរនូវចំណុចដូចខាងក្រោម ហើយត្រូវដាក់ទៅតុលាការអនុវត្តភ្លាមៈ

ក-សញ្ញាណនៃអចលនវត្ថុ ។

ខ-កាលបរិច្ឆេទនៃការលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់ ។

គ-សញ្ញាណរបស់អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា និង អ្នកតំណាង ។

ឃ-តម្លៃទិញរបស់អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ។

ង-ហេតុការណ៍នោះ និង ស្ថានភាព បើមិនអាចកំណត់អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ។

ច-មូលហេតុ និង វិធានការដែលបានចាត់ធ្វើ បើបានចាត់វិធានការដែលបានកំណត់នៅក្នុងមាត្រា ៣៩៦ (ការរក្សាសណ្តាប់ធ្នាប់នៅកន្លែងលក់) នៃក្រមនេះ ។

៥-អាជ្ញាសាលាត្រូវឱ្យអ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ឬ អ្នកតំណាង ចុះហត្ថលេខាលើកំណត់ហេតុនៃការលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់ ។

**មាត្រា ៤៤០.-** កាលបរិច្ឆេទដើម្បីចេញដីកាសម្រេចការលក់

១-តុលាការអនុវត្តត្រូវបើកកាលបរិច្ឆេទដើម្បីចេញដីកាសម្រេចការលក់ ហើយត្រូវប្រកាសអំពីការអនុញ្ញាត ឬ មិនអនុញ្ញាតឱ្យលក់ ។

២-នៅពេលដែលបានកំណត់កាលបរិច្ឆេទដើម្បីចេញដីកាសម្រេចការលក់ តុលា-

ទាន់ចូលជាស្ថាពរ ។

**មាត្រា ៤៤៥.-** ការស្នើសុំកុំឱ្យអនុញ្ញាតការលក់ ជាអាទិ៍ ក្នុងករណីដែលអចលនវត្ថុត្រូវបានខូចខាត

១-ក្នុងករណីដែលអចលនវត្ថុបានទទួលការខូចខាតធ្ងន់ធ្ងរ នៅក្រោយពេលធ្វើសំណើទិញដោយសារគ្រោះធម្មជាតិ ឬ ដោយសារមូលហេតុផ្សេងទៀតដែលមិនមែនជាបន្ទុករបស់ខ្លួន អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ឬ អ្នកទិញអាចស្នើសុំទៅតុលាការអនុវត្តកុំឱ្យអនុញ្ញាតការលក់ ប្រសិនបើនៅមុនពេលចេញដីកាសម្រេចអនុញ្ញាតឱ្យលក់ ឬ អាចដាក់ពាក្យសុំទៅតុលាការអនុវត្តឱ្យលុបចោលដីកាសម្រេចនោះ នៅមុនពេលបង់ប្រាក់បាន ប្រសិនបើនៅក្រោយពេលចេញដីកាសម្រេចអនុញ្ញាតការលក់ហើយ ។

២-ចំពោះដីកាសម្រេចអំពីពាក្យសុំឱ្យលុបចោលដីកាសម្រេចអនុញ្ញាតឱ្យលក់ តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ អាចប្ដឹងជំទាស់បាន ។

៣-ដីកាសម្រេចលុបចោលដីកាសម្រេចអនុញ្ញាតឱ្យលក់ តាមពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ពុំមានអានុភាពឡើយ បើមិនទាន់ចូលជាស្ថាពរ ។

**មាត្រា ៤៤៦.-** ការដកពាក្យសុំការលក់ដោយបង្ខំ នៅក្រោយពេលមានសំណើទិញ

ដើម្បីដកពាក្យសុំការលក់ដោយបង្ខំ នៅក្រោយពេលដែលមានសំណើទិញហើយ ម្ចាស់បំណុលនៃការអនុវត្ត ត្រូវទទួលការយល់ព្រមពីសំណាក់អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ឬ អ្នកទិញ ។

## កថាភាគទី ៤
## អានុភាពនៃការលក់

**មាត្រា ៤៤៧.-** ការបង់ថ្លៃលក់

១-បើដីកាសម្រេចអនុញ្ញាតឱ្យលក់បានចូលជាស្ថាពរ អ្នកទិញត្រូវបង់ថ្លៃលក់ទៅតុលាការអនុវត្ត នៅមុនពេលដែលតុលាការអនុវត្តបានកំណត់ ។ ពេលកំណត់នេះ ត្រូវស្ថិតនៅក្នុងអំឡុងពេល ១ (មួយ) ខែចាប់ពីថ្ងៃដែលដីកាសម្រេចអនុញ្ញាតឱ្យលក់ បានចូលជាស្ថាពរ ។

២-ចំនួនទឹកប្រាក់ដែលអ្នកទិញបានដាក់ដើម្បីធានាលើសំណើទិញ ត្រូវគិតបញ្ចូលក្នុងថ្លៃលក់ ។

៣-បើអ្នកទិញគឺជាម្ចាស់បំណុលដែលត្រូវទទួលការចែកចំណែកពីប្រាក់លក់ អ្នកទិញនោះអាចបង់ថ្លៃលក់ ដោយដកនូវចំនួនទឹកប្រាក់ដែលខ្លួនត្រូវទទួលពីការចែកចំណែកនៅកាលបរិច្ឆេទនៃការចែកចំណែកបាន ដោយស្នើសុំទៅតុលាការអនុវត្ត នៅមុនពេលបញ្ចប់កាលបរិច្ឆេទដើម្បីចេញដីកាសម្រេចការលក់ ។ ក្នុងករណីនេះ បើមានសេចក្តីថ្លែងតវ៉ាអំពីចំនួនប្រាក់នៃការចែកចំណែកដែលអ្នកទិញត្រូវទទួល អ្នកទិញត្រូវបង់ចំនួនប្រាក់ដែលស្មើនឹងភាគដែលមានការតវ៉ានោះជាបន្ទាន់ ។

៤-អ្នកទិញធ្វើលទ្ធកម្មនូវអចលនវត្ថុ នៅពេលដែលខ្លួនបានបង់ថ្លៃលក់ហើយ ។

**មាត្រា ៤៤៨.–** ការផ្ទុកផ្តាក់ឱ្យចុះបញ្ជី ដោយការបង់ថ្លៃលក់

១-ប្រសិនបើអ្នកទិញបានបង់ថ្លៃលក់ហើយ ក្រឡាបញ្ជីត្រូវផ្ទុកផ្តាក់ឱ្យស្ថាប័នដែលមានសមត្ថកិច្ចចុះបញ្ជី និង លុបការចុះបញ្ជីនូវចំណុចដូចកំណត់ខាងក្រោមនេះ :

ក-ការចុះបញ្ជី អំពីការផ្ទេរសិទ្ធិដែលអ្នកទិញបានធ្វើលទ្ធកម្ម ។

ខ-ការលុបការចុះបញ្ជី អំពីលទ្ធកម្មនូវសិទ្ធិដែលបានរលត់ដោយការលក់ ឬសិទ្ធិដែលបានបាត់បង់អានុភាពដោយការលក់ ។

គ-ការលុបការចុះបញ្ជី អំពីការចាត់ចែងជាបណ្តោះអាសន្នដែលបានបាត់បង់អានុភាពដោយការលក់ ។

ឃ-ការលុបការចុះបញ្ជី អំពីការរឹបអូស ឬ ការរឹបអូសជាបណ្តោះអាសន្ន ។

២-ដើម្បីផ្ទុកផ្តាក់ តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ក្រឡាបញ្ជីត្រូវភ្ជាប់ឯកសារចម្លងយថាភូតនៃដីកាសម្រេចអនុញ្ញាតឱ្យលក់ ជាមួយនឹងលិខិតផ្ទុកផ្តាក់នោះ ។

៣-សោហ៊ុយចាំបាច់ដើម្បីផ្ទុកផ្តាក់ តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ជាបន្ទុករបស់អ្នកទិញ ។

**មាត្រា ៤៤៩.–** ការទទួលខុសត្រូវរបស់អ្នកទិញ

១-ចំពោះសិទ្ធិប្រាតិភោគដែលនឹងបន្តអត្ថិភាពក្រោយការលក់ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ៤៣១ (សិទ្ធិដែលនឹងបន្តអត្ថិភាព និង សិទ្ធិដែលត្រូវរលត់

ចុះបញ្ជីអំពីការរឹបអូស ដោយផ្អែកលើដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំ ។

## ផ្នែកទី ៦
## នីតិវិធីចែកចំណែកដោយតុលាការ

**មាត្រា ៤៨៧.-** តុលាការដែលត្រូវអនុវត្តការចែកចំណែក

តុលាការដែលត្រូវអនុវត្តការចែកចំណែក គឺសាលាដំបូងដែលអាជ្ញាសាលាស្ថិតនៅចំពោះការអនុវត្តដោយបង្ខំ ចំពោះចលនវត្ថុ ឬ តុលាការអនុវត្ត ចំពោះករណីផ្សេងទៀត ។

**មាត្រា ៤៨៨.-** ការរៀបចំការចែកចំណែក

១-បើមានមូលហេតុដែលចែងនៅចំណុចនីមួយៗខាងក្រោម តុលាការដែលត្រូវចែកចំណែកត្រូវកំណត់កាលបរិច្ឆេទនៃការចែកចំណែក ហើយផ្តល់ដំណឹងអំពីពេលវេលា និង ទីកន្លែងនោះ ទៅម្ចាស់បំណុលដែលត្រូវទទួលការចែកចំណែក និង កូនបំណុល:

ក-ក្នុងការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ពេលដែលមូលហេតុនៃការផ្ញើប្រាក់បានរលត់ ក្នុងករណីដែលមានការជូនដំណឹង តាមបញ្ញត្តិនៃកថាខណ្ឌទី ១ នៃមាត្រា ៤០០ (ការផ្ញើប្រាក់ទុកនៅតុលាការដោយអាជ្ញាសាលា) ឬ ពេលដែលមានការជូនដំណឹងតាមបញ្ញត្តិនៃមាត្រា ៤០១ (ការជូនដំណឹងទៅសាលាដំបូង) នៃក្រមនេះ ។

ខ-ក្នុងការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល និង សិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត ពេលដែលបានធ្វើការផ្ញើប្រាក់ តាមបញ្ញត្តិនៃមាត្រា ៤១២ (បណ្តឹងទាមទារប្រមូលបំណុល) ឬ ពេលដែលបានធ្វើការលក់ ដោយដីកាសម្រេចបង្គាប់ឱ្យលក់ តាមបញ្ញត្តិនៃមាត្រា ៤១៣ (ដីកាសម្រេចបង្គាប់ឱ្យលក់) ឬ ពេលដែលប្រាក់ដែលបានមកពីការលក់ ត្រូវបានប្រគល់ តាមបញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ៤១៤ (ការអនុវត្តដីកាសម្រេចរឹបអូសសិទ្ធិទាមទារឱ្យប្រគល់ចលនវត្ថុ) នៃក្រមនេះ ។

គ-ក្នុងការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ ពេលដែលមានការបង់ថ្លៃលក់តាមបញ្ញត្តិនៃមាត្រា ៤៤៧ (ការបង់ថ្លៃលក់) ឬ ពេលដែលដីកាសម្រេចអនុញ្ញាតឱ្យលក់បានចូលជាស្ថាពរ នៅក្នុងករណីដែលមានការស្នើសុំ ដោយយោងតាមបញ្ញត្តិនៃវាក្យខណ្ឌទី ១ កថាខណ្ឌទី ៣ មាត្រា ៤៤៧ (ការបង់ថ្លៃលក់) នៃក្រមនេះ ។

# ឧបសម្ព័ន្ធទី២៖
# លំហូរនីតិវិធីនៃការអនុវត្តដោយបង្ខំ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ
ថ្ងៃទី ខែ ឆ្នាំ

## ពាក្យសុំអនុវត្តដោយបង្ខំ

**ម្ចាស់បំណុល៖** ក្រុមហ៊ុន CO., LTD.) ទីស្នាក់ការនៅផ្លូវជាតិលេខ ឃុំ ខណ្ឌ រាជធានីភ្នំពេញ តំណាងដោយលោក មានរាសយដ្ឋានបច្ចុប្បន្ននៅផ្ទះលេខ ផ្លូវ ភូមិ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ ។

**កូនបំណុល៖** ១- លោកស្រី កើតថ្ងៃទី ខែ ឆ្នាំ ជនជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ចុះថ្ងៃទី ខែ ឆ្នាំ មានទីលំនៅបច្ចុប្បន្នផ្ទះលេខ ផ្លូវលេខ ភូមិ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ ។

សាលាដំបូងរាជធានីភ្នំពេញ
ថ្ងៃទី ខែ ឆ្នាំ

លេខ...
ថ្ងៃទី... ខែ... ឆ្នាំ...

**សូមគោរពជូន**
**លោកប្រធានសាលាដំបូងរាជធានីភ្នំពេញ**

*សូមជ្រាប។*

**កម្មវត្ថុ៖** ប្តឹងសុំឲ្យតុលាការអនុវត្តរឹបអូសលក់ដោយបង្ខំនូវអចលនវត្ថុដែលមានទីតាំងស្ថិតនៅ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ ដែលមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ចុះថ្ងៃទី ខែ ឆ្នាំ ជាកម្មសិទ្ធិរបស់កូនបំណុល ដើម្បីទូទាត់ប្រាក់បំណុលចំនួន USD ( ដុល្លារអាមេរិក)។

**យោង៖**
- មាត្រា ៣៣៨, ៣៧៥ និង មាត្រា ៤១៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី
- សាលក្រមរដ្ឋប្បវេណីលេខ ចុះថ្ងៃទី ខែ ឆ្នាំ របស់សាលាដំបូងរាជធានីភ្នំពេញ
- របមន្តអនុវត្តសាលក្រមលេខ ចុះថ្ងៃទី ខែមេសា ឆ្នាំ

តបតាមកម្មវត្ថុ និង យោងខាងលើខ្ញុំបាទសូមជម្រាបជូន **លោកប្រធាន** មេត្តាជ្រាបថា៖ កាលពីថ្ងៃទី ខែ ឆ្នាំ ) សាលាដំបូងរាជធានីភ្នំពេញ បានប្រកាសសាលក្រមរដ្ឋប្បវេណីលេខ ចុះថ្ងៃទី ខែ ឆ្នាំ ដោយចំណុចទី១ នៃសេចក្តីសម្រេចបញ្ចប់ បានបង្គាប់ឲ្យសហកូនបំណុល ឈ្មោះ និងឈ្មោះ គុយស្រ៊ុង សងប្រាក់ចំនួន ( ) ដុល្លារអាមេរិក មកឲ្យម្ចាស់បំណុល និងចំណុចទី៣ បានអនុញ្ញាតឲ្យអនុវត្តជាបណ្តោះអាសន្ន។ ដោយហេតុថាកូនបំណុលមិនព្រមអនុវត្តកាតព្វកិច្ចដោយស្ម័គ្រចិត្តតាមការសម្រេច ហេតុនេះខ្ញុំបាទស្នើសុំឲ្យតុលាការអនុវត្តធ្វើការរឹបអូសអចលនវត្ថុរបស់កូនបំណុលដើម្បីទូទាត់ប្រាក់បំណុលតាមការសម្រេចដូចក្នុងសាលក្រម។

Scanned with CamScanner

### ក. សញ្ញាណនៃលិខិតអនុវត្ត

- សាលក្រមរដ្ឋប្បវេណីលេខ ចុះថ្ងៃទី ខែ ឆ្នាំ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលបង្គាប់ឲ្យកូនបំណុលសងប្រាក់ចំនួនUSD ( ដុល្លារអាមេរិក) ភ្ជាប់ជាមួយការប្រកាសឲ្យអនុវត្តបណ្តោះអាសន្ន។

### ខ. សេចក្តីសុំឲ្យអនុវត្ត

- សុំឲ្យតុលាការអនុវត្ត អនុវត្តដោយផ្ទាល់។

### គ. ទ្រព្យសម្បត្តិដែលជាកម្មវត្ថុ និង វិធីអនុវត្ត

ទ្រព្យសម្បត្តិ៖ អចលនវត្ថុដែលមានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ភព

ចុះថ្ងៃទី ខែ ឆ្នាំ របស់ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានីភ្នំពេញ មានទីតាំងស្ថិតនៅសង្កាត់ព្រែកប្រា ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ។

វិធីអនុវត្ត៖ រឹបអូសលក់ឡាយឡុយ។

សិទ្ធិលើបំណុល៖ USD ( ដុល្លារអាមេរិក)។

អាស្រ័យហេតុដូចបានជម្រាបជូននេះ សូម **លោកប្រធាន** មេត្តាទទួលពាក្យសុំដោយក្តីអនុគ្រោះ។

សូម **លោកប្រធាន** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

ថ្ងៃ ខែ ឆ្នាំ ព.ស

រាជធានីភ្នំពេញ,ថ្ងៃទី ខែ ឆ្នាំ

**ម្ចាស់បំណុល**

Scanned with CamScanner

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

លេខ

## រូបមន្តអនុវត្តសាលក្រម

យើង ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

-បានឃើញ មាត្រា ៣៥៤ , ៣៥៥ , ៣៥៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

-បានឃើញ សំណុំរឿងរដ្ឋប្បវេណីលេខ ចុះថ្ងៃទី ខែ ឆ្នាំ របស់សាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ សាលក្រមរដ្ឋប្បវេណីលេខ ចុះថ្ងៃទី ខែ ឆ្នាំ របស់សាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ ពាក្យសុំរូបមន្តអនុវត្ត ចុះថ្ងៃទី ខែ ឆ្នាំ របស់លោកស្រី ជាមេធាវីតំណាងដោយអាណត្តិឱ្យក្រុមហ៊ុន ( CO.,LTD) មានលោក ជាតំណាងក្រុមហ៊ុន មានស្នាក់ការស្ថិតនៅ ផ្លូវជាតិលេខ សង្កាត់ លេខ ខណ្ឌ រាជធានីភ្នំពេញ។

សូមបញ្ជាក់ អំពីខ្លឹមសារនៃការអនុវត្តដែលមានដូចខាងក្រោមនេះ

ម្ចាស់បំណុល នៃការអនុវត្ត ក្រុមហ៊ុន CO.,LTD)មានលោក ជាតំណាងក្រុមហ៊ុន មានស្នាក់ការស្ថិតនៅ ផ្លូវជាតិលេខ សង្កាត់ លេខ៦ ខណ្ឌ រាជធានីភ្នំពេញ។

អាចអនុវត្តជាបណ្តោះអាសន្ន នូវចំណុចទី១ នៃសេចក្តីសម្រេច តាមសាលក្រមរដ្ឋប្បវេណីលេខ ចុះថ្ងៃទី ខែ ឆ្នាំ របស់សាលាដំបូងរាជធានីភ្នំពេញ។

ពីសហកូនបំណុល នៃការអនុវត្តមាន៖

១.ឈ្មោះ ភេទ អាយុ ឆ្នាំ សញ្ជាតិខ្មែរ មានអាសយដ្ឋាននៅផ្ទះលេខ ផ្លូវ ភូមិ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ។

២.ឈ្មោះ ភេទប្រុស អាយុ ឆ្នាំ សញ្ជាតិខ្មែរ ផ្ទះលេខ ផ្លូវ ភូមិ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ។

*សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់ដល់ភ្នាក់ងារអនុវត្តដោយបង្ខំ ឱ្យបានសម្រេចតាមសាលក្រមនេះ និងឱ្យអាជ្ញាធរសាធារណៈជួយអនុវត្តសាលក្រមនេះ បើមានសំណូមពរត្រឹមត្រូវតាមច្បាប់។*

ថ្ងៃ ខែ ឆ្នាំ ព.ស

រាជធានីភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ

ក្រឡាបញ្ជី

Scanned with CamScanner

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ដីកាសម្រេចបង្គាប់ឲ្យបង់សោហ៊ុយក្រៅពីពន្ធដាក់ពាក្យសុំ

សាលាដំបូងរាជធានីភ្នំពេញ **យើង** **ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ**
លេខ

បានឃើញ ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាដែលប្រកាសឲ្យប្រើតាមព្រះរាជក្រម នស/ រកម/ ុះថ្ងៃទី ខែ ឆ្នាំ

បានឃើញសំណុំរឿងអនុវត្តដោយបង្ខំលេខ ចុះថ្ងៃទី ខែ ឆ្នាំ

**-ម្ចាស់បំណុលនៃការអនុវត្ត៖** ក្រុមហ៊ុន CO., LTD.) មានទីស្នាក់ការនៅផ្លូវជាតិលេខ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ តំណាងដោយលោក មានអាសយដ្ឋាននៅផ្ទះលេខ ផ្លូវ ភូមិ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ។

**-កូនបំណុលនៃការអនុវត្ត៖** លោក កើតថ្ងៃទី ខែ ឆ្នាំ ជនជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ចុះថ្ងៃទី ខែ ឆ្នាំ មានទីលំនៅបច្ចុប្បន្នផ្ទះលេខ ភូមិ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ។

**<u>កម្មវត្ថុបណ្តឹង</u>** ប្តឹងសុំឲ្យតុលាការអនុវត្តរឹបអូសលក់ដោយបង្ខំនូវអចលនវត្ថុជាកម្មសិទ្ធិរបស់កូនបំណុល។

**<u>សំអាងហេតុ</u>**

-ដើម្បីដំណើរការនីតិវិធីបណ្តឹងទៅតាមច្បាប់គប្បីឲ្យឈ្មោះ **អ៊ឹង សម្បត្តិសុភ័ក្ត្រ** ជាម្ចាស់បំណុលបង់សោហ៊ុយក្រៅពីពន្ធដាក់ពាក្យសុំ តាមមាត្រា ៣៧៣ និងមាត្រា ៣៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា។

-ដើម្បីផ្អាកផ្តាក់ចុះបញ្ជីអំពីការរឹបអូស ចំពោះអចលនវត្ថុដែលមានវិញ្ញាបនបត្រសំគាល់ម្ចាស់អចលនវត្ថុ ឬប័ណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី តម្រូវឲ្យបង់ប្រាក់ពន្ធចំនួន ២០០.០០០ (ម្ភៃម៉ឺនរៀល) ក្នុងមួយប័ណ្ណចំនែកម្ចាស់បំណុលបានស្នើសុំអនុវត្តរឹបអូសលក់ឡាយឡុងលើអចលនវត្ថុចំនួន ០១បណ្ណ័ ហេតុនេះគប្បីម្ចាស់បំណុលទទួលបន្ទុកបង់សោហ៊ុយនេះជាមុន។

-ដើម្បីអនុវត្តតាមពាក្យសុំ តុលាការត្រូវបំពេញឯកសារ និងផ្ញើនូវឯកសារទាំងនោះ ដែលបន្ទុកចំណាយសម្រាប់សោហ៊ុយត្រូវប៉ានប្រមាណ ១០០.០០០ (ដប់ម៉ឺនរៀល) ហេតុនេះគប្បីម្ចាស់បំណុលទទួលបន្ទុកបង់ សោហ៊ុយនេះជាមុន។

**<u>ហេតុដូច្នេះ សម្រេច</u>**

១/បង្គាប់ឲ្យម្ចាស់បំណុលឈ្មោះ បង់សោហ៊ុយក្រៅពីពន្ធដាក់ពាក្យសុំ ចំនួន ៣០០.០០០ (សាមសិបម៉ឺន) រៀល ទៅសាលាដំបូងរាជធានីភ្នំពេញ ឲ្យបានមុនថ្ងៃ ខែកញ្ញា ឆ្នាំ កំណត់ដើម្បីតុលាការ ចាត់ការរឿងក្តីនេះតាមច្បាប់ ។

២/ក្នុងករណីមិនអនុវត្តចំនុចទី ១ ដែលបានចែងខាងលើ <u>និងលើកបណ្តឹងចោល</u> តាមច្បាប់ ។

ថ្ងៃ ឆ្នាំ ក ព.ស
រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ
**ចៅក្រម**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងអនុវត្តដោយបង្ខំ

លេខ ចុះថ្ងៃទី ខែ ឆ្នាំ

លេខ៖

## ដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំ

**យើង** **ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ**

-បានឃើញមាត្រា ៤១៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រម នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦

-បានឃើញសំណុំរឿងអនុវត្តដោយបង្ខំលេខ ចុះថ្ងៃទី ខែ ឆ្នាំ របស់សាលាដំបូងរាជធានីភ្នំពេញ

-បានឃើញពាក្យសុំឲ្យអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ ចុះថ្ងៃទី ខែ ឆ្នាំ

**រវាង** ក្រុមហ៊ុន ( CO., LTD.) មានទីស្នាក់ការនៅផ្លូវជាតិ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ តំណាងដោយលោក មានអាសយដ្ឋាននៅផ្ទះលេខ ផ្លូវ ភូមិ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ។

**និង** លោកស្រី កើតថ្ងៃទី ខែ ឆ្នាំ ជនជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ចុះថ្ងៃទី ខែ ឆ្នាំ មានទីលំនៅបច្ចុប្បន្នផ្ទះលេខ ផ្លូវលេខ ភូមិ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ។

*កម្មវត្ថុ៖* ស្នើរបអូសដើម្បីលក់ដោយបង្ខំនូវអចលនវត្ថុដែលមានទីតាំងស្ថិតនៅភូមិ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ ដែលមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ចុះថ្ងៃទី ខែ ឆ្នាំ ។

***-សិទ្ធិលើបំណុលដែលទាមទារ៖*** USD ( ដុល្លារអាមេរិក)។

***-សញ្ញាណនៃទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ៖*** អចលនវត្ថុដែលមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ភព ចុះថ្ងៃទី ខែ ឆ្នាំ ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានីភ្នំពេញ ដែលដាក់ជូនដោយម្ចាស់បំណុល ទីតាំងស្ថិតនៅភូមិ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ។

***-សញ្ញាណនៃលិខិតអនុវត្ត៖*** ឯកសារចម្លងយថាភូតនៃសាលក្រមរដ្ឋប្បវេណីលេខ ចុះថ្ងៃទី ខែ ឆ្នាំ របស់សាលាដំបូងរាជធានីភ្នំពេញ។

- បានឃើញ រូបមន្តអនុវត្តសាលក្រមលេខ ចុះថ្ងៃទី ខែ ឆ្នាំ របស់សាលាដំបូងរាជធានីភ្នំពេញ។

ច្បាប់ចម្លងត្រឹមត្រូវតាមច្បាប់ដើម
សាលាដំបូងរាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ
ក្រឡាបញ្ជី

Scanned with CamScanner

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ
សំណុំរឿងអនុវត្តដោយបង្ខំ
លេខ ចុះថ្ងៃទី ខែ ឆ្នាំ
លេខ៖...

ថ្ងៃ ខែ ឆ្នាំ ព.ស
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ

# លិខិតផ្ទុកផ្ដាក់ឲ្យចុះបញ្ជីអំពីការរឹបអូសអចលនវត្ថុ

ក្រឡាបញ្ជីនៃសាលាដំបូងរាជធានីភ្នំពេញ

សូមគោរពជូន

**ឯកឧត្តមអភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ**

**កម្មវត្ថុ៖** - ការផ្ទុកផ្ដាក់ឲ្យចុះបញ្ជីអំពីការរឹបអូសកម្មសិទ្ធិ:

ក - អត្តសញ្ញាណនៃអចលនវត្ថុ លេខក្បាលដី ឬលេខប័ណ្ណអចលនវត្ថុ ជាដីទំហំ ដែលមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ លេខ ចុះថ្ងៃទី ខែ ឆ្នាំ ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានីភ្នំពេញ។

ទីតាំងដី : ស្ថិតនៅភូមិ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ

ខ - ឈ្មោះកម្មសិទ្ធិករ ឬ ម្ចាស់សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគីនៃអចលនវត្ថុ: លោកស្រី កើតថ្ងៃទី ខែ ឆ្នាំ ជនជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ចុះថ្ងៃទី ខែ ឆ្នាំ មានទីលំនៅបច្ចុប្បន្នផ្ទះលេខ ផ្លូវលេខ ភូមិបឹង សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ។

គ - គោលបំណងនៃការចុះបញ្ជី: ការរឹបអូសកម្មសិទ្ធិទៅលើអចលនវត្ថុចំណុច "ក"។

ឃ - មូលហេតុ: ដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំលេខ ចុះថ្ងៃទី ខែ ឆ្នាំ របស់សាលាដំបូងរាជធានីភ្នំពេញ។

ង - ឈ្មោះម្ចាស់បំណុលនៃការអនុវត្ត : ក្រុមហ៊ុន CO., LTD.) មានទីស្នាក់ការនៅផ្លូវជាតិលេខ៥ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ តំណាងដោយលោក មានអាសយដ្ឋាននៅផ្ទះលេខ ផ្លូវ ភូមិ សង្កាត់ ខណ្ឌ រាជធានី ភ្នំពេញ។

ច - ឈ្មោះកូនបំណុលនៃការអនុវត្ត : លោកស្រី កើតថ្ងៃទី ខែ ឆ្នាំ ជនជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ចុះថ្ងៃទី ខែ ឆ្នាំ មានទីលំនៅបច្ចុប្បន្នផ្ទះលេខ ផ្លូវលេខ ភូមិ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ។

ឯកសារភ្ជាប់ជាមួយ:

-ឯកសារចម្លងយថាភូតនៃដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំលេខ ចុះថ្ងៃទី ខែ ឆ្នាំ របស់សាលាដំបូងរាជធានីភ្នំពេញ។

ហត្ថលេខា និង ត្រា

Scanned with CamScanner

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

លេខ

## ដីកាសម្រេច
## អំពី
## ការកំណត់ពេលចុងក្រោយសំរាប់ការទាមទារឲ្យចែកចំណែក

**យើង ... ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ**

- **បានឃើញ** មាត្រា ៤២២-១ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រម នស/ រកម/ ០៧០៦/ ០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។
- **បានឃើញ** សំណុំរឿងអនុវត្តដោយបង្ខំលេខ ចុះថ្ងៃទី ខែ ឆ្នាំ របស់សាលាដំបូងរាជធានីភ្នំពេញដែលមាន ៖

**ម្ចាស់បំណុលនៃការអនុវត្ត៖** ក្រុមហ៊ុន ... CO., LTD.) មានទីស្នាក់ការនៅផ្លូវ សង្កាត់ , ខណ្ឌ រាជធានីភ្នំពេញ តំណាងដោយលោក មានអាសយដ្ឋាននៅផ្ទះលេខ ផ្លូវ ភូមិ២ សង្កាត់ ខណ្ឌចំ រាជធានីភ្នំពេញ។

**កូនបំណុលនៃការអនុវត្ត៖** លោកស្រី កើតថ្ងៃទី ខែ ឆ្នាំ ជនជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ចុះថ្ងៃទី ខែ ឆ្នាំ មានទីលំនៅបច្ចុប្បន្នផ្ទះលេខ ផ្លូវលេខ ភូមិ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ។

- **បានឃើញ** ដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំលេខ ចុះថ្ងៃទី ខែ ឆ្នាំ របស់សាលាដំបូងរាជធានីភ្នំពេញ។

## សម្រេច

កំណត់ពេលចុងក្រោយសំរាប់ការទាមទារឲ្យចែកចំណែក ត្រឹមថ្ងៃទី ខែ ឆ្នាំ ក្នុងសំណុំរឿងអនុវត្តដោយបង្ខំលេខ ចុះថ្ងៃទី ខែ ឆ្នាំ របស់សាលាដំបូង រាជធានីភ្នំពេញ ដែលមានអចលនវត្ថុជាកម្មសិទ្ធិរបស់ឈ្មោះ មានប័ណ្ណសំគាល់សិទ្ធិកាន់កាប់ អចលនវត្ថុលេខ ចុះថ្ងៃទី ខែ ឆ្នាំ ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានីភ្នំពេញ មានទីតាំងស្ថិតនៅភូមិ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ។

ថ្ងៃ ខែ ឆ្នាំ ព.ស
រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ
ចៅក្រម

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

លេខ

## ការប្រកាសជាសាធារណៈ
## អំពី
## ការកំណត់ពេលចុងក្រោយសំរាប់ការទាមទារឲ្យចែកចំណែក

**យើង ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ**

- **បានឃើញ** មាត្រា ៤២២-២ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រម នស/ រកម/ ០៧០៦/ ០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។
- **បានឃើញ** សំណុំរឿងអនុវត្តដោយបង្ខំលេខ ចុះថ្ងៃទី ខែ ឆ្នាំ របស់សាលាដំបូងរាជធានីភ្នំពេញដែលមាន ៖

**ម្ចាស់បំណុលនៃការអនុវត្តៈ** ក្រុមហ៊ុន
CO., LTD.) មានទីស្នាក់ការនៅផ្លូវជាតិលេខ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ តំណាងដោយលោក មានអាសយដ្ឋាននៅផ្ទះលេខ ផ្លូវ ភូមិ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ។

**កូនបំណុលនៃការអនុវត្តៈ** លោកស្រី កើតថ្ងៃទី ខែ ឆ្នាំ ជនជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ចុះថ្ងៃទី ខែ ឆ្នាំ មានទីលំនៅបច្ចុប្បន្នផ្ទះលេខ ផ្លូវលេខ ភូមិ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ។

- **បានឃើញ** ដីកាសម្រេចអំពីពេលចុងក្រោយសំរាប់ការទាមទារឲ្យចែកចំណែកលេខ...... ចុះថ្ងៃទី ខែ ឆ្នាំ របស់សាលាដំបូងរាជធានីភ្នំពេញ។

## សម្រេច

កំណត់ពេលចុងក្រោយសំរាប់ការទាមទារឲ្យចែកចំណែក ត្រឹមថ្ងៃទី ខែ ឆ្នាំ ក្នុងសំណុំរឿងអនុវត្តដោយបង្ខំលេខ ចុះថ្ងៃទី ខែ ឆ្នាំ របស់សាលាដំបូង រាជធានីភ្នំពេញ ដែលមានអចលនវត្ថុជាកម្មសិទ្ធិរបស់ឈ្មោះ មានប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ។ ចុះថ្ងៃទី ខែ ឆ្នាំ ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានីភ្នំពេញ មានទីតាំងស្ថិតនៅភូមិ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ។

ថ្ងៃ ខែ ឆ្នាំ ព.ស
រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ
**ចៅក្រម**

Scanned with CamScanner

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ពាក្យស្នើសុំចាត់តាំងក្រុមហ៊ុនវាយតម្លៃ**

សាលាដំបូងរាជធានីភ្នំពេញ
បូល
លេខ...
ថ្ងៃទី... ខែ... ២
ម៉ោង... នាទី

**ម្ចាស់បំណុល៖** ក្រុមហ៊ុន T CO., LTD.)
ទីស្នាក់ការនៅផ្លូវជាតិលេខ ឃុំ ខណ្ឌ រាជធានីភ្នំពេញ តំណាងដោយ
លោក មានអាសយដ្ឋានបច្ចុប្បន្ននៅផ្ទះលេខ ផ្លូវ ភូមិ
សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ ។

ជូនទៅក្រុមបច្ចុប្បន្ន
ពិនិត្យ និងចាត់ការ

**សូមគោរពជូន**
**ឯកឧត្តមប្រធានសាលាដំបូងរាជធានីភ្នំពេញ**

*សូមមានព្រះបាទ*

**កម្មវត្ថុ៖** ស្នើសុំជ្រើសតាំងក្រុមហ៊ុន ជាក្រុមហ៊ុនវាយតម្លៃអចលនវត្ថុក្នុងសំណុំរឿងអនុវត្តដោយបង្ខំលេខ ចុះថ្ងៃទី ខែ ឆ្នាំ របស់សាលាដំបូងរាជធានីភ្នំពេញ។

**យោង៖** - សំណុំរឿងអនុវត្តដោយបង្ខំលេខ ចុះថ្ងៃទី ខែ ឆ្នាំ របស់សាលាដំបូងរាជធានីភ្នំពេញ។

តបតាមកម្មវត្ថុ និង យោងខាងលើខ្ញុំបាទសូមជម្រាបជូន **ឯកឧត្តម ប្រធាន** មេត្តាជ្រាបថាដើម្បីឆ្លើយតបទៅនឹងដំណើរការនៃនីតិវិធីនៃការលក់ដោយបង្ខំ និងក៏ដូចជាដើម្បីមានមូលដ្ឋានសម្រាប់ធ្វើការវាយតម្លៃអចលនវត្ថុលក់ឡាយឡុងក្នុងសំណុំរឿងអនុវត្តដោយបង្ខំនេះ ឲ្យសមស្របទៅនឹងតម្លៃអចលនវត្ថុក្នុងទីផ្សា ខ្ញុំបាទសូមស្នើសុំអនុញ្ញាត **ឯកឧត្តម** ពិចារណាសម្រេចជ្រើសរើសតាំងក្រុមហ៊ុន ដែលមានទីតាំងស្ថិតនៅផ្ទះលេខ ផ្លូវលេខ ភូមិ សង្កាត់ផ្សារ ខណ្ឌ រាជធានីភ្នំពេញ ដែលជាក្រុមហ៊ុនអចលនវត្ថុធ្លាប់មានបទពិសោធន៍ជាច្រើនក្នុងវាយតម្លៃដី ផ្ទះ និងអគារ ឲ្យធ្វើការវាយតម្លៃលើអចលនវត្ថុក្នុងសំណុំរឿងអនុវត្តដោយបង្ខំលេខ ចុះថ្ងៃទី ខែ ឆ្នាំ របស់សាលាដំបូងរាជធានីភ្នំពេញ។

អាស្រ័យហេតុ នេះ៖ សូម **ឯកឧត្តម ប្រធាន** មេត្តាសម្រេចតាមការស្នើសុំដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមប្រធាន** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

ថ្ងៃ ខែ ឆ្នាំ ,ព.ស
រាជធានីភ្នំពេញ,ថ្ងៃទី ខែ ឆ្នាំ
**ម្ចាស់បំណុល**

Scanned with CamScanner

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

## ដីកាសម្រេចជ្រើសតាំងអ្នកវាយតម្លៃ

លេខ  យើង  ចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ

- បានឃើញ មាត្រា ៤៣០-១ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឲ្យប្រើតាម ព្រះរាជក្រម នស/ រកម/ ០៧០៦/ ០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។
- បានឃើញ សំណុំរឿងអនុវត្តដោយបង្ខំលេខ  ចុះថ្ងៃទី  ខែ  ឆ្នាំ  របស់សាលាដំបូងរាជធានីភ្នំពេញដែលមាន ៖

**ម្ចាស់បំណុលនៃការអនុវត្ត៖** ក្រុមហ៊ុន  CO., LTD.) មានទីស្នាក់ការនៅផ្ទះជាតិលេខ  សង្កាត់  ខណ្ឌ  រាជធានីភ្នំពេញ តំណាងដោយលោក  មានអាសយដ្ឋាននៅផ្ទះលេខ  ផ្លូវ  ភូមិ  សង្កាត់  ខណ្ឌចំការមន រាជធានីភ្នំពេញ។

**កូនបំណុលនៃការអនុវត្ត៖** លោកស្រី  កើតថ្ងៃទី  ខែ  ឆ្នាំ  ជនជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ  ចុះថ្ងៃទី  ខែ  ឆ្នាំ  មានទីលំនៅបច្ចុប្បន្នផ្ទះលេខ  ផ្លូវលេខ  ភូមិ  សង្កាត់  ខណ្ឌ  រាជធានីភ្នំពេញ។

- បានឃើញ ពាក្យស្នើសុំជ្រើសតាំងអ្នកវាយតម្លៃអចលនវត្ថុសម្រាប់ការលក់ដោយបង្ខំ ចុះថ្ងៃទី  ខែ  ឆ្នាំ  របស់ម្ចាស់បំណុលលោក  បានស្នើសុំឲ្យជ្រើសតាំងក្រុមហ៊ុនវាយតម្លៃ ក្រុមហ៊ុន  ដែលមានទីតាំងស្ថិតនៅផ្ទះលេខលេខ  ផ្លូវលេខ  ភូមិ  សង្កាត់  ខណ្ឌចំការមន រាជធានីភ្នំពេញ ដើម្បីធ្វើការវាយតម្លៃ លើអចលនវត្ថុដែលជាកម្មសិទ្ធិរបស់កូនបំណុល។
- បានឃើញ ដីកាសម្រេចចាប់ផ្ដើមលក់ដោយបង្ខំលេខ  ចុះថ្ងៃទី  ខែ  ឆ្នាំ  របស់សាលាដំបូងរាជធានីភ្នំពេញ។

### សម្រេច

១. ចាត់តាំងក្រុមហ៊ុន  ដែលមានទីតាំងស្ថិតនៅផ្ទះលេខលេខ  ផ្លូវលេខ  ភូមិ  សង្កាត់  ខណ្ឌ  រាជធានីភ្នំពេញ ឲ្យធ្វើការវាយតម្លៃលើអចលនវត្ថុដែលមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ  ចុះថ្ងៃទី  ខែ  ឆ្នាំ  ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានីភ្នំពេញ មានទី តាំងស្ថិតនៅភូមិ  សង្កាត់  ខណ្ឌ  រាជធានីភ្នំពេញ

២. ផ្ញើលទ្ធផលនៃការស្រាវជ្រាវ និងវាយតម្លៃអចលនវត្ថុខាងលើ មកតុលាការអោយបានឆាប់តាមការគួរ។

ថ្ងៃ  ខែ  ឆ្នាំ  ព.ស

រាជធានីភ្នំពេញ ថ្ងៃទី  ខែ  ឆ្នាំ

ចៅក្រម

ភ្ជាប់មកជាមួយនូវ៖

-ដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំលេខ  ចុះថ្ងៃទី  ខែ  ឆ្នាំ  (ថតចម្លងចំនួន ០១ច្បាប់)។

Scanned with CamScanner

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងរាជធានីភ្នំពេញ

លេខ

## ដីកាបង្គាប់ឲ្យស្រាវជ្រាវស្ថានភាព
## បច្ចុប្បន្ននៃអចលនវត្ថុ

**យើង** **ចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ**

- **បានឃើញ** មាត្រា ៤៣៤-២ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រម នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦
- **បានឃើញ** សំណុំរឿងអនុវត្តដោយបង្ខំលេខ ចុះថ្ងៃទី ខែ ឆ្នាំ របស់សាលាដំបូងរាជធានីភ្នំពេញដែលមាន ៖

**ម្ចាស់បំណុលនៃការអនុវត្តៈ** ក្រុមហ៊ុន CO., LTD.) មានទីស្នាក់ការនៅផ្លូវជាតិលេខ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ តំណាងដោយលោក មានអាសយដ្ឋាននៅផ្ទះលេខ ផ្លូវ ភូមិ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ។

**កូនបំណុលនៃការអនុវត្តៈ** លោកស្រី កើតថ្ងៃទី ខែ ឆ្នាំ ជនជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ចុះថ្ងៃទី ខែ ឆ្នាំ មានទីលំនៅបច្ចុប្បន្នផ្ទះលេខ ផ្លូវលេខ ភូមិ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ។

- **បានឃើញ** ដីកាសម្រេចចាប់ផ្តើមលក់ដោយបង្ខំលេខ ចុះថ្ងៃទី ខែ ឆ្នាំ របស់សាលាដំបូងរាជធានីភ្នំពេញ។

### សម្រេច

១. បង្គាប់ឲ្យមន្ត្រីអាជ្ញាសាលា ចុះធ្វើការស្រាវជ្រាវអំពីសណ្ឋានអចលនវត្ថុ អំពីទំនាក់ទំនង និងការកាន់កាប់ព្រមទាំងស្ថានភាពផ្សេងៗនៃអចលនវត្ថុដែលជាកម្មសិទ្ធិរបស់កូនបំណុល នូវអចលនវត្ថុដែលមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ចុះថ្ងៃទី ខែ ឆ្នាំ ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានីភ្នំពេញ មានទីតាំងស្ថិតនៅភូមិ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ

២. បន្ទាប់ពីចុះធ្វើការស្រាវជ្រាវរួចមក សូមផ្ញើលទ្ធផលមកសាលាដំបូងរាជធានីភ្នំពេញ វិញឲ្យឆាប់តាមលទ្ធភាពអាចធ្វើបាន។

៣. ក្នុងករណីមានឧបសគ្គរាំងនៃការអនុវត្តនេះ អាជ្ញាសាលាត្រូវប្រើកំលាំងមានសមត្ថកិច្ចដើម្បី ឱវត្តឲ្យបានសម្រេចតាមបញ្ញត្តិមាត្រា ៣៣៨ កថាខណ្ឌ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

ថ្ងៃ ខែ ឆ្នាំ ព.ស

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ

**ចៅក្រម**

**ភ្ជាប់មកជាមួយនូវៈ**

-ដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំលេខ ...
ចុះថ្ងៃទី ខែ ឆ្នាំ ( ថតចម្លងចំនួន ០១ច្បាប់)។

Scanned with CamScanner

**ព្រះរាជាណាចក្រកម្ពុជា**

**KINGDOM OF CAMBODIA**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**Nation Religion King**

លេខៈ... ...ប.រ.គ

សាលាដំបូងរាជធានីភ្នំពេញ
បញ្ជី | លេខ...
ថ្ងៃ... ខែ... ឆ្នាំ...
ម៉ោង... នាទី

ជូនចៅក្រម...
ពិនិត្យ និងចាត់ការ

**<u>សូមគោរពជូន</u>**

**លោក ចៅក្រមអនុវត្តនៃសាលាដំបូងរាជធានីភ្នំពេញ**

**កម្មវត្ថុៈ** ស្ដីពីការបញ្ជូនរបាយការណ៍វាយតម្លៃអចលនវត្ថុលេខ ចុះថ្ងៃ ខែ ឆ្នាំ ដែលមាន អាសយដ្ឋានស្ថិតនៅ ភូមិ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ។

**យោងៈ** ដីកាសម្រេចជ្រើសតាំងអ្នកវាយតម្លៃលេខ ចុះថ្ងៃទី ខែ ឆ្នាំ របស់សាលាដំបូងរាជធានីភ្នំពេញ។

តបតាមកម្មវត្ថុ និងយោងខាងលើ ក្រុមហ៊ុន សូមជម្រាបជូនលោក ចៅក្រម មេត្តាជ្រាបថា ក្រុមការងាររបស់ក្រុមហ៊ុនយើងខ្ញុំបានចុះធ្វើការសិក្សាស្រាវជ្រាវ និងវាយតម្លៃអចលនវត្ថុ (ដី) ទំហំ ម៉ែត្រក្រឡា មានដែលទីតាំងស្ថិតនៅ ភូមិ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ មានប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ភព ចុះថ្ងៃទី ខែ ឆ្នាំ តាមដីកាសម្រេចជ្រើសតាំងអ្នកវាយតម្លៃលេខ ចុះថ្ងៃទី ខែ ឆ្នាំ របស់សាលាដំបូងរាជធានីភ្នំពេញ។ ដូចនេះក្រោយពីការសិក្សាស្រាវជ្រាវយ៉ាងល្អិតល្អន់ និងវាយតម្លៃរួចមក អចលនវត្ថុខាងលើនេះមានតម្លៃសរុបចំនួន **ដុល្លារអាមេរិក ( អាមេរិកគត់)។**

អាស្រ័យហេតុនេះ ក្រុមហ៊ុន សូមបញ្ជូនរបាយការណ៍វាយតម្លៃអចលវត្ថុខាងលើជូន លោកចៅក្រម ដើម្បីពិនិត្យនិងចាត់ការតាមនីតិវិធីច្បាប់។

សូមលោក ចៅក្រម ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ។

រាជធានីភ្នំពេញ ថ្ងៃ ខែ ឆ្នាំ ត្រីស័ក ព.ស.
ត្រូវនឹងថ្ងៃទី ខែ ឆ្នាំ

**ជ. នាយក**

**ចំពោះ**

- របាយការណ៍វាយតម្លៃអចលនវត្ថុលេខ ចុះថ្ងៃទី ខែ ឆ្នាំ (ច្បាប់ដើម) ចំនួន ០១ ច្បាប់

Scanned with CamScanner

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងរាជធានីភ្នំពេញ

លេខ

## ដីកាសម្រេចកំណត់តម្លៃលក់អប្បបរមា

**យើង ចៅក្រមអនុវត្តនៃសាលាដំបូងរាជធានីភ្នំពេញ**

- បានឃើញមាត្រា ៤៣២ និងមាត្រា ៤៣៧ នៃក្រមនីតិវិធីរដ្ឋប្បវេណីរបស់ព្រះរាជាណាចក្រកម្ពុជាដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៦០៧/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៦
- បានឃើញសំណុំរឿងអនុវត្តដោយបង្ខំលេខ ចុះថ្ងៃទី ខែ ឆ្នាំ
- បានឃើញលទ្ធផលនៃការស្រាវជ្រាវ និងវាយតម្លៃលើអចលនវត្ថុ របស់ក្រុមហ៊ុន

លេខ ចុះថ្ងៃទី ខែ ឆ្នាំ

**យល់ឃើញថា**

១.អចលនវត្ថុ មានទីតាំងស្ថិតនៅភូមិព្រែកតាពៅ សង្កាត់ព្រែកប្រា ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ មានទំហំសរុប ដែលមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ចុះថ្ងៃទី ខែ ឆ្នាំ ជាកម្មសិទ្ធិរបស់លោកស្រី គឹម ហួយ ត្រូវបានក្រុមហ៊ុនអចលនវត្ថុ គ្រុប វាយតម្លៃសម្រាប់ការលក់ដោយបង្ខំចំនួន USD
, ដុល្លារអាមេរិច។

២. តាមមាត្រា ៤៣៧ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី បានកំណត់ថា ជនដែល បម្រុងនឹងធ្វើសំណើទិញអចលនវត្ថុ ត្រូវដាក់ប្រាក់ធានាដែលមានចំនួនស្មើនឹងចំនួន ១ ភាគ ១០ (មួយភាគដប់) នៃតម្លៃលក់អប្បបរមា និងអាចកំណត់ចំនួនលើសពីនេះប្រសិនតុលាការយល់ឃើញថាសមរម្យ។

**ហេតុដូច្នេះ**

**តុលាការសម្រេចកំណត់**

| លេខកម្មវត្ថុ | តម្លៃលក់អប្បបរមា | ប្រាក់ធានាលើសំណើទិញ |
|---|---|---|
| ១ | USD | USD |
| សំគាល់ | | |

ថ្ងៃ ខែ ឆ្នាំ ព.ស

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ

ចៅក្រម

Scanned with CamScanner

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

លេខ

# ដីកាបង្គាប់ឲ្យអនុវត្តការលក់

**យើង ចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ**

- បានឃើញ មាត្រា ៤៣៦ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីរបស់ព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ ២០០៦
- បានឃើញសំណុំរឿងអនុវត្តដោយបង្ខំលេខ ចុះថ្ងៃទី ខែ ឆ្នាំ របស់សាលាដំបូងរាជធានីភ្នំពេញ
- បានឃើញដីកាសម្រេចកំណត់តម្លៃលក់អប្បបរមា លេខ ចុះថ្ងៃទី ខែ ឆ្នាំ

## សម្រេច

បង្គាប់ឲ្យអាជ្ញាសាលា អមសាលាដំបូងរាជធានីភ្នំពេញ ធ្វើការអនុវត្តការលក់ដោយបង្ខំចំពោះអចលនវត្ថុដូចដែលមានបញ្ជាក់ នៅក្នុងបញ្ជីអចលនវត្ថុតាមវិធីដូចខាងក្រោម៖

- វិធីលក់ ៖ លក់ឡាយឡុងដោយស្រោមសំបុត្រ
- កាលបរិច្ឆេទនៃការលក់ ៖ ម៉ោង ព្រឹក ថ្ងៃទី ខែ ឆ្នាំ
- ទីកន្លែងលក់ ៖ បន្ទប់លក់ នៃសាលាដំបូងរាជធានីភ្នំពេញជាន់ទី
- តម្លៃលក់អប្បបរមា ៖ ដុល្លារអាមេរិក
- ប្រាក់ធានាលើសំណើរទិញ ៖ ដុល្លារអាមេរិក
- កាលបរិច្ឆេទដើម្បីចេញដីកាសម្រេចការលក់៖ ថ្ងៃទី ខែ ឆ្នាំ

ថ្ងៃ ខែ ឆ្នាំ ព.ស

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ

ចៅក្រម

Scanned with CamScanner

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងរាជធានីភ្នំពេញ**
**សំណុំរឿងអនុវត្តដោយបង្ខំ**
**លេខ**
**លេខ**

# ការផ្សាយជាសាធារណៈ
# អំពីការលក់ឡាយឡុងដោយស្រោមសំបុត្រ

យើង ជាក្រឡាបញ្ជី នៃសាលាដំបូងរាជធានីភ្នំពេញ

បានឃើញ មាត្រា ៤៣៦ កថាខណ្ឌទី៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីរបស់ព្រះរាជាណាចក្រកម្ពុជាដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។

បានឃើញដីកាបង្គាប់ឱ្យអនុវត្តការលក់ លេខ ចុះថ្ងៃទី ខែ ឆ្នាំ របស់សាលាដំបូងរាជធានីភ្នំពេញ។

## សូមប្រកាសថា

នៅក្នុងសំណុំរឿងអនុវត្តដោយបង្ខំលេខ ចុះថ្ងៃទី ខែ ឆ្នាំ ចំពោះអចលនវត្ថុដែលមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ កក ចុះថ្ងៃទី ខែ ឆ្នាំ បញ្ជាក់ក្នុងឧបសម្ព័ន្ធនៃបញ្ជីអចលនវត្ថុ ត្រូវបានតុលាការចេញដីកាបង្គាប់ឱ្យអនុវត្តការលក់ដោយបង្ខំចំពោះអចលនវត្ថុតាមវិធីដូចខាងក្រោម:

- **វិធីលក់** ៖ លក់ឡាយឡុងដោយស្រោមសំបុត្រ
- **កាលបរិច្ឆេទនៃការលក់** ៖ ម៉ោង ព្រឹក ថ្ងៃទី ខែ ឆ្នាំ
- **ទីកន្លែងលក់** ៖ បន្ទប់លក់ នៃសាលាដំបូងរាជធានីភ្នំពេញ
- **តម្លៃលក់អប្បបរមា** ៖ ដុល្លារអាមេរិក
- **ប្រាក់ធានាលើសំណើទិញ** ៖ ដុល្លារអាមេរិក
- **វិធីផ្តល់ប្រាក់ធានាលើសំណើទិញខាងលើ** ៖ ដោយប្រាក់សុទ្ធ ឬដោយមូលប្បទានប័ត្រ
- **អំឡុងពេលសំរាប់ឱ្យសាធារណជនមើលអំពី ឯកសារលំអិតអំពីវត្ថុ និង របាយការណ៍ ស្តីពីការវាយតម្លៃ ជាអាទិ៍ គឺ ចាប់ពីថ្ងៃទី ខែ ឆ្នាំ ដល់ថ្ងៃទី ខែ ឆ្នាំ**
- **កាលបរិច្ឆេទដើម្បីចេញដីកាសម្រេចការលក់៖ ថ្ងៃទី ខែ ឆ្នាំ**

ថ្ងៃ ខែ ឆ្នាំ ព.ស

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ

**ក្រឡាបញ្ជី**

Scanned with CamScanner

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងរាជធានីភ្នំពេញ

លេខ

**ដីកាសម្រេចអនុញ្ញាតឲ្យលក់**

យើង ............................................ ចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ។

បានឃើញ មាត្រា៥៤២-១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

បានឃើញ សំណុំរឿងអនុវត្តលេខ ... ចុះថ្ងៃទី ... ខែ... ឆ្នាំ ... របស់សាលាដំបូងរាជធានីភ្នំពេញ ។

បានឃើញ សំណើទិញអចលនវត្ថុរបស់ឈ្មោះ ............... ភេទ... អាយុ...ឆ្នាំ ទីលំនៅសព្វថ្ងៃ .................................................................................................... រាជធានីភ្នំពេញ ។

**សាលាដំបូងរាជធានីភ្នំពេញសម្រេច**

អនុញ្ញាតឲ្យលក់អចលនវត្ថុដែលមានបញ្ជាក់នៅក្នុងបញ្ជីអចលនវត្ថុ ទៅឲ្យបុគ្គលខាងក្រោនេះ ពីព្រោះបុគ្គលនេះបានធ្វើសំណើទិញអចលនវត្ថុក្នុងតម្លៃអតិបរមាចំនួន .............$ (...............ដុល្លារអាមេរិក) គឺឈ្មោះ ..................... ភេទ... អាយុ...ឆ្នាំ ទីលំនៅសព្វថ្ងៃ.........................រាជធានីភ្នំពេញ ។

រាជធានីភ្នំពេញ,ថ្ងៃទី .... ខែ....... ឆ្នាំ............

**ចៅក្រម**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងរាជធានីភ្នំពេញ

លេខ

**ដីកាសម្រេចកំណត់អំឡុងពេលបង់ថ្លៃលក់**

យើង ........................................................ ចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ។

បានឃើញ មាត្រា៥៥៧-១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

បានឃើញ សំណុំរឿងអនុវត្តលេខ ... ចុះថ្ងៃទី... ខែ... ឆ្នាំ... របស់សាលាដំបូងរាជធានីភ្នំពេញ ។

បានឃើញ ដីកាសម្រេចអនុញ្ញាតឲ្យលក់លេខ ......................... ចុះថ្ងៃទី... ខែ... ឆ្នាំ ... របស់សាលាដំបូងរាជធានីភ្នំពេញ ។

**សាលាដំបូងរាជធានីភ្នំពេញសម្រេច**

ស្ដីពីអចលនវត្ថុដែលមាននៅក្នុងបញ្ជីអចលនវត្ថុ តុលាការសម្រេចកំណត់អំឡុងពេលដើម្បីឲ្យអ្នកទិញបង់ថ្លៃលក់ដោយគិតចាប់ពីថ្ងៃនេះតទៅ រហូតដល់ថ្ងៃ... ខែ... ឆ្នាំ... រៀងរាល់ម៉ោងធ្វើការ ។

រាជធានីភ្នំពេញ,ថ្ងៃទី .... ខែ........ ឆ្នាំ.............

**ចៅក្រម**

## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## សេចក្តីថ្លែងការណ៍
## ស្តីពីការបង់ថ្លៃលក់អចលនវត្ថុ
## គោរពជូន
## ក្រឡាបញ្ជីនៃសាលាដំបូងរាជធានីភ្នំពេញ

រាជធានីភ្នំពេញ ថ្ងៃទី... ខែ... ឆ្នាំ...

ចំពោះរឿងក្តីនៃការលក់ដោយបង្ខំចំពោះអចលនវត្ថុលេខ... ចុះថ្ងៃទី... ខែ... ឆ្នាំ... របស់សាលាដំបូងរាជធានីភ្នំពេញ ខ្ញុំឈ្មោះ ..................... ភេទ... អាយុ...ឆ្នាំ ជាភាគីអ្នកទិញ បានបង់ថ្លៃលក់អចលនវត្ថុ ជាអាទិ៍ដូចខាងក្រោម ៖

| សេចក្តីរាយការណ៍ | តម្លៃ |
|---|---|
| ថ្លៃលក់ (ប្រាក់ធានា ១០%ត្រូវបានដកចេញ) | |
| ពន្ធចុះបញ្ជីផ្ទេរកម្មសិទ្ធិនៃអចលនវត្ថុ | |
| ពន្ធលុបចោលការចុះបញ្ជីអំពីការរឹបអូស ជាអាទិ៍ | |
| សោហ៊ុយផ្ញើលិខិតផ្ទុកផ្តាក់អោយចុះបញ្ជីទៅមន្ទីរសុរិ យោដីតាមប៉ុស្តិ៍ | |
| សោហ៊ុយផ្ញើឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃសៀវភៅចុះបញ្ជីទៅក្រឡាបញ្ជី | |
| សោហ៊ុយផ្ញើឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃ សៀវភៅចុះបញ្ជីបញ្ជូនទៅអ្នកទិញ | |
| សរុប | |

នៅកាលបរិច្ឆេទដដែលនេះ ខ្ញុំ......................ក្រឡាបញ្ជីនៃសាលាដំបូងរាជធានីភ្នំពេញ បានទទួល ការបង់ថ្លៃដូចដែលបានសរសេរខាងលើនេះ ។

ក្រឡាបញ្ជី

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងរាជធានីភ្នំពេញ

លេខ

**លិខិតផ្ទុកផ្តាក់**

**ឲ្យចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិ**

យើង ............................................... ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

**សូមជម្រាបជូន**

**លោកប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានីភ្នំពេញ**

**កម្មវត្ថុ:** សំណើរចុះបញ្ជីផ្ទេរកម្មសិទ្ធិ និងលុបចោលលិខិតផ្ទុកផ្តាក់ឲ្យចុះបញ្ជីអំពីការរឹអូសអចលនវត្ថុលេខ ... ចុះថ្ងៃទី... ខែ... ឆ្នាំ... របស់សាលាដំបូងរាជធានីភ្នំពេញ ។

**យោង:**
- សំណុំរឿងអនុវត្តលេខ ... ចុះថ្ងៃទី... ខែ... ឆ្នាំ... របស់សាលាដំបូងរាជធានីភ្នំពេញ ។
- ដីកាសម្រេចអនុញ្ញាតឲ្យលក់លេខ ... ចុះថ្ងៃទី... ខែ... ឆ្នាំ... របស់សាលាដំបូងរាជធានីភ្នំពេញ ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន លោកប្រធានជ្រាបថា: សាលាដំបូងរាជធានីភ្នំពេញ បានធ្វើការលក់ឡាយឡុងនូវអចលនវត្ថុដែលមានវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អលចនវត្ថុលេខ ...... ចុះថ្ងៃទី... ខែ... ឆ្នាំ... របស់ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានីភ្នំពេញ ដែលមានទីតាំងស្ថិតនៅ ............................ រាជធានីភ្នំពេញ ដែលជាកម្មសិទ្ធិរបស់កូនបំណុលនៃការអនុវត្តឈ្មោះ ...................... ភេទ... អាយុ...ឆ្នាំ ទៅឲ្យឈ្មោះ ...................... ភេទ... អាយុ...ឆ្នាំ ។

អ្នកដាក់ពាក្យសុំឲ្យចុះបញ្ជីផ្ទេរកម្មសិទ្ធិឈ្មោះ ....... ភេទ... អាយុ...ឆ្នាំ មានទីលំនៅបច្ចុប្បន្ន........................................................................................ រាជធានីភ្នំពេញ ។

អាស្រ័យហេតុនេះសូមលោកប្រធានធ្វើការចុះបញ្ជីផ្ទេរកម្មសិទ្ធិ និងលុបចោលលិខិតផ្ទុកផ្តាក់ឲ្យចុះបញ្ជីអំពីការរឹអូសអចលនវត្ថុលេខ ... ចុះថ្ងៃទី... ខែ... ឆ្នាំ... របស់សាលាដំបូងរាជធានីភ្នំពេញ រួចផ្ញើឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃសៀវភៅចុះបញ្ជីនោះ ព្រមទាំងសោហ៊ុយចាត់ចែងការចុះបញ្ជី មកតុលាការវិញដោយក្តីអនុគ្រោះ ។

សូមលោកប្រធានទទួលនូវការគោរពអំពីខ្ញុំ ។

រាជធានីភ្នំពេញ,ថ្ងៃទី .... ខែ........ ឆ្នាំ.............

**ក្រឡាបញ្ជី**